# យើងអាន



ថ្នាក់ទី ១០

CA 80

•ឈូក ម៉ឹង-ម៉ៅ
អធិការបឋមសិក្សា
ចាងហ្វាងទីចាត់ការគរុកោសល្យ

•ហួរ-ហោង
គ្រូបង្រៀន
គណៈកម្មការជាតិពិនិត្យសៀវភៅសិក្សា

[illegible]

# រៀនអាន

ថ្នាក់ទី ១០

កម្មវិធីសិក្សាថ្មី

អ្នកគូរ រស់ - កាន គ្រូបង្រៀន

# អំណរគុណ

ជាបឋម យើងសូមសំដែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះលោក

ពុង-ប៉េងចេង ជាប្រធាន ។ អគ្គអង្គមាស់ . . .

ស៊ីសុវត្ថិ សុវណ្ណារ៉េត លោក ដៃ-ដេង

លោក ស៊ុយ-សុន — គីមយិន-ស៊ុសាមុត

— ប៊ូរ-ទាំម៉ៅ — ធីវ-អ៊ុល

— គីម-ឈុំ — ធី-សែម

— លី-ឡាច — ឃក-អៀង

ជាសមាជិក នៃគណៈកម្មការជាតិពិនិត្យសៀវភៅសិក្សា ដែលបានជំនុំពិនិត្យព្រមទាំងកែសម្រួលសៀវភៅនេះ អស់ពេល ៤ ខែ ដើម្បីឲ្យមេកាន រូបភាព ហើយនឹងការយកមកក្នុងសៀវភៅ "យើងអាន" ថ្នាក់ទី ១០ យើង មានតម្លៃក្នុងការសិក្សាកាន់តែជាក់ស្តែងឡើង ។

អំពើដ៏ប្រសើរនេះ បញ្ជាក់ឲ្យឃើញថា ទ្រង់ហើយនឹងអស់លោកគិតដល់ប្រយោជន៍កូនខ្មែរ ក្នុងការសិក្សាពិតប្រាកដ ។

ភ្នំពេញ នៅថ្ងៃទី ១០ ខែកញ្ញា ១៩៦៤

អ្នកនិពន្ធ

# ប្រកាសក្រសួងអប់រំជាតិនិងវិចិត្រសិល្បៈ

លេខ - ១៤៥២ ចុះថ្ងៃទី ៧-៥-៦៤

បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ

បានឃើញ . . .

## សម្រេច :

ប្រការ ១ — សៀវភៅដែលមានចំណងជើង «យើងអាន» សម្រាប់ថ្នាក់ទី ១០ រៀបរៀងដោយលោក ឈុក-ម៉ុង-ម៉ៅ និង ហួរ-ហោង ធ្វើការនៅទីចាត់ការកិច្ចការគរុកោសល្យ ត្រូវបានបញ្ចូលក្នុងពពួកសៀវភៅសិក្សា និងការផ្សាយខាងផ្នែកសិក្សា ហើយអនុញ្ញាតឲ្យប្រើប្រាស់នៅគ្រប់សាលារៀនសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ — នាយខុទ្ទកាល័យនិងអគ្គនាយកនៃការអប់រំ ត្រូវទទួលភារៈតាមមុខក្រសួងរៀងខ្លួន ដើម្បីឲ្យបានសម្រេចតាមប្រកាសក្រសួងនេះ ។

ភ្នំពេញ នៅថ្ងៃទី ៧ ឧសភា គ-ស ១៩៦៤

ហត្ថលេខា : ភូ-ស៊ីអ៊ុយ

រដ្ឋលេខាធិការក្រសួងអប់រំជាតិនិងវិចិត្រសិល្បៈ

# កថាមុខ

«យើងអាន» ថ្នាក់ទី ១០ ជាមេអានបន្តពីសៀវភៅ «យើងអាន» ថ្នាក់ទី ១១ ដែលយើងបានចេញផ្សាយក្នុងឆ្នាំ ១៩៦២ តាមប្រកាសក្រសួងអប់រំជាតិលេខ ២០៦៦ ។ យើងយល់ថា មេអានថ្នាក់ទី ១០ មិនត្រូវឲ្យណែនទៅដោយពាក្យសំដីច្រើនពេកទេ ព្រោះនាំឲ្យក្មេងអាយុ ៨ ឬ ៩ ឆ្នាំ ដែលទើបនឹងហាត់អានបានពីរឆ្នាំ ពិបាកអានពិបាកយល់ ។

អត្ថបទ «យើងអាន» ជារឿងនិទាន ស្ដីពីមនុស្ស-ក្មេង-សត្វដែលយើងសរសេរចាត់តាំងជាតួ ឲ្យដើរធ្វើសកម្មភាពចុះឡើងនៅជុំវិញទីប្រជុំរឿងយ៉ាងពិរោះ ហើយមានជំឡែក្នុងការអប់រំផង ។ អត្ថបទយើងអានបែកជាវគ្គ ៗ ជាហេតុងាយកាយទំនងផ្លូវសេចក្ដីឲ្យន័យ-មិនប្រាប់ត្រង់-អ្វីដែលសិស្សថ្នាក់នេះត្រូវដឹង តាមវ័យលូតលាស់របស់វា ។

ឃ្លាក្នុងអត្ថបទ «យើងអាន» ងាយហើយច្បាស់ ប៉ុន្តែគ្មានលក្ខណៈជាឃ្លាក្មេងទេ ។ ចំពោះភាសាវិញ ក៏យើងនិយមតែពាក្យណា ដែលខ្មែរយើងធ្លាប់ប្រើរាល់ថ្ងៃដែរ ។

យើងមិនអាចរចនារូបភាពក្នុង «យើងអាន» ឲ្យមានពណ៌ធម្មជាតិបានឡើយ ព្រោះអស់ថ្លៃច្រើនណាស់ តែទោះបីមានគំនូរឥតពណ៌ខ្លះ ក៏គង់រូបភាពនេះធ្វើមេអានយើងឲ្យមានរូបិយបង្គួរហើយដែរ ។

ការយកមក្នុង «យើងអាន» មានច្រើនបែបប្លែកៗ តែមានភាពទាក់ទងគ្នា ហើយជួយឲ្យជំរុញគ្នាទៅវិញទៅមកជានិច្ច ។ យើងយល់ថា ការយ៉កម្មបែបនេះ អាចនាំសិស្សឲ្យយល់វេយ្យាករណ៍-ឲ្យដុះគំនិតថ្មី ឲ្យបែកយោបល់ផ្សេងៗ-ឲ្យចូលចិត្តនិយាយនិងសរសេរភាសាជាតិយ៉ាងរីករាយ ។

តាមវិធីថ្មីមួយ ស្របនឹងគរុកោសល្យទំនើប យើងសុំស្នើលោកគ្រូ-អ្នកគ្រូថា នៅថ្នាក់ទី ១០ នេះ គួរបាត់ឲ្យសិស្សមានទម្លាប់ក្នុងការអានដោយស្ងៀមស្ងាត់ (Lecture silencieuse) បានបួន ឬ ប្រាំនាទី មុននឹងតាំងសំនួរផ្សេងៗ ដល់សិស្សផង ព្រោះគោលដៅរបស់មេអានបិតនៅត្រង់ :

១ – អានដោយភ្នែកបានរហ័ស ២ – បណ្ដុះគំនិតឲ្យសិស្សចូលចិត្តអាន ។ ឯការអានឮម្នាក់ម្ដងឬឮព្រមៗគ្នា ដូចយើងបានធ្វើហូរហែមកនោះ គ្រាន់តែជាមធ្យោបាយសម្រាប់គ្រូបង្រៀនសិស្ស ឲ្យចេះអានប៉ុណ្ណោះទេ ។

សរុបសេចក្ដីទៅ យើងយល់ថា «យើងអាន» ដែលយើងបានរៀបចំឡើង តាមលំនាំបច្ចេកទេសគរុកោសល្យទំនើប អាចបាត់ជាសម្ភារៈមួយ សម្រាប់លោកគ្រូ-អ្នកគ្រូបង្រៀនមេអាន ដោយប្រើសកម្មវិធីនៅថ្នាក់ទី១០ តាមគំនិតកម្មវិធីសិក្សាសព្វថ្ងៃនេះហើយ ។

ភ្នំពេញ នៅថ្ងៃទី ១០ ខែ កញ្ញា ១៩៦៤

អ្នកនិពន្ធ



## ១ – បំណាន ស៊ុឃឹម

១ – ព្រហស្បតិជាថ្ងៃធំមួយ នៅភូមិប្រាសាទ ។ ថ្ងៃនោះ អ្នកភូមិភ្ញាក់ពីព្រលឹម រសសត្វផង ។ គេស្លៀកពាក់ ខោអាវស្អាតបាត ហើយរៀបចំផលដំណាំ ពងមាន់ ពងទា បុះទៅលក់នៅផ្សារ បំបក់ រួចទិញអីវ៉ាន់ខ្លះ ត្រឡប់មកផ្ទះវិញ ។

២ – ថ្ងៃព្រហស្បតិនេះ ស៊ុឃឹម គ្មានបានសប្បាយចិត្តនឹងគេទេ ។ វាកើតទុក្ខ ព្រោះគ្មានអ្វីយកទៅលក់ឯផ្សារ ។ ប៉ុន្តែវាភ្ញាក់ពីព្រលឹមដូចគេឯងដែរ ។ ស៊ុឃឹម ជួយដកស្ពៃ បេះត្រឡាច ស្ពៅ នោង ហើយនឹងជួយចងជើងមាន់ ជើងទា ឪពុកម្តាយវា ។ តើស៊ុឃឹម បានទៅផ្សារនឹងគេឬទេ ? រៀបចំហើយ ម្តាយ ស៊ុឃឹម ទូល

កញ្ចើមាន់-ទា ឪពុកវារែកបន្លែទៅផ្សារភ្លាមគ្មានអែអង់ ។ ស៊ីឌឹម សុំម្ដាយថា :- ម៉ែ! ខ្ញុំសុំទៅផ្សារជាមួយម៉ែដែរ ។

-ទេ! អញឲ្យឯងទៅផ្សារ តែកាលណាឯងមានអ្វីយកទៅលក់ផង ។

៣ - ស៊ីឌឹម នៅក្មេង អាយុទើបនឹងបាន ១០ ឆ្នាំ ។ រាល់ថ្ងៃ វាជួយបោចស្មៅក្នុងច្បារ ជួយដងទឹកស្រោចដំណាំ ជួយធ្វើការគ្រប់មុខ ដល់ឪពុកម្ដាយវា ។ ស៊ីឌឹម ធ្វើការទាំងនេះ គ្មានបានអ្វីទាំងអស់ ខ្លាំងណាស់បានត្រឹមតែឲ្យ ឪពុក ម្ដាយ សប្បាយចិត្តប៉ុណ្ណោះ ។ បើម្ល៉េះ តើឲ្យគាមានអ្វីយកទៅលក់នៅឯផ្សារ ?

*គ្នា : បុ-អញ គេ វា គាត់ : ឲ្យគ្នាទៅផងគឺថាឲ្យអញ គេ វា គាត់ ទៅផង ។*

---

● *ជញ្ជាំងគិត : បើយើងទៅផ្សារដៃទទេ ឥតមានអ្វីយកទៅលក់ផង គិតតែទិញអីវ៉ាន់ពីផ្សារមក តើយើងរបខ្លួនឬទេ ? ស៊ីឌឹម ជាកូនល្អ ឃ្លាត្រង់ណាដែលបញ្ជាក់ថាយ៉ាងនេះ ។*

● *ការិយកម្ម : ចូរអ្នកហាត់ធ្វើឃ្លានឹងពាក្យ « គ្នា » ឲ្យបានសមតាមសេចក្ដីដែលត្រូវប្រើនឹងពាក្យនេះ ។*

## ២ ខំគ៣ – ស៊ីឌឹម មានមាន់មួយហើយ

១ – ខែចែត្រអាកាសក្ដៅណាស់ ។ មេមាន់សំពៅមួយ ក្រាបពងដល់កំណត់ហើយ ញាស់បានកូនតែមួយ ។ វាពុំព្រមបះពីសំបុកទេ ព្រោះវាមិនដឹងថា ពងឯទៀតស្អុយខូច ។ ម្ដាយ ស៊ីឌឹម ដឹងរឿងនេះ គឹកស្ដាយ ហើយនិយាយប្រាប់ស៊ីឌឹម ថា:

– អញមិនបង់ឲ្យមេសំពៅ បណ្ដើរកូនតែមួយសោះ ។ ពិត្ត អញបង់បំបែកកូននេះចេញ ឲ្យមេសំពៅឆាប់មានពងទៀត ប៉ុន្តែ មិនដឹងបានអ្នកណាចិញ្ចឹមកូនមាន់នេះ ។

– ខ្ញុំទទួលចិញ្ចឹម ឲ្យតែម៉ែឲ្យវាមកខ្ញុំដាប់ ។

– អើ! បើឯងចិញ្ចឹមវារស់ ដល់ធំឡើង ឯងយកវាទៅផ្សារ



លក់យកប្រាក់បុះ ។

២ – ស៊ុឌឹម ថែរក្សាកូនមាន់មិនបាញ់មេមាន់ទេ ។ កាលមាន់នៅតូច វាក្រុងរក្សាក្នុងអង្រុត ប្រយ័ត្នមិនឲ្យខ្លែងឬប្រមង់ឆាបបានឡើយ ។ ដល់ធំបន្តិច ទើប ស៊ុឌឹម បើកឲ្យមាន់វាដើររកស៊ី ។ ស៊ុឌឹម ឲ្យចំណីមាន់ ក្នុងមួយថ្ងៃពីរបួនដង ។ វាដាក់ឈ្មោះមាន់វាថា អាទោល ។

៣ – អាទោល ស្រឡាញ់ម្ចាស់វាណាស់ ។ កាលណាស៊ុឌឹមហៅ វារត់មករកហើយវាត្រដាងស្លាប អួតឲ្យ ស៊ុឌឹម មើលរាងវា ។ ថ្ងៃមួយ ម្ដាយ ស៊ុឌឹម ឃើញ អាទោល ពេញជំទង់ ក៏និយាយប្រាប់ស៊ុឌឹម ថា: អាទោល ធំល្មមលក់ហើយ កូនឯងយកវាទៅផ្សារបុះ ស៊ុឌឹម សប្បាយចិត្តណាស់ ព្រោះវារង់ចាំតែសំដីនេះ ។

៤ – ស្អែកឡើង ស៊ុឌឹម ឱប អាទោល ទៅផ្សារជាមួយឪពុកវា ។ តាមផ្លូវ ឪពុកនិយាយប្រាប់កូន: មាន់ជាតិ រោមលើបដូចអាទោល បានថ្លៃណាស់ កូនឯងលក់ ៣០ រៀលបានល្មម ។

ស៊ុឌឹម នឹកថា៣០រៀលមិនតិចទេ ។ វាគិតឃើញទិញបាល់កៅស៊ូមួយទុកលេង ទិញកន្សែងជូតមុខមួយឲ្យឪពុក ហើយនឹងក្រាស

មួយឲ្យម្ដាយ ។ សល់ពីនេះ វានឹងទិញស្ករគ្រាប់ ស៊ីឲ្យផ្អែតម្ដង ។

ខ្វែង: ន. ឈ្មោះសត្វស្លាបមួយយ៉ាង សម្បុរក្រហមក្រមៅ ត្រង់ក មានសម្បុរស បំពុះខុប ក្រញ៉ាំជើងចំណាប់អាចឆាបចាប់សត្វតូចៗស៊ីបាន ។

________________ ឥ . . .

• ជញ្ជឹងគិត: ហេតុម្ដេចបានជា ស៊ីឈឹម ហៅមាន់ថា អាខោល ? ក្នុងអត្ថបទទី ២ និងទី ៣ នេះ ស៊ីឈឹម ធ្វើជាកូនល្អម្ដងទៀត តើឃ្លាត្រង់ណាដែលបញ្ជាក់ថាយ៉ាងនោះ ។

• ការិយកម្ម: ប្អូនអ្នកបំពេញឃ្លានឹងពាក្យ ក្លែង ខ្វែង ក្រាស ក្រាស់ ។

ខ្ញុំនិយាយជាព្រម មិនគួរវាំ . . . . . . សំដីខ្ញុំជាទេសោះ ។ . . . . . .
អាឈីហោះខ្ពស់ណាស់ ។ សត្វ . . . ឆាបកូនមាន់ហៅស៊ីឈឹមមិនបានទេ ។
. . . . . . សិតសក់ខ្ញុំបាក់ធ្មេញអស់ខ្លះហើយ ។ ក្រដាសសៀវភៅសរសេរ
ខ្ញុំមិន . . . . . មិនស្ដើងទេ ល្មមតែខ្ញុំសរសេរបានស្រួល ។





## ៤-៥ – នៅផ្សារចំបក់

១ – ស៊ីម ឱប អាទោល ឈរនៅមុខតូប ដែលមានលក់ប្រដាប់ក្មេងលេង ។ អ្នកលក់ញញឹមរកវាហើយសួរ ៖

– អានាង! ឯងចង់បានអ្វី?

– បាល់កៅស៊ូមួយ! ប៉ុន្តែ ចាំលក់មាន់១ដាប់សិន ។

– ឱ! មាន់ឯងលក់ អញឲ្យ ២០ រៀល បើព្រមឯងយកបាល់កៅស៊ូមួយ ហើយអញថែមប្រាក់ឲ្យឯង ១៥រៀលទៀត ។ បាល់នេះសំបកវាក្រាស់ អញគិតថ្លៃតែប្រាំរៀល គ្មានយកចំណេញពីឯងទេ ។

– អរគុណហើយ ! ខ្ញុំចង់ដើរលក់មើលបន្តិចទៀតសិន ។

ជាតែប៉ុណ្ណោះ សុីឌឹម ឱប អាទោល ដើរចេញពីទីនោះភ្លាម ។

២ – សុីឌឹម ដើរក្រឡឹងផ្លូវ ។ ដល់មុខតូបលក់កន្សែងក្រាស-ក៊ែនតា . . . វាឈប់ មើលម្តងទៀត ។ អ្នកលក់ម្នាក់និយាយ

– កន្លែងនេះ មានរបស់ល្អ ៗ ណាស់ អានាងចង់បានអ្វីដែរ?

– កន្សែងហើយនឹងក្រាស ប៉ុន្តែចាំលក់អាទោល មាន់ខ្ញុំសិន ។

– មាន់ឯងឈ្មោះ អាទោល អ៊ែយ៉ា ! ធាត់ហើយ ខ្លាញ់ច្រើនផង ។ អញគិតថ្លៃឲ្យឯង ២៥ រៀល បើព្រម ឯងដូរយកកន្សែងមួយក្រាសមួយបុះ ហើយអញថែមប្រាក់ . . . ។

– អរគុណហើយ ខ្ញុំចង់ដើរលក់បន្តិចទៀត ក្រែងបានថ្លៃជាងនេះ ។

៣ – សុីឌឹម ដើរចុះ-ឡើង ស្រាប់តែជួបនឹងឪពុកវា ។

– ម៉េចកូន! គ្មានអ្នកណាតថ្លៃទិញមាន់ឯងទេ!

– មាន ពុក! តែគេឲ្យមិនទាន់ដល់ថ្លៃ ដូចពុកប្រាប់ ។

– ថ្លៃហើយកូនយកវាទៅលក់ឲ្យមីង ទូប ឯនោះ កុំឲ្យហួសពេល ។ សុីឌឹម ឱបអាទោល ដើរសំដៅរកមីង ទូប គ្មានបង្អង់ ។

ក្រឡឹង : កិ.វិ. ដែលមានដំណើរវិលជុំវិញ ដើរក្រឡឹង បរក្រឡឹង ហោះក្រឡឹងទីក្រុង សត្វហើរក្រឡឹងបឹង ។

• ជញ្ជឹងគិត : ស៊ីឌឹម មានគំនិតយ៉ាងណា បានជាវមិនព្រមលក់មាន់ឲ្យអ្នកទិញទី ១ ហើយនឹងអ្នកទិញទី ២ ? អ្នកទិញទាំងពីរនាក់នេះជាមនុស្សល្អត្រឹមត្រូវឬទេ ? ពីព្រោះអ្វីបានជាអ្នកដឹង ?

• រៀនពាក្យ : អំពីផ្សារ

នាម : ផ្សារ អ្នកលក់ អ្នកទិញ រាន លក់ទំនិញ បន្លែ ផ្លែឈើ មាន់ ទា ស៊ុត សាច់ អង្ករ ខុស ។

គុណនាម : ថ្លៃ ថោក ស្រស់ ក្រៀម ។

កិរិយាសព្ទ : លក់ ដូរ ទិញ តថ្លៃ ឡើងថ្លៃ ចុះថ្លៃ ដឹកនាំ ។

• ការិយកម្ម : ចូរអ្នកធ្វើឃ្លានឹងពាក្យខាងលើនេះ ឲ្យបានមួយឃ្លា ក្នុងពាក្យមួយម៉ាត់ ។

– អ្នកដែលទៅផ្សារនៅស្រុកអ្នកដែរ ចូរអ្នកនិយាយរៀបរាប់ពីផ្សារនោះ ផ្សារនៅស្រុកអ្នកនៅត្រង់ណា ? ឈ្មោះផ្សារអ្វី ? ពេលណាផ្សារនោះអ៊ូអរ ? ពីព្រោះអ្វី ? នៅផ្សារមានលក់អ្វីខ្លះ ? របស់ទាំងអស់នោះគេយកមកពីណា ? នៅជុំវិញផ្សារអ្នកឃើញមានអ្វីខ្លះ ? ពេលណាផ្សារនោះកាន់តែស្ងាត់ ? ចូរអ្នករៀបរាប់ពីប្រយោជន៍នៃផ្សារ ។

## ៦ – ស៊ឹម លក់អាកោល មិនដាច់ទេ

១ - នៅមុខវាំងមីងទូប សម្ការនំបញ្ចុក ផ្សាយក្លិនដល់ ស៊ឹម នាំឲ្យវានឹកឃ្លាន ។ ស៊ឹម ឱបមាន់ឈរមើល ។ មីងទូប ឃើញមាន់ នឹកបង់បាន ក៏សួរទិញយ៉ាងប្រញាប់ ។

– អាតាង! មាន់ឯងលក់ថ្លៃប៉ុន្មាន?

– មាន់នេះជាតល្អ ខ្ញុំលក់ថ្លៃបន្តិចហើយ ។

– មីងឲ្យ ៣០ រៀល! មីងមិនបាច់តថ្លៃទេ ។

ស៊ឹម ហាក់ដូចជាបង់លក់ ។ វានឹកថា ៣០ រៀលអញទិញ បានកន្សែង - ក្រាស - បាល់ - ស្ករគ្រាប់ - នំបញ្ចុក ហើយនៅសល់



ប្រាក់ខ្លះទៀតផង ។ ប៉ុន្តែ ដល់មីងទូចស្សបន្ថែម:

– មើប! ៣០ រៀល លក់ឬមិនលក់? ស៊ីឌីម បែរជាងា
មើលមកមាន់ ហើយឆ្លើយថា ចាំថ្ងៃក្រោយទៅវិញ ។

២ – ស៊ីឌីម ឱបអាទោល ផ្ទាប់នឹងដើមទ្រូងយ៉ាងខ្ជាំង ហើយ
ត្រឡប់មករកឪពុកវាជាបន្ទាន់ ។ តាមផ្លូវមកភូមិ ឪពុកបន្ទោស
កូនថា គេឲ្យមាន់ដល់ថ្លៃហើយឯងមិនលក់ ដូច្នេះឯងគ្មានអ្វីទិញ
នឹងគេហើយ ។ យើញទេ! ថ្ងៃនេះ ឯងបានតែឱបមាន់មកផ្សារ
ហើយឱបមាន់វិលទៅផ្ទះវិញ ។ ស៊ីឌីមនៅស្ងៀមមិនឆ្លើយថាអ្វីទេ
ឪពុកវាឡើយ ។ វាគិតតែដើរស្រួតឲ្យដល់ផ្ទះឆាប់ ។

---

• *ជញ្ជឹងគិត : អ្នកស្ទូរទិញមាន់ ស៊ីឌីម មានបីនាក់ តើអ្នកយល់ថា អ្នក
មួយណាដែលត្រឹមត្រូវជាងគេ? ពីព្រោះអ្វី? ស៊ីឌីម គិតយ៉ាងណា បានជាមិន
លក់មាន់ឲ្យមីងទូច? វាគិតថា មាន់វានៅលក់បានថ្លៃជាង៣០រៀលឬយ៉ាងណា*
(ក្មេងស្រឡាញ់បក្សី ជាងប្រដាប់លេង ជាងប្រាក់ ព្រោះវាឃើញសត្វល្អ ហើយប្លែករាល់ថ្ងៃ) ។

• *ការសំដែងដោយសេរី :– នាំសិស្សច្រើននាក់ហាត់គាន មួយ
ធ្វើអ្នកពោល មួយធ្វើម្តាយ មួយធ្វើឪពុក មួយធ្វើ ស៊ីឌីម មួយធ្វើអ្នកល
មួយធ្វើអ្នកទិញ ។ នាំសិស្សនិយាយរឿង ស៊ីឌីម ហើយនឹង អាទោល
តាំងពីដើមដល់ចប់ ។*

## ៧-៨ — ការងារ (បទកាកគតិ)



មើលនុ៎ះបក្សី ពាំស្មៅ-សំឡី
មកធ្វើសំបុក ដើម្បីទុកពង
ភ្ញាស់កូនបានសុខ ដល់តទៅ
មុខ ផុតក្តីលំបាក ។



ដូចឪពុកម្តាយ រិះខ្វល់ខ្វាយ
ធ្វើការផុតស្រាកយប់ថ្ងៃមិនគិត
ស្ទើរគ្មានសម្រាក ស៊ូទ្រាំពិបាក
ព្រោះបីញ្ចឹមកូន ។



មើលនុ៎ះស្រមោច បបេះបបោច
ពាំនាំសណ្តូន គ្រាប់ស្រូវអង្ករ យកមកគរពូន ពេលក្រខ្សត់ស្បៀ
វាគ្មានព្រួយអ្វី ។ មើលនុ៎ះពីងពាង វាលាតត្រដាង មងប្រក្រតី
រួចសម្ងំចាំ ឃ្លាំចាប់ចំណី មូសក្តីរុយក្តី ធ្វើជាអាហារ ។
កុមារប្រុស-ស្រី អ្នកនៅវ័យខ្ចី ត្រូវខំសិក្សា រិះរកបំណេះ

# ពីគ្រូអាចារ្យ ដើម្បីធ្វើការ កាលណាធាងធំ ។

(ស្រង់សំរួលពីសៀវភៅមើលសម្រាប់អាទិកដ្ឋានទំព័រ ៦២)

បបេះបបោច : កិ. ចាប់ ឬ ខាំនេះបន្តិចនោះបន្តិច មិនកំណត់ ។

គរព្វង : កិ. ធ្វើឲ្យបានជាគំនរ ។

---

- ជញ្ជាំងគិត : មនុស្សក្ដី សត្វក្ដី បើមិនធ្វើការរស់ ឬទេ ? អ្នកមកសាលារៀនធ្វើអ្វី ? ធំឡើងអ្នកចង់ធ្វើអ្វី ? ហេតុអ្វីបានជាអ្នកចង់ធ្វើការនោះ ?
- ការសំដែងដោយសេរី : ឲ្យសិស្សត្រានមេសូត្រ ដោយធ្វើកាយវិការ ព្រមទាំងពោលសំដី ទៅតាមអំពើនៃវគ្គមេសូត្រនីមួយ ៗ ផង ។



កាលនៅតូចមិនព្រមទៅសាលា
រៀន ដល់ធំឡើងមិនចេះអក្សរ
ជនពួកនេះ គេហៅថាអ្វី ?

# ៩ – គ្រួសារ ចៅមឿន

១ – ឪពុកចៅមឿន នៅជិតវត្តទួលតាពូង ក្នុងសង្កាត់លេខ១៥ ក្រុងភ្នំពេញ ។ គាត់ធ្វើជាងឈើ ។ រាងគាត់មាំ សម្បុរទង់ដែង ខ្នងត្រង់ហើយមានដុះពុកចង្ការុយៗផង ។ នៅផ្ទះគេឃើញគាត់ហាំង-ឈូស-ដាប់ឈើធ្វើតុ ទូ កៅអី... ។ គាត់បៀមបារីស្លឹកសង្កែមួយជាប់នៅមាត់ សឹងតែរលត់ជានិច្ច ព្រោះពេលដែលគាត់លើកឈើផ្ទៀង តម្រង់ជ្រុង ឬពេលដែលគាត់ដាប់ឈើ គាត់ភ្លេចបឺតបារី ។



២ – ម្ដាយចៅមឿន ពុំសូវមានសុខភាពគ្រប់គ្រាន់ទេ នៅរដូវត្រជាក់ គាត់ច្រើនផ្ដាសាយ ។ រាល់ថ្ងៃ គាត់បោសសំអាតផ្ទះ បោកគក់សំលៀកបំពាក់គ្រួសារគាត់ ។ ម្ដាយចៅមឿន ធ្វើការច្រើនមុខទៀត ។ អ្នកគិតមើល

តាំងពីបបរព្រឹក រហូតដល់ពេលបាយល្ងាច គាត់រវល់នឹងជើងក្រាន

បាន ឆ្នាំង សឹងរកពេលទំនេរគ្មាន ។

ម្ដាយហៅមឿនថែទាំកូនបានសមរម្យ ចេះណែនាំកូនឲ្យនៅ

លេងជិតៗផ្ទះ ចេះលួងលោមកូនគាត់ប្រើ ដើម្បីឲ្យមានទម្លាប់ចេ

ជួយដៃ-ជើងគាត់បានខ្លះផង ។

ផ្ទៀង : ក. ពិនិត្យមើលឲ្យត្រឹមត្រូវតាមបែបបទ តាមគំរូ តាមច្បាប់ដើម

---

● ជញ្ជឹងគិត : អ្នកយល់ថាឪពុកហៅមឿន ជាជាងយ៉ាងដូចម្ដេច

ឃ្លាត្រង់ណាដែលបញ្ជាក់ថា ឪពុកហៅមឿន គិតតែពីការរបស់គាត់ ?

ម៉ែហៅមឿន ធ្វើអ្វីខ្លះនៅផ្ទះ ? ឃ្លាត្រង់ណាដែលបញ្ជាក់ថាគាត់ជាម្ដាយល្អ

● រៀនពាក្យ : គ្រួសារ

នាម : ជីតា ជីដូន ឪពុក ម្ដាយ កូន បង ប្អូន សុខភាព ។

គុណនាម : ចាស់ ក្មេង ឧស្សាហ៍ ខ្ជិល ។

កិរិយា - ធ្វើការ ថែទាំផ្ទះ លួងលោមប្អូន ។

● ការិយកម្ម : ចូរអ្នកតែងជាឃ្លានឹងពាក្យខាងក្រោមនេះ :

ជីតា ជីដូន ឧស្សាហ៍ ខ្ជិល លួងលោម ។



## ១០ — បងប្អូន ចៅមឿន

១ – ចៅមឿន មានបងប្អូនបីនាក់ បងបង្អស់របស់វា ឈប់រៀនហើយ សព្វថ្ងៃកំពុងហាត់រៀនធ្វើជាងឈើជាមួយឪពុកវា ។ វាចេះរើសឈើ រើសក្តារ មកផ្គុំធ្វើតុ-ទូ ហើយចេះអារប្រៀកឈើតាមគំនូសបន្ទាត់ខ្មៅខ្លះហើយ ។ ថ្ងៃណា ឪពុកជាប់រវល់ វាអូសរទេះកង់ពីរ ដឹកកូនទូតូចៗទៅជូនអ្នកទិញដល់ផ្ទះ ។ មុខងារអូសរទេះដូចសេះនេះ ចៅមឿនគិតចង់ធ្វើណាស់ រហូតដល់ប្រណែននឹងបងវាផង ។

២ – រាល់ព្រឹក ចៅមឿនភ្ញាក់ពីម៉ោង ៦ ដោយសារបងវា

ផាស់ ៗ វាពត់ខ្លួនហើយស្ទាប ពុំទាន់ស្វាងពីងងុយ ៗ ប៉ុន្តែដល់

វាងូតទឹករួច វាស្រឡះមុខធេង ។ ប៉ៅមឿន ទៅញ៉ាំបបរ ។

វាស្លៀកពាក់ លើកសំពៀតស្បែកមកស្ពាយ ហើយនាំប្អូនស្រីវាទៅ

សាលារៀន ។ តាមផ្លូវ ប៉ៅមឿន នាំប្អូនវាដើរលើចិញ្ចើមថ្នល់ដោយ

ប្រយ័ត្ន មិនឲ្យម្តាយឪពុកវា ព្រួយពីគ្រោះថ្នាក់បានឡើយ ៗ

*ស្វាង : គុ. ដែលស្រឡះមុខមាត់ពីងងុយ ៗ*

---

ក ...

● ជញ្ជាំងគិត : *អ្នកយល់ថា បងប៉ៅមឿនបានទៅជាជាងឈើ បំណានមួយឬទេ ? ដោយហេតុអ្វី ? អ្នកដែលហាត់ធ្វើជាង គេហៅថាអ្វី ? ប៉ៅមឿន ធ្វើអ្វីខ្លះដើម្បីជួយសំរាលការគ្រួសារវា ?*

● ការសំដែងដោយសេរី : *– ធ្វើត្រាប់ក្មេងខ្ជិល នៅពេលវាក្រោកពីដំណេក ដោយកាយវិការនិងសំដី ៗ – ចូរអ្នករៀបរាប់តាមលំដាប់ តាំងពីអ្នកភ្ញាក់ពីដេក រហូតទៅដល់សាលារៀន តើអ្នកបានធ្វើអ្វីខ្លះ ?*

● វេយ្យាករណ៍ : *អំពីនាមសព្ទ*

*នាមសព្ទ : គឺសព្ទសំដែងនូវឈ្មោះមនុស្ស សត្វ ទ្រព្យរបស់និងអ្វីៗ ទាំងពួង ពាក្យថា ឪពុក ម្តាយ គោ មាន់ ទា ផ្ទះ តុ ទូ កៅ ... ជានាមសព្ទ ៗ*

● ការិយកម្ម : *ចូរអ្នករកនាមសព្ទ ដែលមាននៅក្នុងអត្ថបទ ។*



## ១១ – ជីតាយើង

១ – ព្រឹកនេះ ចៅមឿន បានទទួលសំបុត្រមួយច្បាប់ពីជីតាវា សំបុត្រនោះមានសេចក្ដីថា: មកដល់កូនចៅទាំងអស់គ្នា,

តានៅផ្ទះមួយធំម្នាក់ឯង ។ រដូវប្រាំងនេះ អាកាសស្អុះស្អាប់ មនុស្សសត្វ ក្ដៅរហែងរហាងណាស់ ។ តាអផ្សុក បង់មកលេងនិងអ្នកគ្រប់គ្នា ។ តានឹកថា មកនៅនឹងចៅរហូតដល់រដូវវស្សា ។

តាទៅដល់ភ្នំពេញ នៅថ្ងៃសុក្រខាងមុខនេះជាកំណត់ ។ តាសង្ឃឹមថាចៅមកទទួលតា នៅស្ថានីយអយស្ម័យយានមិនខាន។

២ – ដំណឹងនេះនាំឲ្យគ្រួសារចៅមឿន បានរីករាយទាំងអស់-គ្នា ។ គេរៀបចំកន្លែងទុកជូនតា រួចគេនាំគ្នាស្លៀកពាក់យ៉ាង

ស្អាតទៅចាំទទួលតានៅបំណោតរទេះភ្លើង ។

៣ – តាមផ្លូវ គេនិយាយតែពីរឿងតា គេថាតាចាស់ណាស់ហើយ មិនគួរទុកគាត់ឲ្យនៅស្រុកស្រែតែម្នាក់ឯងទេ ។ បំណែកចៅមឿនថា : បានតាមកលេងម្តង ។ ផ្ទះយើងអ៊ូអរដូចមានបុណ្យ តាបេះនិយាយរឿងព្រេងពិរោះៗឲ្យយើងស្តាប់ មិនតែប៉ុណ្ណោះ តាបេះបង្រៀនស្រីមុំមបានឆាប់ចេះអានអក្សរទៀតផង ។

កំពុងតែជជែកគ្នាយ៉ាងសប្បាយ ស្រាប់តែគេបានទៅដល់បំណោតរបភ្លើងភ្លាម ។

*របោនរបាជ : គុ. ក្តៅក្រហល់ក្រហាយ រសាប់រសល់ ស្វាក់ស្វើរ ។*

*អន្ទះអន្ទែង : កិ. មិនសប្បាយចិត្ត ធុញទ្រាន់នៅមិនសុខ ។*

---

- *ជញ្ជាំងគំនិត : តានិយាយអ្នកនៅឯណា ? គាត់ដែលមកលេងផ្ទះអ្នកឬទេ ? ពេលគាត់មកលេងម្តង ៗ អ្នកបានទទួលគាត់យ៉ាងណាខ្លះ ?*
- *វេយ្យាករណ៍ : អំពីគុណនាម*

*គុណនាម : គឺនាមសព្ទដែលប្រាប់ដំណើរនាម ឲ្យឃើញលក្ខណៈផ្សេង ៗ គ្នា ដូចពាក្យថា ខ្មៅ ស តូច ធំ វែង ខ្លី ខ្ពស់ ទាប រៀប ត្រង់ . . . ។*

*ចូរអ្នកធ្វើឃ្លាឲ្យមានពាក្យគុណនាមមួយ ឬ ពីរ នៅក្នុងនោះ ។*

## ១២ – យើងទៅទន្លេតា

១ – នៅស្ថានីយរាជអយស្ម័យយាន មានមនុស្សប្រុស-ស្រី មីរដើរដាស រង់ចាំទទួលញាតិ មិត្តរបស់គេ ដូចគ្រួសារចៅមឿនដែរ ។ មានយានជំនិះដឹកនាំមនុស្ស នឹងទំនិញចេញ ចូលឥតស្ញែ។ នៅទីនេះ ចៅមឿនឈរមិនស្ងៀមទេ ជួនវាដើរចុះ ដើរឡើង រកមើលរទេះភ្លើង ជួនវាក្រឡេកមើលនាឡិកា ។

២ – មិនយូរប៉ុន្មាន សំឡេងធ្វេកមួយ បានបន្លឺយ៉ាងវែងគ្រលួប ។ ភ្នាក់ងារធ្វើការប្រចាំចំណាតរថភ្លើង ស្រែកថាៈ ប្រយ័ត្ន! រទេះភ្លើងមកដល់ហើយ ។ សូរឃឹកៗលេចឮរំពងខ្លាំងឡើងៗ ។ នៅលើក្បាលរទេះភ្លើង ផ្សែងខ្មៅខ្មួលបាញ់អង្កាញ់ទៅលើ ហើយ



រសាត់ទៅបាត់នៅខាងក្រោយ ។ រទេះភ្លើងបង្អង់ល្បឿនបន្តិចម្តងៗ ហើយឈប់នៅស្ទៀម ។

៣ – តាបុះពីរទេះភ្លើង ទំកមុខញញឹមមករកចៅ ។ ស្រីម៉ុមនិងចៅមឿន រត់ទៅឱបតាបានមុនគេ ។ ម្តាយចៅមឿនទៅទទួលហិប និងកញ្ចប់មួយយ៉ាងបំប្លែកពីដៃតា ។ ចៅមឿននិងស្រីម៉ុមចំសំឡឹងកញ្ចប់នេះ ស្ទើរមិនដាក់ភ្នែក ។ ទាំងអស់គ្នាម្នីម្នាឡើងជិះរថយន្តឈ្នួលតូចមួយ ត្រឡប់មកផ្ទះវិញ ។

*ស្ថានីយអយស្ម័យយាន ន. ទីកន្លែងដែលរថភ្លើងចតឬឈប់នៅៗ*

*ម្នីម្នា : កិ. វិ. រវៀសរវៃ ប្រញាប់ប្រញាល់ រសាប់ ។*

---

• *ជញ្ជឹងគិត : នៅចំណតរទេះភ្លើងមានអ្វីខ្លះ? ហេតុម្តេចបានជាចៅមឿន នៅមិនស្ងៀម ? ឃ្លាត្រង់ណាបង្ហាញថា ចៅស្រឡាញ់តា? អ្នកហ៊ានទាយថា កញ្ចប់យ៉ាងបំប្លែកនោះមានអ្វីខ្លះឬទេ ? ពីព្រោះអ្វី ? អ្នកស្រឡាញ់តា និងយាយអ្នកដែរឬ ? ហេតុអ្វី ?*

• *ការសំដែងដោយសេរី : សិស្ស៤ ឬ ៦នាក់ឱបចង្កេះគ្នាតៗដោយដៃម្ខាង ដៃម្ខាងទៀតធ្វើកង់រថភ្លើង ត្រាប់រទេះភ្លើងដែលមកដល់ចំណតនឹងកំពុងចេញដំណើរ ។ ធ្វើកាយវិការឲ្យព្រម ១ គ្នា មានពុស្សូរផ្សេង ១ ថែមទៀត ។*



## ១៣-១៤ — ចៅមឿនសុខចិត្តខានញ៉ាំបន្ថែម

១ - ល្ងាចនេះ ម្ដាយចៅមឿនបានចែកផ្លែក្រូច ឲ្យគ្រួសារគាត់ម្នាក់មួយ ៗ គាត់ជូនទៅឪពុកចៅមឿនពិសាមុនគេ រួចបានចែកបងប្អូនចៅមឿនជាបន្តបន្ទាប់គ្នា ។ ដល់វេនចៅមឿន ក្រូចនៅសល់តែមួយ ។ ចៅមឿនដឹងថាក្រូចខ្វះ ព្រោះមេចំណែកមិនទាន់បាននៅឡើយ ក៏ខំសង្កត់ចិត្ត ទប់សំឡេងនិយាយទៅកាន់ម្ដាយថា

- សូមម៉ែទុកពិសាចុះ ។

ម្ដាយចៅមឿនឈរទ្រឹង មុខឡើងស្លុត រួចសួរទៅចៅមឿនវិញថា

- ឯងញ៉ាំបាយឆ្អែតពេកឬ?

– បាទ! មិនផ្អែតណាស់ណាទេ ។

២ – ម្ដាយចៅមឿនកាត់ក្រូចជាប្រាំចំណិត ។ គាត់យកមួយបំណិតមកពិសា ហើយហុចក្រូចបួនចំណិត ទៅឲ្យចៅមឿនម្ដងទៀត ដោយនិយាយបន្ទប់ថា:

– ក្រូចនេះផ្អែមណាស់ ញុំាលាងមាត់ទៅកូន ។

– ទេម៉ែ! ខ្ញុំមិនញុំាទេ ។ សូមម៉ែពិសាតែម៉ែទៅ ។

៣ – ប្អូនចៅមឿនជាក្មេងឃ្លានពុំសូវស្រាក បានឈរស្ដាប់រឿងនេះ យូរបន្តិចមកហើយ ។ វាហេលកន្ទុយភ្នែកទៅរកចំណិតក្រូច ហើយប្រាប់ចៅមឿនថា:

– បើបងមិនញុំាទេ ឲ្យខ្ញុំញុំាមក ។

៤ – ចៅមឿនហុចផ្លែក្រូចទៅប្អូនទាំងស្ដាយ ដែវាបែបញ៉រ ។ ម្ដាយចៅមឿនយល់គំនិតកូន រំជួលក្នុងចិត្តយ៉ាងខ្លាំង ។ គាត់នឹកថា ចៅមឿនកូនអញចិត្តល្អមែន វាសុខចិត្តអត់ខ្លួនឯងដូបអញ ឲ្យតែបងប្អូនវាបានញុំាច្រើន ។

វេន : ន. ការកំណត់តាមលំដាប់ ឬ ដំណើរផ្លាស់ប្ដូរគ្នា ។

ច្រឹង : គុ. ដែលមិនទាន់យល់ច្បាស់ថា ដូចម្ដេចនៅឡើយ ។

ញុំ : កិ. ស៊ី " ជាពាក្យទំយើ និយាយបានតែក្បួនក្មេង ,, ។

លាងមាត់ : កិ. ញុំបន្ថែមក្រោយបាយ « មិនមែនលាងមាត់ឲ្យជ្រះមាត់ទេ ។

រំជួលក្នុងចិត្ត : ន. ដំណើរដែលរំភើបក្នុងចិត្ត ។

និយាយបន្ទប់ : កិ. និយាយបំភាន់សំដី ។

---

• ជញ្ជីងគិត : ហេតុអ្វីបានជា ចៅមៀង មិនទទួលក្របពីម្ដាយ ? ដោយពិត ចៅមៀង ឃ្វាលក្របឬទេ? ការប្រែកែបែបនេះ ជាការងាយឬពិបាក? ពីព្រោះអ្វី? ប្អូនចៅមៀង មិនដឹងសុខ ទុក្ខ ចៅមៀងទេ ឃ្វាគ្រង់ណាដែលបញ្ជាក់ថាយ៉ាងនេះ? ចៅមៀងចិត្តល្អចំពោះគ្រួសារ តើមានឃ្វាគ្រង់ណាដែលបញ្ជាក់ថាយ៉ាងនេះ?

• ការសំដែងដោយសេរី : ប្អូនអ្នកនិទានរឿង ចៅមៀង ដោយមើលតែគំនូរ មិនបាច់មើលអក្សរ ហើយនិយាយលើកដាក់សំឡេងឲ្យដូចជាម្ដាយ នឹង ចៅមៀង និយាយគ្នាមែនៗ មកមើល ។

• វេយ្យាករណ៍ : អំពីស្រៈ

ស្រៈ មានពីរយ៉ាង :

– ស្រៈពេញតួ : ឥ ឦ ឧ ឩ ឯ ឰ ឪ ឫ ឬ ឭ ឮ អ អា អិ អី អឹ អឺ ។ល។ អុំ អំ អាំ អះ ។ ស្រៈផ្សំត្រូវសរសេរគំនូសដូចនេះ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ុះ េះ ោះ ។



## ១៥ — នាងម៉ុម និងមេឆ្មា

១– ជិតមួយអាទិត្យហើយ នាងម៉ុមសង្កេតឃើញ មីត្រសក់ មេឆ្មារបស់នាង នៅផ្ទះតិចពេលណាស់ ។ មួយថ្ងៃៗមេឆ្មានេះចូលទៅជើងក្រានបី-បួនដង ដើបក្បាលយំប្រាស់ប្រាល់ទារចំណីៗ ភិស៊ីយ៉ាងញាប់ ហើយរត់បាត់ភ្លាមទៅ ។

២– ថ្ងៃមួយ នាងម៉ុមដេញតាម មីត្រសក់ បំរុងនឹងចាប់ ។ មេឆ្មាដឹងខ្លួន បានលោតយ៉ាងលឿនផុតពីដៃនាង រួចគេចចូលប្រហោងជញ្ជាំងរោងឈើ បាត់ភ្លាមបំផុតស្រមោល ។

នាងម៉ុមបើកទ្វាររោង ឃើញមេឆ្មាកំពុងកន្ត្រោងឡើងជណ្តើរ នាងក៏ឡើងតាមឆ្មាទៅ ។

៣– នៅក្នុងរោងឈើ សំឡេងឆ្មាតូច-ធំ យំឆ្លើយឆ្លងគ្នាមិនដាច់ ។ នាងនឹកឆ្ងល់ថា: ចុះសំឡេងមកពីណាក៏ច្រើនម្ល៉េះ? នាងដើរទៅជិតសំឡេងនោះ ឃើញមីត្រសក់បំពោងខ្លួន បើកភ្នែក

មូលក្រឡង់សំឡក់មករកនាង ។ នៅក្រោមពោះ មានកូនឆ្មាពីរកំពុងបៅដោះវា ។ កូនមួយសំបុរត្រសក់ កូនមួយទៀតសំបុរខ្មៅប្រផេះហើយមានឆ្នូតសនៅពោះ ។

នាងម៉ុមផ្ទាក់មាត់ថា : ប៉ុះកូនសត្វឆ្មានេះ អ្វីក៏ល្អបំប្លែកម្ល៉េះ !

លោត : កិ. បោលផ្លោះដោយជើងទាំងបួនពេញទំហឹង ។

កន្ត្រោង : កិ. លោតចាប់ - លោតខាំ ឬ លោតបេះ ។

---

ក...

● ផ្ចាំផ្ចិត : រឿងអ្វីបានជានាងម៉ុមតាមចាប់ឆ្មា ? មេឆ្មាចង់គេចពីនាង ឬ ទេ ? វាធ្វើដូចម្ដេច ? នៅក្នុងពេងឈើ នាងម៉ុមឮអ្វី ? ឃើញអ្វីខ្លះ ? អ្នកដឹង ឬ ទេ ហេតុអ្វីបានជាមេឆ្មាបើកភ្នែកមូលក្រឡង់មករកនាង ?

● ការិយកម្ម : អ្នកដែលបានឃើញអ្វីល្អប្លែក ដូចនាងម៉ុមឃើញកូនឆ្មាពីរនេះដែរ ប្អូននិយាយបន្តិចហើយបញ្ចប់ដោយឃ្លាថា « ប៉ុះកូនសត្វពីរនេះក៏ល្អបំប្លែកម្ល៉េះ » ។

● វេយ្យាករណ៍ : អំពីកិរិយាសព្ទ ។ កិរិយាសព្ទ : គឺសំដីសំដែងកិរិយា ប្រាប់អំពើ លំនាំ ឬ សំដែងហេតុឲ្យសម្រេចកិច្ចនោះ ។ ដូចពាក្យថា ដេក, ដើរ, ឈរ, អង្គុយ, ទៅ មក, និយាយ, ឃើញ, ឮ, ស្ដាប់, ជាដើម ។

– ប្អូនរកកិរិយាសព្ទ ដែលមាននៅក្នុងអត្ថបទខាងលើ ។

# ១៦ – មេឆ្មា និង កូន

១ – នាងម៉ុមលូកដៃអង្អែលកូនឆ្មា ខ្នងវាក្តៅឧណ្ហៗ ។ នាង
រំភើបចិត្ត នឹកអាណិតដល់កូនសត្វតូចៗនេះណាស់ ទើបនាងថា

– មីត្រសក់! ឯងដូចជាម្តាយមែនទែនតែម្តង ។ មើល! ឯង
ឲ្យអញបីកូនឯងបន្តិចផងបានទេ ។

ថាតែប៉ុណ្ណោះ នាងលូកដៃចាប់កូនឆ្មាមួយ មកបីផ្អិបនឹង
ថ្ពាល់ យ៉ាងបន្តើរ ។ កូនឆ្មាភ័យខ្លាំង ខំប្រវេប្រវាបញ្ចេញក្រចក
ខ្វាបបាតដៃនាងស្រាលៗ ។ នាងម៉ុមលាន់មាត់ថា:

– កុំភ័យអាទូច! បងមិនធ្វើអ្វីអាក្រក់ដល់ឯងទេ ។

២ – មេឆ្មាយំមៀវៗមើលមុខនាង ដំបូងដូចជាមិនថាអ្វី ។
ប៉ុន្តែបន្តិចមក ទឹកមុខវា បែរប្រែជាទុក្ខព្រួយ ។ នាងម៉ុមញញឹម



ហើយហុចកូនឆ្មាទៅមេវាវិញភ្លាម រួចថាៈ អីក៏ចិត្តអាក្រក់ម្ល៉េះ មី
តសក់ គ្នាគ្រាន់តែសុំបីកូនឯងបន្តិចក៏មិនបានដែរ ។

៣– នាងម៉ុមដាក់កូនឆ្មា មិនទាន់ដល់កន្លែងវាស្រួលបួលផង
សាប់តែមេវាលៀនអណ្ដាតគគ្រាត មកលិទ្ធកូនជុំវិញខ្លួន ។

នាងម៉ុមនឹកក្នុងចិត្តថាៈ តាំងពីនាងកើតមក នាងមិនដែល
ប្រទះឃើញអ្វីចំឡែកយ៉ាងនេះទេ ។

*ឧណ្ហា ១ : (អ.ថ.=អ៊ុន ១) គុ. ដែលក្ដៅបន្តិច ៗ ។ រំភើប.កិ. រំជួល
ចិត្ត - ចំប្រប់ចិត្ត ។ បង្ខើរ : កិ. វិ. សើរ ៗ ស្រាល ៗ ថ្នម ៗ ។*

---

• *ជញ្ជាំងគិត : នាង ម៉ុម ធ្វើអ្វីខ្លះ កាលបើឃើញកូនឆ្មាល្អយ៉ាង
នេះ ? ហេតុម្ដេចបានជានាងថា កាទូចកុំភ័យ ? មេឆ្មាទុកចិត្តនាង ម៉ុម ថា
មិនធ្វើបាបកូនវាឬទេ ? ហេតុដូចម្ដេចបានជាអ្នកដឹង ? នាង ម៉ុម នឹកឃើញ
យ៉ាងណា បានជានាងញញឹម ? ចុងក្រោយនាង ម៉ុម នឹកក្នុងចិត្តថាដូចម្ដេច ។*

• *ការិយកម្ម :– ចូរអ្នកពិនិត្យមើលរូបគំនូរខាងលើ : នាង ម៉ុម
ពាបដេកធ្វើអ្វី ? មេឆ្មានឹងកូនកំពុងធ្វើអ្វី ? នាង ម៉ុម នឹករំភើបក្នុងចិត្តយ៉ាង
ណា ចំពោះកូនសត្វតូច ១ នេះ ។ – ចូរអ្នករកនាម - គុណនាម និងកិរិយា
សព្ទ ដែលមាននៅក្នុងអត្ថបទខាងលើ ឲ្យបានម្នាក់មួយ ហើយធ្វើជាឃ្លាដោយ
ភ្ជាប់ថា នេះនាម នេះគុណនាម នេះកិរិយាសព្ទ ។*



## ១៧-១៨ — បំណងខ្ញុំ (បទពាក្យ ៧)

– ខ្ញុំនឹកមមៃ ចង់បានផ្ទះ មួយតូចស្រឡះ នៅជើងភ្នំ
សង់ប្របមាត់ស្ទឹង និងឈើធំ បែកមែកត្រសុំ មូបសាខា ។
– នៅជិតជុំផ្ទះ ខ្ញុំនឹងដាំ អស់ទាំងដំណាំ ធ្វើសួនបុប្ផា
ខ្ញុំព្រោះបណ្ដុះ ឈើផ្លែផ្កា ទុកធ្វើអាហារ រៀងរាល់ថ្ងៃ ។
– រួចខ្ញុំចិញ្ចឹម ឆ្កែសេះគោ មាន់ទាមាន់ទោ យកកម្រៃ
ថែទាំឲ្យធាត់ លក់យកថ្លៃ កែខ្វះបន្ត រៀងរាល់ឆ្នាំ ។
– ផ្ទះមួយលំអ ដោយឈើព្រៃ ដោយដីមានជី ដុះដំណាំ
ដោយសត្វចិញ្ចឹម មានផ្លែចាំ ទាំងអស់នេះនាំ ខ្ញុំសប្បាយ ។

– បើបានសម្រេចផ្តិតបំណង នេះម្តងខ្ញុំលើសជិនទាំងឡាយ ខ្ញុំបានសុខចិត្ត សុខទាំងកាយ លែងគិតខ្វល់ខ្វាយអ្វីទៀតហើយ ។

ខ្វល់ខ្វាយ : គិ. ខ្វះខ្វែង ខ្វល់ខ្វាយរកស៊ី ខ្វល់ខ្វាយក្នុងការងារ ។

---

● សព្ទសាស្ត្រ : ស្រះ ា ហើយនឹងស្រះ ៀ : តា-ទៀត ពន រៀន ។ មាន-តា-ដើរបែកគ្នារកស៊ីរៀង ៗ ខ្លួន ។

● ហាត់អាន : ឲ្យសិស្សហាត់អានបទពាក្យ ៧ ជាពាក្យឲ្យច្បាស់ហើយ ធ្វើបទឲ្យបានពិរោះផង ។ ដំបូងធ្វើម្នាក់ម្តង បន្ទាប់មក ពីរ-បី-បួន នាក់ . . . ជាមួយគ្នា ។

● ជញ្ជាំងគិត : ឥឡូវនេះ អ្នកមានបំណងចង់ធ្វើអ្វី ឬទេ ? ផ្ទះ ដែលអ្នកប្រាថ្នាចង់បានទៅថ្ងៃក្រោយមានរូបរាងដូចម្តេច ? អ្នកគិតបង្កើត របស់អ្វីនៅផ្ទះនោះ ? ផ្ទះនៅជើងភ្នំ មានអ្វីផ្តល់សុខភាពដល់អ្នកនៅ ? ( ខ្យល់បរិសុទ្ធហើយស្រាល ) ។

● ការិយកម្ម : – ចូរអ្នកគូររូបរាងផ្ទះ សណ្ឋានភាពដីភូមិព្រមទាំង ធម្មជាតិទាំងឡាយ នៅជុំវិញផ្ទះ ដែលអ្នកប្រាថ្នាចង់បាន ។

# ១៩ – ចៅមឿនចង់ទៅឃ្វាលគោ



១–នៅស្រុកស្រែ ចៅមឿ
ឃើញតែការឃ្វាលគោមួយ
ទេ ដែលសំខាន់ជាងគេ
ចៅមឿន នឹកមមៃចង់ស
តាវា ទៅតាមអ្នកឃ្វាលគោ
ម្នាក់ឈ្មោះ ជួប ។

ជួប អាយុ ១៤ ឆ្នាំ ជាក្មេ
នៅជិតខាងគ្នា ។ វាដឹងខុសត្រូវច្រើន ម្ល៉ោះហើយ តាចៅមឿ
ក៏ព្រមទៅនិយាយនឹងជួប :

– ជួប! ចៅមឿន ចង់តាមឯងទៅឃ្វាលគោ តើឯងព្រមឲ្យវ
ទៅជាមួយផង ឬទេ ?

– មានអ្វីតា! ចាំស្អែក ដល់ពេលខ្ញុំមកហៅវា ។

ចៅមឿនឮដូច្នេះ សប្បាយចិត្តណាស់ ។

២ – ស្អែកឡើង ចៅមឿន ស្លៀកពាក់ខោ-អាវហាស់

ប ដើររកម្ហូបក្អេលនឹងបំពង់ទឹក ។ តាភារើបបាយមួយសំណុំធំ
ានដាក់ពងទាប្រៃ ត្រីអាំងហើយនឹងជ្រក់ទំពាំង ។ គាត់បង
បំណុំបាយបណ្ដើរ និយាយបណ្ដើរថា នៅព្រៃ គេស៊ីបានច្រើន
ណាស់ ។ ថាហើយ គាត់បន្ថែមនំពីរឲ្យ ចៅមឿន ទៀត ។

ចៅមឿន ឈរចាំ ជួប នៅមុខផ្ទះ ។ បន្តិច ជួប មកដល់ ។
ចៅមឿន លាជីតាហើយដើររតាម ជួប ទៅឃ្វាលគោ ។

— មមៃ : ក. រ. ដែលក្អកនឹករឿយ ៗ មិនដាច់ ។

ក...

● ជញ្ជឹងគិត : បំណង់ធំរបស់ចៅមឿនគឺអ្វី ? វាបានសម្រេច
ាមបំណងវា ឬទេ? តើវាយកអ្វីខ្លះ ដើម្បីទៅឃ្វាលគោ ? បើគ្មានរបស់ទាំងនេះ
តីអ្នកឃ្វាលគោយើងអាចនៅព្រៃបានពេញមួយថ្ងៃ ឬទេ ?



ត្រចៀកកាំចូលចិត្តខ្យល់
អាកាសត្រជាក់ស្រួល ។
វាមករកស៊ីនៅស្រុកអ្នក
តាមរដូវ ។ តើវាធ្វើសម្បុក
ពងនៅឯណា ?



## ២០-២១ - ជួបនឹងចៅមៀនទៅឃ្វាលគោ

១ - ជួប ហ្វូតរនុក បើកក្រោល ។ គោឈ្មោលធំពីរចេញ
មកមុនគេ បោះជំហានមួយៗដើរបានបន្តិចឈប់ ងើបក្បាលរោ
រកគ្នា ។ ពីខាងក្រោយ មានមេគោ ៤-៥ ពោះកំប៉ោង ដើរបណ្ដើ
ឈ្មោករកស៊ីស្មៅបណ្ដើរ ។ ចុងក្រោយបង្អស់ កូនគោចេញម
រត់ផ្លេផ្លាបោលកញ្ឆោងត្រកងកន្ទុយ សម្រូលសរសៃជើងវា ។

ម៉! ម៉! គោឈ្មោល-ញី ស្រែករំពងនៅវាលខាងមុខក្រោល

២ - ហ្វូងគោដើរឈូសដី បែកធូលីហុយសំពោង មើលទៅ
បីដូចមេឃបុះអាប់ ។ មេគោកញ្ចាស់មួយពាក់ស្នែងម្ខាង ដើ
ក្បាលស្មើន បញ្ចោញត្រដោកនៅក នាំមុខហ្វូងគោទៅព្រៃលើ

៣ – ក្នុងពេលធ្វើដំណើរនេះ ប៉ាមឿនលែងនៅជិតជួបហើយ វារត់ម្ដងទៅខាងនេះ ម្ដងទៅខាងនោះ ដើម្បីកៀងគោ ។ មួយសន្ទុះធំ ក្មេងនិងសត្វបានដល់វាលមួយ នៅក្បែរព្រៃ ។ គោទាំងអស់ស្គាល់កន្លែង ដើរបែកគ្នា រកស្លឹកឈើនិងស្មៅស៊ី បក់កន្ទុយរវិច ៗ ដេញសត្វរុយនិងសត្វរបោម ។

៤ – មឿន រត់ក្រឡឹងហ្វូងគោពីរ-បីជុំ ហើយគួសដីប្រាប់គោកុំឲ្យចេញពីទីវាល ។ ក្រោយមក វារត់ឡើងលើដំបូក ភ្នែកបែរមើលគោបះឡើង ជាកិច្ចបង្ហាញជួបថា វាឃ្វាលគោតែឯងក៏បានដែរ ។

នៅវាលស្មៅនេះ ជួបនឹងប៉ាមឿន បបួលគ្នាលេងល្បែងផ្សេង ៗ រហូតដល់ពេលត្រឡប់មកផ្ទះវិញ ។

*សំពោង : គុ.វិ. ដែលបែកផង់ចូលព្រោងព្រាត ។*

*ស្រូង : គុ.វិ. អើតងើបងើយស្ទើតឡើង ។*

---

● *ផ្ញើជគិត : អ្នកដែលបញ្ចេញគោពីក្រោលដែរ តើគោធ្វើដូចម្ដេចខ្លះនៅពេលនោះ ? គោឈ្លោលរាក់យ៉ាងណា ? ចូរអ្នកធ្វើត្រាប់គោញីយំ ។ អ្នកដឹងឬទេ ហេតុម្ដេចបានជាមេគោកញ្ចាស់ងើបស្ទើ បញ្ចេញត្រដោក ? (វាត្រអឹតព្រអោងព្រោះវាជាមេហ្វូង) ។ មឿន ចង់បង្ហាញជួបថា វាយ៉ាងណាក្នុងពេលឃ្វាលគោនេះ ។*

# ២២-២៣ - ដើមផ្កា និងដើមឈើស៊ីផ្លែ

១-ចៅកែវ ហើយនឹងចៅជា ជជែកគ្នាអំពីប្រយោជន៍នៃដើមឈើទាំងឡាយ ។ ចៅកែវស្រឡាញ់ដើមផ្កា ចៅជាចូលចិត្តឈើស៊ីផ្លែ ។ ចៅកែវនិយាយទៅចៅជាថា :

-ឈើទាំងអស់មិនសូវមានប្រយោជន៍ដូចដើមផ្កាទេ ។

ចៅជាឆ្លើយថា :



-ដូចម្តេចបានជាឯងថា គ្មានប្រយោជន៍ មើល! ដើមវាសម្រាប់ធ្វើឧស មួយវាសម្រាប់ជ្រក ផ្លែវាសម្រាប់ស៊ី តើឯងថា គ្មានប្រយោជន៍ម្តេចកើត ?

២-ការជជែកគ្នានេះ កើតមកពីម្នាក់ៗ ចង់និយាយតម្រូវតាមដំណាំដែលខ្លួនមាន ។

ចៅជា មានចំការដំណាំមួយនៅក្រោយផ្ទះ ។ ក្នុងចំការនោះមានដាំដើមបេក ល្ហុង ម្នាស់ និងដូង ។ បេកផ្លែថ្លោសទាំងស្លុងៗ

ល្មុងមានផ្លែធំ ៗ ទុំក្រហម សាច់ផ្អែមដូចស្ករ ។ ម្នាស់ផ្លែទុំពណ៌លឿង សាច់ជូរអែម គេចូលចិត្តអាស្រ័យគ្រប់គ្នា ។ ដើមដូងផ្លែធំទាំងធ្លាយ ៗ ទឹកផ្អែមត្រជាក់ សាច់ក្រាស់មានខ្លិះ ប្រើការបានច្រើនយ៉ាង ។ ឪពុកចៅជា បានប្រាក់ច្រើនដោយលក់ផ្លែឈើ ទាំងអស់នោះ ។

៣ - បំណែកចៅកែវវិញ វាមានសួនផ្កាមួយនៅមុខផ្ទះដែរ ។ នៅក្នុងសួននោះមានដើមបំប៉ា កុលាប ម្លិះលា ម្លិះរួត រំយោល បាន់ធូ... ដាំបំរុះគ្នា វាមានផ្កាស ក្រហម-លឿង យ៉ាងស្រស់ ។ ផ្កាខ្លះទើបតែងប៉ុប ខ្លះនោប ខ្លះរីក សាយក្លិនធុំភាយពេញទាំងសួន នាំឲ្យរីករាយដល់អ្នកដាំ ហើយនឹងអ្នកមកមើលយ៉ាងក្រៃលែង ។

យើងត្រូវដាំដើមឈើស៊ីផ្លែផង ដាំផ្កាលំអផ្ទះយើងផង ។

ការពន្យល់ : ន. ឲ្យត្រូវនៅលើអ្វីមួយដែលខ្លួនមាន ឬ ចង់ ។

នោប : ផ្កាដែលនៅក្រពុំ ផ្កានោប ។

---

● ដញ្ញាដំតិត : ចៅ កែវ ស្រឡាញ់អ្វី ? ចៅ ជា ស្រឡាញ់អ្វី ? ដោយហេតុអ្វីបានជាវាដដែកគ្នាមិនព្រមយល់ប្រយោជន៍ឈើ ទាំងពីរបែបនេះ ? អ្នកយល់តាមចៅកែវ ឬ ចៅ ជា ឬ យល់យ៉ាងណាទៅវិញ ?

● តែងសេចក្ដី : អ្នកមានសួនបន្លែមួយ ចូរអ្នកនិយាយរៀបរាប់អំពីសួនបន្លែនោះ ។

# ២៤ – ទាហានល្បាតរបស់អ្នកចំការ





១ – នៅចំការ អ្នកបានភ្ជួររាស់ កាប់គាស់ដី ។ អ្នកបានសាបព្រោះ បានដាំដំណាំ អ្នកបានស្រោចទឹក បោចស្មៅ ដាក់ជីដំណាំរាល់ថ្ងៃ ។ ការនឿយហត់នេះ នឹងទៅជាឥតផល បើអ្នកគ្មានទាហានល្បាត ជួយការពារដំណាំអ្នក ឲ្យបានជិតដល់ផងទេ ។







២ – សត្វល្អិតបង្រៃមានច្រើនណាស់ ខ្លះនៅក្នុងដីចាំស៊ីមើមនឹងឫស ខ្លះនៅនឹងដើមចាំស៊ីស្លឹកនឹងត្រួយ ខ្លះនៅលើអាកាស ចាំទិបផ្កា ឬ ក្តិបឲ្យក្រិន ។

៣ – ដំណាំអ្នកដុះបានល្អ ដោយសារពេលថ្ងៃ អ្នកមានសត្វត្រចៀកកាំ ពេលយប់ អ្នកមានសត្វប្រចៀវហើរឃ្លាំលើចំការ ។ នៅតាមរបងចំការ សត្វបង្កួយចាំយាម ។ នៅក្នុងចំការ សត្វគីង្គក់ដើរល្បាត ហើយនៅលើដើមឈើ សត្វចាបចាំស៊ីដង្កូវ ។

៤- ទាហានល្បាតជើងគោក និងជើងអាកាសនេះ ធ្វើការទៀងពេលណាស់ ហើយបេះបំពេញមុខការរៀងខ្លួនឥតខ្ចោះផង ។

ក្នុងការធ្វើសួនច្បារ ធ្វើចំការនិងធ្វើស្រែ បើយើងគ្មានសត្វទាំងអស់នេះជាជំនួយទេ នោះផលដំណាំយើងក៏គ្មានចំរើនដែរ ។ យើងត្រូវថែរក្សាពូជសត្វ ដែលជួយការពារដំណាំយើង ឲ្យកាន់តែកើនច្រើនឡើង ។

ទាហានល្បាត : ទាហានដែលត្រូវល្បាតមើល ។

---

● ជញ្ជឹងគិត : ព្រោះអ្វីបានជាគេទុកសត្វប្រចៀវ ត្រចៀកកាំ គីង្គក់ ចាប ចង្គួយ . . . ជាទាហានល្បាតរបស់អ្នកចំការ ? ដូចម្ដេចហៅថាទាហានល្បាត ? ពេលណាអ្នកឃើញគីង្គក់លោតរកចាប់សត្វល្អិត ? ចូរអ្នករាប់សត្វល្អិតដែលបំផ្លាញដំណាំ រាប់សត្វដែលស៊ីសត្វល្អិតខ្លះទៀត ។

● វេយ្យាករណ៍ : យាមមាន ៥ គឺ : យាម : ន. ប្រដាប់របស់នង្គ័លដែលភ្ជាប់ផ្ទៀងនឹងដង សម្រាប់កាន់ភ្ជួរ ។ យាម : ន. « សំ-ម » វេលាដែលបែងជាសង្កាត់ៗ ក្នុងមួយថ្ងៃ ១ បើគិតជាម៉ោង ក្នុងមួយយាមមាន ៣ ឬ ៤ម៉ោង យាមទី ១ យាមទី ២ ...។ យាម : ន. " ស-យ៉ាម „ ( អ-ថ = យាម ) ថង់សំពត់មានដៃ ឬ យោគស្ពាយបាត្រ ។ យាម : ន.« ម-យាម " ឈ្មោះកាមាវ-ចរសួគ៌ ជាន់ទី ៣ ឋានយាម ។ យាម : កិ. យាមឃ្លាំង យាមផ្លូវ យាមគុក ។

# ២៥ — ស្រែប្រាំង

ផុតស្រូវរដូវវស្សា អ្នកស្រែដែលនៅជិតបឹងហើយនឹងទំនប់ទឹក ចាប់សាបស្ទូងស្រូវស្រាល នៅរដូវប្រាំងទៀត ។

កាលណាសំណាបដុះបានម្ភៃសង់ទីម៉ែត្រ ដោយប្រមាណ ហើយ កសិករក្មេង-ចាស់បណ្ដើរគ្នាជាក្រុម ដៃកាន់បំណងកក់ ឬ ស្បូវ ដើរតម្រង់ទៅថ្នាលសំណាបដ៏មានពណ៌ខៀវស្រងាត់ ។ នៅថ្នាល អ្នកខ្លះបង់ក្បិន ខ្លះលាត់ជើងខោពាក់កណ្ដាលភ្លៅ ដកសំណាប ៗ យូរៗ គេបោកដីនៅឫសសំណាបដាក់គ្នាម្ដងៗ ហើយហោកៈព្រៀវយ៉ាងសប្បាយ ។ គេចងសំណាបជាកណ្ដាប់រួចរែកជញ្ជូនទៅស្រែ ដែលទើបនឹងភ្ជួររាស់ហើយថ្មីៗ ។ គេដាក់សំណាប



ឯណោះខ្លះ ឯណោះខ្លះក្នុងផ្ទៃស្រែនោះ ហើយគេនាំគ្នាស្ទូងតាមមុខ រៀងខ្លួន ដើម្បីឆាប់បានពេញស្រែ ។

ការធ្វើស្រែប្រាំង លំបាកជាងការធ្វើស្រែនៅរដូវវស្សា ច្រើនណាស់ ព្រោះអ្នកស្រែត្រូវបាចទឹកបញ្ចូលស្រែ ដោយស្នាបឬថ្លឹង រាល់ថ្ងៃ រហូតដល់បីខែទើបស្រូវទុំ ។

ស្រូវស្រាល : ន. ស្រូវដែលឆាប់ចេញផ្កា ផ្លែ ។

---

● ពន្យល់គំនិត : អ្នកដឹងឬទេ នៅដំបន់ណាខ្លះដែលមានធ្វើស្រែប្រាំង ? គេធ្វើស្រែប្រាំងដោយសារមានអ្វី ? ( ទំនប់ទឹក ) ។ ទំនប់ទឹកមាននៅឯណាខ្លះ ? អ្នកណាដែលដឹកនាំឲ្យបង្កើតទំនប់ទឹកលំពូក ពលសោះខ្យល់ ឈូកស . . . ។ គេយកស្រូវធ្ងន់ ឬស្រូវស្រាលទៅធ្វើស្រែប្រាំង ? ពីព្រោះអ្វី?

● វេវចនាត្ថ : ការធ្វើស្រែ នាម : កសិករ ស្រែ សំណាប សន្ទូង ស្រូវ នង្គ័ល រនាស់ បបកាប់ គោ ។ គុណនាម : ស្រាល ធ្ងន់ ឆាត ខ្ជាំង ខ្ជៀយ ។ កិរិយាសព្ទ : ធ្វើស្រែ ស្ទាប ព្រោះ ស្ទូង ច្រូត បោក បែន បញ្ចីមគោ បាចទឹក ។

● ការិយកម្ម : ចូរអ្នកឆ្លើយនឹងសំនួរខាងក្រោមនេះ :

កសិករចាប់ធ្វើស្រែប្រាំងពីខែណា ទៅខែណា ? គេធ្វើស្រែប្រាំងនៅខេត្តណាខ្លះ ? បើគ្មានទំនប់ទឹក គេធ្វើស្រែប្រាំងកើតឬទេ ? ការធ្វើស្រែប្រាំងពិបាកជាងធ្វើស្រែវស្សាយ៉ាងណាខ្លះ ? ពីព្រោះអ្វី ?



## ២៦-២៧ — ច្រូតស្រូវ (បទពាក្យ ៧)

កណ្ដាលវាលស្រែ នៅខែបុស្ស អ្នកស្រែស្រីប្រុស ច្រើនពេកក្រៃ
លើកគ្នាច្រូតស្រូវ ច្រវាស់ដៃ រាល់ថ្ងៃក្រោមមេឃ ខៀវស្រឡះ ។
ក្រោកឡើងពីយប់ គេនាំគ្នា ម្នីម្នាចុះស្រែ មុនថ្ងៃរះ
កណ្ដៀវនៅដៃ ទាំងក្មេងចាស់ កាត់រះដើមស្រូវ ចងកណ្ដាប់ ។
ថ្ងៃទ្រេតពីត្រង់ ក្ដៅដូចភ្លើង ពួកអ្នកច្រូតយើង នៅស្ងាបហាប់
វាតទីច្រូតស្រូវ យ៉ាងចំណាប់ យកឆាប់រៀងខ្លួន ពុំមានល្ហែ ។
ជួនកាលលេចឮ សព្ទសំដី ប្រុសស្រីចំអន់ គ្នាហោអែ
បែកសំឡេងខ្ទាយ ឆ្ងាយកាត់ស្រែ រួចគេងើបបែរ មើលមុខគ្នា ។

សៀលត្រជាក់ ធ្លាក់ខ្យល់មក ពពករសាត់ កាត់មេឃា
ស្មៅម្អមបញ្ចោញ នូវក្លិនផ្កា អ្នកប្រុតគ្រប់គ្នា បានធូរស្បើយ ។
ថ្ងៃលិចព្រលប់ យប់មកដល់ ឥតអ្នកណាខ្វល់ នឹងពេលឡើយ
គេនៅទំប្រុត ធ្វើព្រងើយ ព្រោះបង់បង្ហើយ ស្រូវក្នុងស្រែ ។

ន័យ : (អ. ថ. នៅ) កា. ទិ. ពាក្យប្រាប់ដំណើរ សម្រេចអំពើដែលគេត្រូវធ្វើ ។ ទីនេះ ផ្កាស្មៅ ម្អម ក្រោយដែលបានទទួលចំហាយក្តៅយ៉ាងយូរ ហើយស្រាប់តែ មកប៉ះខ្យល់ត្រជាក់វិញភ្លាម ក៏ត្រូវបញ្ចោញនូវក្លិនរបស់វា ។ បែកសំឡេងខ្លាយឆ្ងាយកាត់ស្រែ : សំឡេងអ្នកប្រុតហៅព្រួញខ្លាំងហើយរសាត់ទៅឆ្ងាយតាមរលកខ្យល់ស្រាវ ។

---

• ពាក្យដែលត្រូវយាត់អានជាមុន : ប្រវាស់ដៃ ម្អមា ស្ទាហាប់ សព្ទ ខ្លាយ មេឃា នូវ ព្រងើយ ។

• ជញ្ជាំងគិត : តាមធម្មតា រដូវប្រុតចាប់ពីខែណាទៅខែណា ? ហេតុម្តេចបានជាអ្នកនិពន្ធលើកតែខែបុស្សមកនិយាយ ? អ្នកប្រុតធ្វើការគ្មានឈប់ហើយរីករាយផង ឃ្លាត្រង់ណាខ្លះដែលបញ្ជាក់ថាធ្វើការគ្មានឈប់ ? ថាអ្នកប្រុតរីករាយ ?

• ដំណើរកាព្យពាក្យ ៧ : កំណាព្យនេះ អាចធ្វើជាបទក៏បាន ច្រៀងក៏បាន តាមចំណង់អ្នកអាន ។ ចូរអ្នកលៃធ្វើបទណាមួយបែកយើងស្តាប់ផង ។

## ២៨-២៩ – ល្បែងលក់ដូរ

១ – នាងវួចហៀង ធ្វើជាអ្នកលក់ ។ ពៅណាំធ្វើជាកូ

ឈ្មួល ។ នាងផលា និង ពៅសាកល ធ្វើជាអ្នកទិញ ។

នៅលើតុមួយ ពៅណាំបានរៀបតាំង សាលាដ ប៉េងប៉ោ

ដីឡូប់ ត្រកួន នៅខាងស្តាំ អំបោះប៉ាក់ ម្ជុល បេសហើយនឹ

កំណាត់សំពត់តូចៗ នៅខាងឆ្វេង ។

នាងផលា ហើយនឹង ពៅសាកល បានដាក់គំរបដបពេ

ហោប៉ៅ ទុកធ្វើប្រាក់ ។



នាងរុំប្រហៀង ប៉ានសំពត់សមួយនៅពោះ រង់ចាំអ្នកទិញ ។
- ជំរាបសួរ! លោកស្រីត្រូវការអ្វី សុំមានប្រសាសន៍ ។
- បាស! ខ្ញុំចង់ទិញស្ករយកទៅធ្វើនំឲ្យកូនញ៉ាំ បាស! មួយគីឡូថ្លៃប៉ុន្មាន ?
- ១៥ រៀល លោកស្រី ។
- ថ្លៃណាស់! ខ្ញុំធ្លាប់ទិញតែ ១៣ រៀលទេ ។
- ស្ករនេះល្អណាស់ គ្រាប់វាធំៗ លោកស្រីមើល ខ្ញុំទិញមកមួយគីឡូថ្លៃ ១៤ រៀលទៅហើយ ។
- អើ! ថ្លឹងឲ្យមួយគីឡូមក ។
២ - ហៅណាំហែកក្រដាសសៀវភៅចាស់មួយ យកមកខ្ចប់ស្ករ ហើយថ្លឹងនឹងជញ្ជីងដែលវាទើបនឹងធ្វើហើយ ។
- ថ្លឹងឲ្យត្រឹមត្រូវ ។
- បាទ! ទុកចិត្តលើខ្ញុំចុះ ។
- សុំមើលភ្នែកជញ្ជីងផង ។
- អញ្ជើញពិនិត្យលោកស្រី ផ្ទះខ្ញុំលក់ថ្លៃ ត្រង់បំបាត់ទម្ងន់មិនហ៊ានតែម្តង ។ នាងផលាទទួលកញ្ចប់ស្ករពីហៅណាំ ហើយ

ល្អកហោប៉ៅ យកគំរបក្បាលដបពីរថ្លៃ ២០ រៀល ហុចទៅតា

រួបហៀង ។ តាងរ៉ូបហៀងថា: អរគុណ! ក្រោយដែលបានអា

គ្រួសអាបម៍ផ្កាយមួយថ្លៃ ៥ រៀល ជូនមកតាងផលាវិញ ។

*ប្រសាសន៍ : (អ.ថ សាស ន.) ពាក្យបង្គាប់ ពាក្យផ្ដាំផ្ញើ*

*បណ្ដាំ ។ ខ្មែរយើងប្រើចំពោះតែពាក្យ សំដីរបស់ឥស្សរជនក្រៅពីក្សត្រ*

*ស្ទូវ : ន. គួរតែ ដោយប្រថុយ បើមិនដល់ថ្លៃមិនលក់ទេ ស្ទូ*

*យកទៅផ្ទះវិញជាដាន់ ។ មិនសូវគ្មាញ់ មិនឆ្ងាញ់ប៉ុន្មាន ។*

---

- *ហាត់អាន : ឲ្យសិស្សអានម្ដងបីនាក់ - ម្នាក់ធ្វើអ្នកទិញ - ម្នាក់ធ្វើអ្*

*លក់ ម្នាក់ទៀតធ្វើកូនឈ្នួល ។*

*សិស្សណាពេះអានទម្លាក់សំឡេងត្រូវល្អ ទុកជាគ្រាន់បើ ។*

- *ការសំដែងដោយសេរី : ឲ្យសិស្សដើរតួតាមសាច់រឿងដោយ*

*មានសិស្សអ្នកពោលម្នាក់ ។*

- *វេយ្យាករណ៍ : ចូរអ្នករកពាក្យផ្ទុយនឹងពាក្យ លក់ កូនឈ្*

*លោកស្រី ខ្ចប់ ហើយសរសេរនៅគ្ការឈ្មនលើកមកមើល ។*



# ៣០ – ជ្រូក ពពែ និងចៀម

១ – ឈ្មួញម្នាក់ដាក់ពពែ ចៀម ហើយនិងជ្រូកក្នុងរទេះ នាំ
កទៅលក់នៅឯទីក្រុង ។ តាមផ្លូវ ជ្រូកស្រែកខ្លាំងដូចគេរៀប
ក់ករា ។ អ្នកផងទាំងពួង ឮដំនឹងសំរែកនេះស្ទើរបែកត្រចៀក ។
ធ្ងល់និងជ្រូក ដែលស្រែកហៅឲ្យគេជួយ ព្រោះគេរកមើលមិន
ញ មានហេតុនាំឲ្យខ្លាចយ៉ាងនេះសោះ ។

---

២ – អ្នកបររទេះសួរជ្រូកថា: ម្ដេចក៏ឯងស្រែកខ្លាំងម៉្លេះ ឯង
លចៀមនិងពពែ វានៅស្ងៀម ។
ជ្រូកឆ្លើយថា: អាពីរហ្នឹងវាភ្លើ បើវាដឹងការណ៍ដូចខ្ញុំនោះ
ហែលជាវាស្រែកខ្លាំងជាងខ្ញុំទៅទៀត ។ ពពែស្មានថា គេដឹក

វាយកទៅរំតទឹកដោះ   ឯចៀមក៏ស្មានថាគេយកវាទៅកាត់រោមដែ

ដែលខ្ញុំថានេះ មិនដឹងជាខុស ឬត្រូវទេ ។ ប៉ុន្តែ ចំពោះខ្លួនខ្ញុំ

ប្រាកដជាគេដឹកខ្ញុំយកទៅកាប់ស៊ីហើយ ។ សេចក្តីស្លាប់របស់

ទៀងណាស់ ខ្ញុំសូមលាហើយ លាឈប់ខានជួបជុំបួល នឹងទ្រ

ដែលខ្ញុំធ្លាប់ជ្រក ។

មនុស្សក្តី សត្វក្តី តែងតែចង់រស់គ្រប់គ្នា ។ ម្ល៉ោះហើយ 

មិនឲ្យជ្រកភ័យដូចម្តេចបាន ?

« ស្រង់សម្រួលចេញពីកម្ពុជសុរិយា ឆ្នាំ ទី ៣៥ លេខ ១ ទំព័រ ៦៣ »

---

ចៀម : ន. ឈ្មោះសត្វជើងបួនមួយពួកគេចិញ្ចឹមសម្រាប់កាត់យករោ

ធ្វើកម្រាល ឬ ធ្វើសំពត់ផ្សេង ៗ ។

ការណ៍ : អ. ឋ. កា : ហេតុ ដំណើរ ទាស់ការណ៍ហើយឯន

---

* ឧញ្ញាណគិត : ហេតុម្តេចបានជាជ្រូកស្រែកខ្លាំង ? ម្តេចក៏ពពែនឹ

ចៀមនៅស្ងៀម ? បើជ្រូកចៀសស្លាប់មិនរួចទេ វាចាំស្រែកធ្វើអ្វី ? បើខ្ញុំ

អ្នកជាជ្រូកវិញ តើអ្នកស្រែកថ្ងូរ ឬ ទេ ? ពីព្រោះអ្វី ?

## ៣១ — ផ្លូវត្រឡែងកែង



១ – នៅផ្លូវត្រ-ឡែងកែង មានរថយន្តតូច រថយន្តធំ រថយន្តដឹកទំនិញ បើកទៅមកជាជួរ ៗ គេនឹកឆ្ងល់ថា រថ-យន្តដែលទៅមកមិនឈប់យ៉ាងនេះ ម្តេចក៏មិនប៉ះទង្គិចគ្នាសោះ ។ ួនកាលមានគ្រោះថ្នាក់រថយន្តម្តង ៗដែរ ហើយបើកាលណាមាន ហតុយ៉ាងនេះ មានតែប៉ូលិសដែលយាមប៉ុស្តិ៍នៅទីនោះ បានរក ុស-ត្រូវឲ្យអ្នករងគ្រោះឃើញ ។

២ – នៅផ្លូវត្រឡែងកែង អ្នកជិះទោចក្រយាន អ្នកបរត្រី-ចក្រយាន ប្រជ្រៀតគ្នាឆ្លងផ្លូវជាមួយនឹងរថយន្ត គ្មានខ្លាចគ្រោះថ្នាក់អ្វីសោះ ។ ឃើញតែអ្នកដើរប៉ុណ្ណោះទេ ដែលបេះប្រយ័ត្ន ៗ គេនៅឈរត្រង់កន្លែងឆ្លងកាត់ រង់ចាំទាល់តែរទេះឡានឈប់ មាន

សញ្ញាពណ៌ខៀវជាឲ្យឆ្លងកាត់ ទើបគេបានឆ្លងផ្លូវ ។

នៅចិញ្ចើមថ្នល់ មានមនុស្សអ៊ូអរណាស់ ។ អ្នកខ្លះឈរ មើលហាងលក់ទំនិញ អ្នកខ្លះចូលមើលកុន អ្នកខ្លះទៀតកំពុង ទិញផ្កា ។ នៅទីនេះ ម្នាក់ៗគិតតែពីមុខការរៀងៗខ្លួន ឥតមាន រវល់ដល់អ្នកណាឡើយ ។

*ត្រឡែងកែង : ន. ឬ គុ. ដែលមានមុខ ៤ ផ្លូវត្រឡែងកែង គឺផ្លូវ បែក ៤ ។*

---

• *ជញ្ជីងគំនិត : ផ្លូវត្រឡែងកែងដែលនិយាយនេះ នៅឯណា ? ហេតុម្ដេចបានជាអ្នកថានៅទីក្រុង ? ផ្លូវត្រឡែងកែងនៅស្រុកស្រែអ៊ូអរឬស្ងាត់ ? នៅពេលណាផ្លូវត្រឡែងកែង នៅទីក្រុងអ៊ូអរជាងគេ ?*

• *តែងសេចក្ដី : ចូរអ្នកនិយាយពីផ្លូវថ្នល់នៅស្រុកស្រែ ហើយនឹង ផ្លូវនៅទីក្រុង : អ្នកមានឃើញអ្វីខ្លះនៅថ្នល់ឯទីក្រុង ? នៅថ្នល់ឯស្រុកស្រែ ? ផ្លូវថ្នល់ទាំងពីរនេះ តើថ្នល់ណាអ៊ូអរ ? ផ្លូវថ្នល់ណាស្ងាត់មិនសូវមានអ្នក ដំណើរ ? អ្នកចូលចិត្តដើរនៅផ្លូវណា ? ពីព្រោះអ្វី ?*





១ - នៅជាយក្រុង ផ្ទះជំរៀបគ្នាជាជួរសង់ហួរហែតាមបំពោមថ្នល់ដ៏មានសួនផ្កាមួយ ៗ ជួយលំអផង ។ ផ្លូវថ្នល់នៅទីនេះ មិនសូវអ៊ូអរប៉ុន្មានទេ ។

លុះដល់កណ្ដាលក្រុង ផ្ទះសង់ជាប់ ៗ គ្នាជាច្រើនជាន់ មើលទៅឃើញខ្ពស់ត្រដឹម ។ ការធ្វើដំណើរនៅកន្លែងនេះ ពិបាកណាស់ ព្រោះនៅផ្លូវថ្នល់ រថយន្តធំ-តូចបើកទៅមកគ្មានឈប់ ។ នៅបំពោមថ្នល់ មនុស្សដើរប្រជ្រៀតគ្នា មីរដេរដាសមិនដាច់ ។

២ - គេចែកទីក្រុងជាសង្កាត់ផ្សេងពីគ្នា សង្កាត់នីមួយ ៗ មិនដូចគ្នាទេ ។ នៅសង្កាត់ចាស់ ផ្លូវថ្នល់ច្រើនតូច ហើយផ្ទះក៏

មិនសូវល្អប៉ុន្មានដែរ ។ នៅសង្កាត់ណាថ្មី ដែលទើបនឹងរៀប
ហើយ គេឃើញផ្ទះធំស្កឹមស្កៃ ផ្លូវថ្នល់ធំទូលាយ លាតសន្ធឹងទៅ
រកសួនច្បារ ហើយនឹងវិមានដ៏ឆើតឆាយ ។

៣– នៅសង្កាត់ជំនួញ មានហាងទំនិញល្អប្លែក ៗ រាប់មិន
អស់ តាំងនៅសងខាងផ្លូវ គួរឲ្យចង់ចូលមើល ។ មនុស្សគ្រប់
ស្រុកចូលមកកកកុញនៅកន្លែងនេះ ដើម្បីទិញបំណីអាហារ ទិញ
សំលៀកបំពាក់ ទិញប្រដាប់ប្រដាធ្វើការ ។ល។ ហើយនឹងលក់
ផលដំណាំ ព្រមទាំងរបស់ផ្សេង ៗ ផង ។

ក្នុងសង្កាត់ឧស្សាហកម្ម គេឃើញមានរោងចក្រធំ ៗ ប្រកប
ដោយបំពង់ផ្សែងហុយទ្រលោមជានិច្ច ។

៤– មនុស្សនៅទីក្រុង ច្រើនជាអ្នករាជការ ជាអ្នកជំនួញ
ជាកម្មករ ជាសិស្សសាលា ។ល។ ក្នុងមួយថ្ងៃ ៗ ពេលដែលអ្នក
ទាំងអស់នេះ ចេញទៅធ្វើការ ឬត្រឡប់មកពីធ្វើការវិញ ផ្លូវថ្នល់
នីមួយ ៗ តែងតែអ៊ូអរខុសប្រក្រតី ។

*ត្រដឹម : គុ. ឬ កិ. វិ. ខ្ពស់ត្រដួចសន្ធឹម មើលទៅឃើញត្រដឹម*

*មិរដេរដាស : គុ. ច្រើន តាន់តាប់ កកកុញ ត្រៀបត្រា*

● ជញ្ជាំងគិត : ផ្ទះនៅទីក្រុងដូចផ្ទះនៅស្រុកស្រែឬទេ ? ខុសគ្នាដូចម្តេចខ្លះ ? ផ្ទះនីមួយ ៗ នៅទីក្រុង មានគ្រួសារតិចឬច្រើននៅ ? ហេតុដូចម្តេចបានជានៅទីក្រុង គេបែកជាសង្កាត់ ? សង្កាត់នីមួយ ៗ មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ ? ផ្លូវថ្នល់នៅទីក្រុង ខុសពីផ្លូវថ្នល់នៅស្រុកស្រែចំការដូចម្តេច ?

● វេយ្យាករណ៍ : ពាក្យដែលអានថា កា ហើយមានន័យខុសគ្នា មាន ៧ : កា ន. បំពង់សម្រាប់ដាក់ទឹក កាទឹក ។ កា : កិ. សរសេរចុះឈ្មោះទីលំនៅអ្នកដែលនឹងទទួលសំបុត្រ លើស្រោមសំបុត្រ កាខ្នងសំបុត្រ ។ កាណ៌ : អ. ៥ កា ន. ត្របៀកស្តេច ។ ការ: កិ. មូរសរសៃសូត្រ សរសៃអំបោះជាខ្នារ ការសូត្រ សរសៃអំបោះដោយខ្នារ ការសូត្រ ការអំបោះ . . . ។ ការ : កិ. បិទបាំង រាំងរា ឃាត់ឃាំង ការមិនឲ្យសត្រូវចូលមក ការពារខ្លួន ។ ការ : ន. កិច្ច ឬ អំពើដែលត្រូវធ្វើ ធ្វើការ មានការ ការអ្វីខ្លះ ។ ការណ៍ (អ.៥ កា) : ហេតុ ដំណើរ ។

● ការិយកម្ម : ចូរអ្នកធ្វើជាឃ្លានឹងពាក្យ : « កា » ទាំង ៧ ឲ្យបានម្នាក់មួយឃ្លា ហើយសរសេរ “ កា „ ដែលអ្នកប្រើក្នុងឃ្លានោះ នៅក្តារខៀនលើកបង្ហាញឲ្យគេឯងមើលផង ។





## ៣៤-៣៥ – កង្កែបធ្វើដំណើរ

១– រដូវប្រាំង កង្កែបមួយចេញមកសំដិលខ្លួននៅទីវាល ។ ពេលនោះមានទាព្រៃមួយហ្វូង ហើរបន្ទាបខ្លួនពីលើមេឃ ហើយចុ មកលេងទឹកនៅជិតវា ។ កាប ៗ! កិប ៗ! ធាតុអាកាសនៅ ខាងត្បូងកាន់តែល្អឡើងហើយ ។

កង្កែបឆ្ងល់ សួរទាព្រៃថា៖

– បងទា! អ្វីខាងត្បូង ខាងត្បូងមានអ្វីខ្លះ?

– ខាងត្បូងបឹងមានទឹកឧណ្ហ ៗ ហើយមានកន្លែងឲ្យយើងរ ស៊ីយ៉ាងស្រួល ។

– មានមមាប មេភ្លៀង ហើយនឹងកណ្ដូប ឬទេ ?

– ច្រើនណាស់! សត្វល្អិតហើរ វារពាសពេញដីឯនោះ

– បងទា ! តាំងពីកើតមក ខ្ញុំមិនដែលបានទៅឯណាទេ ខ្ញុំស្គាល់តែបឹងនេះ ។ ខ្ញុំសុំទៅខាងត្បូងជាមួយពួកបងផង ។

ពួកទាព្រៃសើច ហើយឆ្លើយថា: – ឯងមានស្លាបឯណានឹងហើរ? កង្កែបថា ឈប់! ខ្ញុំសុំបងគិតរកផ្លូវ ប្រាំនាទីសិន ។

២ – កង្កែបមុជទឹកទៅបាតបឹង ហើយមមុលខ្នបួលភក់ប្រយោជន៍ងាយប្រមូលគំនិតគិត ។ ប្រាំនាទីបានកន្លងទៅហើយ ។ ពួកទាព្រៃកំពុងចំកាងស្លាប រៀបចេញដំណើរ ស្រាប់តែកង្កែបងើបក្បាលឆ្លោមកវិញ ។ អូក ៗ ! ខ្ញុំគិតឃើញហើយ ខ្ញុំអាចទៅជាមួយពួកបងបាន ។ នេះបង្កើះ សូមបងពាំចុងម្ខាងម្នាក់ ខ្ញុំខាំប្រគោងត្រង់ពាក់កណ្ដាលបង្កើះ ។ បងហើរខ្ញុំធ្វើដំណើរតាមបងទៅ ។ បើបងយល់ព្រម ខ្ញុំសុំបងថា តាមផ្លូវអាកាស បងក្ដីខ្ញុំក្ដី យើងកុំហាមាត់និយាយឲ្យសោះ ។

៣ – ពួកទាព្រៃនឹកថា ហើរយោងកង្កែបមួយ មិនមែនធ្ងន់ទេ តែថា ហាមមិនឲ្យនិយាយក្នុងការធ្វើដំណើរ ពេញមួយថ្ងៃជាការពិបាកនឹងខាន ។ ប៉ុន្តែ ដោយវាពេញចិត្តនឹងប្រាជ្ញាកង្កែបផង ហើយវាចង់បើកយានជំនិះថ្មី ដែលកង្កែបទើបនឹងបង្កើតផង ពួកទាព្រៃក៏សុខចិត្តហើរពាំបង្កើះ នាំកង្កែប ធ្វើដំណើរតាមផ្លូវអាកាសទៅ ។



សំដិល : កិ. ហាលខ្យល់ហាលក្នុងម្លប់ ឬ ហាលក្នុងទីវាល នៅវេលាដែលមានកំដៅព្រះអាទិត្យទន់ ហាលថ្ងៃមួយស្របក់ សំដិលសំពត់ ឈើសំដិលខ្លួន ។

មមុល : កិ. ត្រសុល ។

---

● ជញ្ជឹងគិត : សត្វណាខ្លះដែលហើរមករកស៊ីនៅប្រទេសយើងតែនៅរដូវប្រាំង ? ( ចាបព្រៃវែង - ទាព្រៃ ) កង្កែបនឹកឃើញដូចម្ដេច បានជាចង់ផ្ញើដំណើរតាមទាព្រៃ ? ឃ្លាត្រង់ណាដែលបញ្ជាក់ថាកង្កែបចង់យ៉ាងនោះ ? យានដែលកង្កែបបង្កើតស្រួលជិះ ឬ ទេ ? ពីព្រោះអ្វី ?

● ប្រណាំងអាន : ឲ្យសិស្សហាត់អានត្រង់វគ្គទី ៣ ។ សិស្សណាចេះអានពីរោះ ទុកជាគ្រាន់បើ ។

ចូរអ្នកបំពេញឃ្លាខាងក្រោមនឹងពាក្យពីរ អ្នក - នាក់ ។ ........ ទៅណា ? ខ្ញុំទៅផ្សារជាមួយបងខ្ញុំពីរ ...... សិស្សមួយ ...... នោះខ្ជិល ។ ខ្ញុំហៅបងថ្លៃប្រុសខ្ញុំថា ...... ។ ...... គ្រូខ្ញុំតែងខ្លួនសមរម្យណាស់ ។



១ - តាមផ្លូវអាកាស កង្កែបកើតភ័យសឹងគ្មានឈប់ ។ ដង្ហើមវាលែងស្មើគ្នាហើយ ។ ពួកទាព្រៃហើរខ្ពស់ ។ កង្កែបទំខាំបង្កើះហើយក្រឡេកភ្នែកមើលមកខាងក្រោម ។

២ - វាឃើញស្រូវទុំពេញស្រែពណ៌លឿង ឃើញដើមត្នោតដុះដោតពាសវាល ឃើញស្ទឹង-ទន្លេបត់ពង់ពេន ឃើញព្រៃពណ៌បៃតង ឃើញពពករសាត់លើភ្នំ . . . ។ ធម្មជាតិទាំងអស់នេះញាំងវាឲ្យរីករាយណាស់ ។ វានឹកកោតដល់ប្រាជ្ញាវាដែលបេះរកឃើញយានបង្កើះ ។ វាចង់ថ្លែងអំណរគុណដល់ទាព្រៃ ។

៣ - ទាព្រៃវាយបំពុះ បានប្តូរវេនគ្នាពាំបង្កើះម្តងម្នាក់ យ៉ាងប៉ុនប្រសប់ ។ ពេលនោះកង្កែបយើងស្លុតស្មារតី ដូចបានស្លាប់មួយដង ឬពីរដងទៅហើយ ។ កង្កែបមើលមកក្រោម ឃើញមនុស្សតូចៗ បែបទាបៗ នាំគ្នាមើលហ្វូងទា ហើយចង្អុលមកវា ។ វាចង់ដឹងថា តើមនុស្សអស់នោះ និយាយពីវាយ៉ាងណាខ្លះ ?

៤ – ថ្ងៃប្រផាត់មាត់ព្រៃហើយ ពួកអ្នកដំណើរយើងបានបបួលគ្នាសម្រាក យកកម្លាំងនៅដៃព្រៃកមួយ ។ លុះព្រលឹមស្រាងៗ ហ្វូងទារៀបចំដំណើរទៅទៀត ។ កង្កែបនិយាយថា បើយើងហើរឲ្យទាបទៅមិនបានឬអ្វី ? ពួកទាព្រៃអាណិតកង្កែប ព្រមធ្វើតាមបំណងវា ។ ម្ដងនេះកង្កែប ឃើញភូមិ ឃើញផ្ទះ ឃើញគំនរកណ្ដាប់ស្រូវ ឃើញមនុស្សប្រូតស្រូវ ។ វាឮស្នូរគេបោកស្រូវ ទុបៗ ឮមាត់មនុស្សស្រែកប្រាប់គ្នាថា មើលយន្តហោះប្ដី អ្នកណាអេះ! បង្កើតគ្រឿងប្រដាប់នេះ ។

មនុស្សស្រី.ប្រុស ផ្អើលងោឡើងមើលវា ហើយសួររកអ្នកបង្កើតយានថ្មីៗគ្នា ។ កង្កែបឡើងជោរ អត់មាត់មិនបាន ក៏ស្រែកថា « គឺខ្ញុំ! គឺខ្ញុំតែម្នាក់ឯង » ។

*ស្ទូត : កិ. ភ័យខ្លាំង ស្ទុតការ់ការ៉ស្មារតី ។ ពាហាន បិត្តមុតមិនស្ទុតនឹងប្រាំង ។ ថ្ងៃប្រផាត់មាត់ព្រៃ : ពេលថ្ងៃរៀបលិច នៅកំពស់ចុងឈើឯនាយ ។*

---

● ផញ្ញាជភិត : *កង្កែបមួនភ័យ មួនអរ ។ តាមផ្លូវអាកាសកង្កែបភ័យពីព្រោះអ្វី ? អរពីព្រោះអ្វី ? ហេតុម្ដេចបានជាដំណើរលើកទី ២ កង្កែបសុំឲ្យទាហើរទាប ? អ្នករកនឹកមើលថា តើកង្កែបវាទៅជាយ៉ាងណាក្រោយដែលវាថា គឺខ្ញុំ! គឺខ្ញុំតែម្នាក់ឯង ។*

## ៣៨-៣៩ – គ្រោះថ្នាក់តាមដំណើរ



១ – គីង! គីងតែម្នាក់ឯង ។ គ្រាន់តែបានមាត់ថាគី ... កង្កែបយើងរបូតខ្លួនពីបង្កើះភាម ក្បាលដាំទឹង គូថបះឡើងលើ ធ្លាក់មកក្រោមយ៉ាងលឿន ។ ទាព្រៃមួយឃើញទាន់
...ានហាក់ចាប់កង្កែបយើងដែរ តែឥតប្រយោជន៍ ហាប់ផុត ហាប់ផុត ។

២ – សំណាងល្អ! ខ្យល់បានជួយដាក់វាទម្លាក់ចំបឹង ខុសពីដីរឹង ។
...ង! កង្កែបយើងលិចបាត់ទៅក្នុងទឹកល្អក់ សន្លប់បាត់មាត់ៗកង្កែប
...ាច្រើននៅកន្លែងនោះ ភ្ញាក់ផ្អើលនឹងសូរនេះ មុជទឹកបាត់អស់ ។
ដល់ដឹងខ្លួនមកវិញ កង្កែបយើងនៅស្រែកថា : គីង! គីង
...តម្នាក់ឯង ។

៣ – កង្កែបនៅបឹងនឹកឆ្ងល់ ក៏បបួលគ្នាមកជុំ ហើយសួរ
...កង្កែបយើងថា :

– អ្វីទៅគីង! គីងតែម្នាក់ឯង ?

កង្កែបយើងឆ្លើយថា មួយជីវិតនេះ ខ្ញុំបានបង្កើតយានជិះ
...មួយ សម្រាប់ជិះធ្វើដំណើរ ។ យាននោះល្អចំឡែកណាស់ សូម្បី

មនុស្សកើតស្លាដៃខ្ញុំដែរ ។ តាមផ្លូវ គេសួររកអ្នកបង្កើតយាន
នោះគ្រប់ៗគ្នា ។ ហេតុនេះហើយ បានជាខ្ញុំជាប់មាត់ ទន្ទេញ
ប្រាប់គេថា គឺខ្ញុំ ! គឺខ្ញុំតែម្នាក់ឯង ។

៤– វាបន្ថែមសេចក្ដីទៀតថា ខ្ញុំមានទាព្រៃច្រើនជាសេនា។
មុននេះ ខ្ញុំបានបង្គាប់វាឲ្យបើកយានខ្ញុំ ទៅទុកនៅទិសខាងត្បូង
ទៅហើយ ។ ខ្ញុំផ្ដាំនឹងវាថា ដល់ផុតរដូវប្រាំង សូមឲ្យវានាំគ្នា
ត្រឡប់មកដឹកខ្ញុំទៅស្រុកវិញ ព្រោះខ្ញុំចង់សង្កេតមើលការរស់នៅ
របស់ពួកអ្នកនៅបឹងនេះ ឲ្យបានមួយប្រាំងសិន ។

(រឿងកង្កែបធ្វើដំណើរបប់តែប៉ុណ្ណោះ ។ ទាព្រៃឥតបានមករក
កង្កែបវិញទេ ព្រោះវាស្មានថា កង្កែបធ្លាក់មកស្លាប់ទៅហើយ ) ។

*ធាប : កិ. ហើរហកចុះទាប ដើម្បីនឹងចាប់អ្វី ? ក្អែកធាបកូនមាន់ ។*

*សេនា : ន. ( អ-ថ-សេ-ណា ) ពួកទាហាន ពួកពល កងទ័ព ។*

---

● *ផញ្ញើគំនិត : គ្រោះថ្នាក់កង្កែបបណ្ដាលមកពីអ្នកណា ? ពីព្រោះអ្វី ? ត្រង់លេខ ៤ កង្កែបយើងនិយាយកុហក ។ អ្នកយល់ព្រមឲ្យវានិយាយកុហកយ៉ាងនេះឬទេ ? មនុស្សដូចកង្កែបនេះ ជាមនុស្សដូចម្ដេច ?*

● ការសំដែងដោយសេរី : ឲ្យសិស្សនិយាយរឿង កង្កែបធ្វើដំណើរ
ងពីដើមដល់ចប់ ។

– ឲ្យសិស្សសាកានរឿងកង្កែបធ្វើដំណើរតាំងពីដើមដល់ចប់ ។

● រៀនពាក្យ : អំពីដំណើរ

នាម : យន្តហោះ រថភ្លើង រថយន្ត ទោចក្រយាន ត្រីចក្រយាន
ក កប៉ាល់ សេះ រទេះគោ ដំរី អ្នកដំណើរ ទំនិញ ។

គុណនាម : ខ្ពស់ ទាប លឿន រហ័ស យឺត ធ្ងន់ ស្រាល ។

កិរិយាសព្ទ : ដឹកនាំ ផ្ទុកទំនិញ ធ្វើដំណើរ ប្ដូរគំនិត ។

● ពាក្យសួរ : ពីដើមគេធ្វើដំណើរតាមអ្វី ? សព្វថ្ងៃគេធ្វើដំណើរតាមផ្លូវ
ាខ្លះ ? តាមផ្លូវអាកាសគេជិះអ្វី? តាមផ្លូវទឹក តាមផ្លូវគោកគេជិះអ្វី? យានណា
កទំនិញបានរហ័សជាងគេ ? យានណាដែលគេផ្ទុកទំនិញបានច្រើនជាងគេ ?
គេត្រូវដឹកនាំទំនិញតាមផ្លូវណាឲ្យអស់ឈ្នួលតិចហើយបានច្រើនផង ។





## ៥០-៥១ — ដំណើរ (បទកាកគតិ)

កាលពីបូរាណ ដំណើរមិនបាន ដូចសព្វថ្ងៃនេះ
ផ្លូវទឹកជិះទូក ផ្លូវគោកជិះសេះ ជិះស្នែងរទេះ
ពុំនោះ ដើរ ៗ ខុសពីឥឡូវ អ្នកប្រាជ្ញមានផ្លូវ
បង្កើតយានថ្មី រថយន្តរថភ្លើង បរតាមវិថី
លឿនលយឥតបី រកអ្វីប្រៀបបាន ៗ ផ្លូវទឹកនាវា
មានស្លាបបក្រខារ ដូចគេរុញច្រាន បើកកាត់ទន្លេ
សមុទ្រប៉ុន្មាន អាចទៅមកបាន ដូចក្តីប្រាថ្នា
មិនតែប៉ុណ្ណោះ លើមេឃយន្តហោះ ផ្លោះអាកាសា
អាចធ្វើដំណើរ ឆ្លងកាត់ទ្វីប៉ា ហោះលឿនអស្ចារ្យ

គ្មានយានណាស្មើ ។ ដោយសារស្ពាដៃ អ្នកប្រាជ្ញសម័យ
ធ្វើយន្តឲ្យដើរ ដឹកនាំទំនិញ នឹងអ្នកដំណើរ
លើសលែងប្រសើរ ហួសពីការស្មាន ។

នាវា ន. ទូក សំពៅ កប៉ាល់ ។ ទារ : កិ. ទាញអូសដោយគ្រឿងចក្រ ។ ផ្លោះ : កិ. លោតរំលង ។ ទ្វីប : ន. ប្រទេសដែលជាក់ស្ដែងក្នុងកណ្ដាលទឹក គោះ (ដើម្បីឲ្យដួនក្នុងកំណាព្យ ទ្វីប ក្លាយជា ទ្វីប៉) ។

ហាត់អាន : ឲ្យសិស្សហាត់អានពាក្យ រថភ្លើង វិថី នាវា ស្ពាបចក្រ ទារ ផ្លោះ ទ្វីប៉ា អស្ចារ្យ សម័យ ។

ជញ្ជឹងគិត : ជាន់ដើមមានយានអ្វីខ្លះសម្រាប់ធ្វើដំណើរ ? បើចង់កាត់ព្រៃគេជិះអ្វី ? បើចង់ឆ្លងសមុទ្រគេជិះអ្វី ? សព្វថ្ងៃយើងមានយានអ្វីខ្លះសម្រាប់ធ្វើដំណើរ ? យានសម័យនេះខុសប្លែកពីសម័យមុន ចូរអ្នកនិយាយតើប្រយោជន៍យានថ្មីសព្វថ្ងៃនេះយ៉ាងណាខ្លះ (លឿន បានសុខសាន្ត ទៀងពេល) ។

ការសំដែងដោយសេរី : ចូរអ្នកគូររូបយានថ្មីទាំងអស់ដែលអ្នកបានស្គាល់ ។



## ៤២ - ៤៣ — ជាងកាត់សក់នៅភូមិខ្ញុំ



១ – នៅកណ្ដាលៈ

ខ្ញុំ  មានរោងជាងកាត់ស

មួយ ។  រោងនោះ

ឫស្សីនិងស្លឹក  រាងប្រ

បន្តិចទៅហើយ ។ រ

ថ្ងៃអ្នកស្រុក តែងមកអង្គុ

លេងនៅរោងនោះ  ព្រ

ជាងកាត់សក់  មាន

ឈើត្រង់មួយឲ្យលេង ហើយនិងសារពត៌មានថ្មីៗ ឲ្យអានកំសាន្ត

២ – ជាងកាត់សក់នៅភូមិខ្ញុំ ឈ្មោះ ប៉ាង ។ រាងគាត់ស្ដើង

ស្លេក ហ្វាសធក ។ គាត់ជាមនុស្សមិនសូវមានកម្លាំងមាំមួនប៉ុន្មានទេ

៣ – ជាងប៉ាងរកស៊ីកាត់សក់ជាង ១៥ ឆ្នាំហើយ ។ គ

ជាជាងមួយពេះកាត់សក់ច្រើនបែបណាស់ ។ ពេលណាអ្នកកាត់ស

មកដល់  គាត់មិនប្រញាប់កាត់ភ្លាមទេ ។ គាត់យកក្រាសសិតស

អ្នកនោះ ហើយសង្កេតមើលពីខាងក្រោយ ពីចំហៀងក្បាល ។ គាត់ថយក្រោយពី-បីជំហាន ពិនិត្យមើលសក់ម្ដងទៀត ទើបគាត់ចាប់យកកន្សែងស មករុំព័ទ្ធខ្លួនអ្នកមកកាត់សក់ ។

៤ – កន្ត្រៃ កាំបិតកោរ ជាងប៉ាងមុតណាស់ ។ មួយថ្ងៃៗ គាត់កាត់សក់បានច្រើននាក់ ។ ឥឡូវ ជាងប៉ាងអាយុជិត ៤០ ឆ្នាំហើយ ភ្នែកគាត់កាន់តែងងឹត ព្រោះមួយថ្ងៃ ៗ តាំងពីព្រឹកទល់ល្ងាច គាត់ខំសំឡឹងមើលសក់ ហើយនឹងកញ្ចក់ឆ្លុះឥតឈប់ ។ ហេតុនេះហើយ បានជាក្នុងពេលធ្វើការ គាត់ពាក់វ៉ែនតាជានិច្ច ។

មុខរបរកាត់សក់នៅភូមិខ្ញុំ បានផលគួរសមដែរ ។

*កំសាន្ត : ក. សំរាកចិត្ត ធ្វើឲ្យក្សាន្តចិត្ត លំហើយចិត្ត ។*

---

● *ជញ្ជឹងគិត: ពេលកាត់សក់នៅភូមិអ្នកនៅត្រង់ណា ? នៅពេលនោះមានអ្វីខ្លះ? ជាងកាត់សក់នៅពេលនោះចាស់ឬក្មេង? គាត់សក់បានល្អឬទេ? ជាងយកថ្លៃក្បាលមួយប៉ុន្មាន? កាំបិតកោរនឹងកន្ត្រៃជាងមុតឬមិនមុត? ជាងកាត់សក់នៅភូមិអ្នករកស៊ីបានធូរឬទេ ? ធំឡើងអ្នកចង់ធ្វើជាងកាត់សក់ឬទេ ? ពីព្រោះអ្វី?*

● *ការសំដែងដោយសេរី : ឲ្យសិស្សពីរនាក់លេងល្បែងកាត់សក់ មួយធ្វើជាង មួយធ្វើអ្នកមកកាត់សក់ ។ ការលេងនេះគួរមានកំប្លែងដោយវាចា ដោយអវយវៈ មានញាក់មុខ ញាក់មាត់ជាដើមផង ។*

រឿងមួយដំណាលថា :

សេដ្ឋីម្នាក់ ត្រូវការផ្លូវឈ្នាន់កែបសេះ ជាបន្ទាន់ បានបញ្ជូ

ទៅរោងជាងដែកឈ្មោះ ណាម ។ ជួនពេលជាមួយគ្នានេះ អ្នកស្រ

ម្នាក់លីនង្គ័លមកដល់ ហើយស្រែកពីងជាងណាមថា :

– ណាម ! ផ្លូវដែកផៀងនង្គ័លគាបន្តិច ប្រឹះខ្ចាស់ហើយ ស្រ

គ្នានៅឆ្ងាយណាស់ ។ ជាងទទួលផៀងនង្គ័លមកធ្វើ ។ សេដ្ឋីទ

អន់ចិត្តព្រោះខ្លួនមកដល់មុន ក៏និយាយថា :

– ម្តេចមិនធ្វើឈ្នាន់កែបសេះខ្ញុំសិន ។ ជាងណាមងាកមករ

សេដ្ឋី ងក់ក្បាលគំនាប់ ហើយឆ្លើយថា :



– តាមតែលោកអត់ទោសខ្ញុំផងចុះ ជាងល្អត្រូវស្គាល់ការ ហើយត្រូវហាប់ធ្វើការណាដែលប្រញាប់មុន ។ លោកជ្រាបហើយថា ការអ្នកស្រែបំការនឿយលំបាកណាស់ ខ្ញុំមិនអាចធ្វើឲ្យតានេះរង់ចាំខ្ញុំយូរ ក្នុងពេលដែលគាត់ទៅភ្ជួរស្រែ ក្រោមកំដៅថ្ងៃទេ ។

សេដ្ឋីឮសំដីនេះ មិនសប្បាយចិត្តសោះ ។ ប៉ុន្តែ ដោយនឹកឃើញថា ជាងដែកនិយាយមកត្រូវពេក មិនអាចឆ្លើយតបទៅវិញបាន ទើបខំខាំមាត់សង្កត់ចិត្តព្រមនៅស្ងៀមទៅវិញ ។

សេដ្ឋី : (អ.ថ សេត-ថី) ន. អ្នកមានទ្រព្យច្រើន ។

ក...

● បញ្ញាជំរិត : ជាងដែកគិតឃើញយ៉ាងណា បានជាមិនផ្សារឈ្នាន់កែបសេះឲ្យសេដ្ឋីមុន? បើអ្នកជាជាងដែកវិញតើអ្នកធ្វើដូចជាងណាមួយទេ? ពីព្រោះអ្វី?

● វេយ្យាករណ៍ : របៀបប្រើពាក្យ " ទើប " ទើប : និ. ពាក្យជាសន្ធានសម្រាប់និយាយបន្តឃ្លាសេចក្ដីដោយឡែក ច្រើនប្រើបន្តពីឃ្លាសេចក្ដីរបស់ពាក្យថា : លុះតែ ទាល់តែ បើ... ដូចសេចក្ដីមានដើមថា : លុះតែគេសួរខ្ញុំ ទើបខ្ញុំឆ្លើយ ។ ទាល់តែដល់ម៉ោង ទើបដេកលក់ ។ ខ្ញុំទើបមកដល់ ។ ជួនណាគេនិយាយភ្ជាប់នឹងពាក្យថា បាន នឹង តែនឹង ដូចពាក្យថា : ទើបបានគេមក ទើបនឹងដឹង ទើបតែនឹងយល់ ។

● ការិយកម្ម : ឲ្យសិស្សហាត់ធ្វើឃ្លានឹងពាក្យ " ទើប " ។



៤៩ – ជាងដែកយែន

គ្រាន់តែជាងដែកផ្សារផ្ទៀងគង្គលហើយ មានសេះមួយអូសរទេះដំណើរទើបៗចូលមកដល់រោងជាងទៀត ។ ស្រីម្នាក់រាងកន្ទ្រលលោតចុះពីរទេះសេះ ហើយលើកដៃសំពះរួចថា :

– ជំរាបសួរលោកធំ! ជំរាបសួរជាង! សូមជាងបោះដែកក្រចកសេះឲ្យខ្ញុំមួយភ្លែត ថ្ងៃកាន់តែខ្ពស់ហើយ ព្រឹកនេះខ្ញុំដឹកមាន់-ទានឹងបន្លែច្រើនណាស់ តែយឺតក្រពានដល់ផ្សារ មុខជាលក់លែងដាច់ហើយ ។

ជាងណាម បែបស្នាក់ស្មើរ ទាល់តែយូរបន្តិចទើបព្រមទទួល ។

– មិនអីទេ! ជួយកាន់សេះឲ្យនឹងទៅ ខ្ញុំធ្វើហើយឥឡូវ ។

ពេលនោះ សេដ្ឋីទឹងឡើងមុខក្រហម បញ្ចេញសំឡេងខ្លាំង ៗ ថា :

– មិនត្រូវបោះក្របកឲ្យសេះគិរក់នេះ មុនធ្វើឈ្នាន់កែបសេះខ្ញុំទេ។

– យី! បាទបើសេះខ្ញុំគិរក់ផង សេះខ្ញុំមិនល្អជិះសេះលោកធំទេ ប៉ុន្តែ មិនត្រូវមើលងាយវាឡើយ ព្រោះវាអួសរទេះគ្មានឈប់ ។ សេដ្ឋីឈប់និយាយតនឹងស្រី បែរមកអង្វរជាងណាមវិញ :

– ជាងឯងចង់បានឈ្នួលប៉ុន្មាន? ថាមក! ខ្ញុំជូនប៉ុណ្ណោះកុំឲ្យតែខ្ញុំចាំយូរទៀត ។

ជាងដែកយើងញញឹម ហើយឆ្លើយថា :

– ជំរាបលោកធំ! ស្រីនេះមេម៉ាយ មានកូនតូច ៗ ច្រើនណាស់ សូមលោកធំ ជួយអាណិតគាត់ផង តែខកជំណើរគាត់មុខជារកអង្ករចិញ្ចឹមកូនមិនបានទេ ។ សេដ្ឋីយល់ថា ជាងណាម គិតត្រូវ ក៏ងក់ក្បាលហើយនៅស្ងៀមជាថ្មីទៀត ។

*គំរគាំ : ដែលអាក្រក់យកជាការមិនបាន ។*

---

*ជញ្ជាំងគិត: គុ. អ្នកស្រែឲ្យជាងដែកធ្វើអ្វី ? ស្រីមេម៉ាយពឹងជាងណាមឲ្យធ្វើអ្វីដែរ? ជាងណាមយល់ឃើញយ៉ាងណាខ្លះ បានជាទទួលធ្វើការពីរនេះមុនស្បាន់ឈ្នាន់កែបសេះសេដ្ឋី ? ជាងណាមគិតដល់អ្នកក្រីក្រយ៉ាងនេះត្រូវឬខុស ?*

# ៤៦-៤៧ – ជាងកាត់ដេរនៅភូមិខ្ញុំ



១ – ម្សិលមិញ នាង
សុផល បានទៅផ្ទះ
មីងផៃ ដើម្បីកាត់អាវ
មួយ ។

មីងផៃ យកខ្មៅដៃ
ក្នុងសៀវភៅមកបើក
ដាក់លើតុ ។ គាត់

ទាញម៉ែត្រសំពត់មួយ ដែលគាត់បំណាំតែពាក់នៅក មកវាស់ខ្លួន នាងសុផល ។ មីងផៃវាស់បណ្ដោយដងខ្លួន វាស់ទំហំដើមទ្រូង ខ្នង ចង្កេះ ហើយកត់ក្នុងសៀវភៅ ។ បន្ទាប់មក គាត់ពិនិត្យកំណត់នោះ ហើយណាន់មាត់ថា ៖ យី ! ភ្លេចវាស់ដៃទេតើ ។

– បត់កែងដៃទៅនាង ! ឲ្យមីងងាយវាស់ដៃអាវ ។

នាងសុផល ធ្វើតាមបង្គាប់មីងផៃយ៉ាងស្រួល ។

២ – មីងផៃ លាក្រដាសមួយផ្ទាំងយ៉ាងធំដាក់លើតុ ។ គាត់

ាស់-គូស ហើយកាត់ក្រដាសនោះតាមកំណាត់ក្នុងសៀវភៅ ។
ក្រដាសដាច់ជាផ្នែក លេចរាងជាដៃ ជាខ្លួន ជាពោះអាវ ។ នាង
សុផល តាមមើលកិច្ចការមីងផៃ ហើយនិយាយថា៖

– នេះជាអាវក្រដាស ឬអ្នកមីង ?

– ហ្នឹងហើយនាង ! មកឈរត្រង់នេះ ឲ្យមីងលអាវនាងមើល ។

នាងសុផល ឈរត្រង់ខ្លួន ឲ្យមីងផៃ លអាវតាមត្រូវការ ។

– បានហើយ ! សមណាស់នាង មិនបាច់កែតម្រូវទេ ។

៣ – ម្ដងនេះ មីងផៃ យកកំណាត់ផ្កាមកលាតលើតុ យក

អាវក្រដាសមកខ្ទាស់ពីលើធ្វើគំរូ ហើយកាន់ដីសខៀវគូសតាម ។

ចុងក្រោយបង្អស់ មីងផៃយកកន្ត្រៃមកកាត់សំពត់តាមគំនូស

នោះ ដើម្បីបានផ្គុំដេរធ្វើជាអាវនាងសុផល ។

*លាន់មាត់ : កិ. បញ្ចេញសំឡេងខ្លាំង ឬ តិចដោយគ្មានចេតនា ។*

---

● *ជញ្ជឹងគិត : អ្នកដឹងឬទេ ពីព្រោះអ្វីបានជានាងសុផល បណ្ដោយ ឲ្យមីងផៃវាស់តាមត្រូវការ ។*

● *នែងសេចក្ដី : អ្នកដែលទៅជួលជាងកាត់ការ សំពត់ ឬ ទោនៅ ផ្ទះជាងកាត់ការម្នាក់នៅភូមិអ្នកដូច នាងសុផល ដែរ ។ ចូរអ្នកនិយាយរៀបរាប់អំពីផ្ទះអ្នកកាត់ដេរនោះ ហើយទំនងអំពីកិច្ចការគាត់ផង ។*

## *៤៨ — ផ្ទះកំពុងសង់*

១ – តាមបន្លោះវត្ថា ខ្ញុំមើលផ្ទះកំពុងសង់ ឃើញដូចជាទ្រុងសត្វអ្វីមួយ ៗ ជញ្ជាំងរៀបឥដ្ឋពុំទាន់ហើយ កន្លែងខ្ពស់ កន្លែងទាប មានទុកប្រហោងជាច្រើន ៗ គន់មើលយូរទៅ ផ្ទះនេះមិនគ្រាន់តែអាក្រក់ទេ ខ្ញុំថែមទាំងធុំក្លិនកំបោរ ស៊ីម៉ង់ត៍ ហើយនឹងឥដ្ឋទៀតផង ៗ

ទុកជាយ៉ាងដូចម្ដេច ក៏គេពុំទាន់ដឹងថា ផ្ទះកំពុងសង់នឹងក្លាយទៅជាយ៉ាងណាដែរ ពីព្រោះនៅដី កូនជាងកំពុងលាយបាយអ នៅវត្ថាខាងលើ មេជាងកំពុងធ្វើការគ្មានឈប់ ៗ



២ - ជាងបាយអ រៀបឥដ្ឋម្ដងមួយ ៗ ប៉ុន្តែ ជញ្ជាំងរីកធំ ហើយឡើងខ្ពស់រហ័សណាស់ ។

លុះផ្ទះនេះ មានរាងជាប្រអប់ធំមួយ ស្រាប់តែមានជាងជាច្រើននាក់ទៀតមកដល់ ។ ជាងឈើបាច់ធ្វើដំបូល ហើយនឹងដាក់ទ្វារបង្អួច ។ ជាងភ្លើងវាយខ្សែអគ្គិសនី ហើយនឹងដាក់លំផ្លូងបង្កៀង ។ ជាងទឹកតបង្កប់បំពង់ទឹក ។ ជាងបេតុងរៀបបំពុម្ព ពត់ដែកដាក់បេតុង ធ្វើជណ្ដើរ ។ ចុងក្រោយបង្អស់ ជាងលាបពណ៌មករំលីងជញ្ជាំង ហើយលាបផ្ទះឲ្យកាន់តែស្រស់ឡើង ។ គិតទៅដើម្បីធ្វើផ្ទះមួយ ឲ្យនៅបានស្រួល គេត្រូវការជាងច្រើនណាស់ ។

*រន្ទា : ន. ដើមឬស្សីឬលំពង់ឈើ ដែលចងប្រគងលើគ្នាជាច្រើន ទប់ត្រៀនជាន់ឡើងធ្វើការក្នុងទីខ្ពស់ „ ចងរន្ទា „ ។*

---

• *ជញ្ជឹងគិត : ហេតុម្ដេចបានជាផ្ទះមិនទាន់ធ្វើហើយ មើលទៅឃើញអាក្រក់ ? ផុកផុយមិនល្អ ? គេយកអ្វីខ្លះទៅធ្វើផ្ទះឥដ្ឋ ថ្ម ? ដើម្បីសង់ផ្ទះនេះគេត្រូវការជាងណាខ្លះ ? ដូចម្ដេចដែលហៅថាផ្ទះនៅបានសុខ ?*

• *រៀនពាក្យ : ការសង់ផ្ទះ នាម : ផ្ទះ បាយអ ឥដ្ឋ ថ្ម ដែកសរសៃ រន្ទា ខ្សែអគ្គិសនី បំពង់ទឹក ដំបូល ក្បឿង បេតុង ។ គុណនាម : ខ្ពស់ ទាប ស្មើ រលីង គគ្រាត ។ កិរិយាសព្ទ : សង់ រៀបឥដ្ឋ បោះប្រហោង ចាក់ពុម្ព វាយខ្សែអគ្គិសនី បង្កប់បំពង់ទឹក នៅបានសុខ ។*



## ៤៩-៥០ — មេអំបៅនឹងចង្រិត (បទកាកគតិ)

មានមេអំបៅ ស្លាបលឿងឆ្នូតខ្មៅ ដំក្រហមស្លា
ហិចហើរលើសួន រាំរែកដាក់ផ្កា សំដែងរូបា
អួតបង្ហាញគេ ៗ កាលនោះចង្រិត សំដិលនៅជិត
មាត់រន្ធឃើញមេ- អំបៅរូបល្អ កកើតចិត្តគ្នេរ
ងាកបែរប្រែរេ តូចចិត្តខ្លួនឯង ៗ ជាអញចង្រិត
រូបខ្មៅកក្រិត អាក្រក់ក្រៃលែង នៅរន្ធក្នុងដី
ជាផ្ទះសំបែង កម្មអីព្រេងឯង កើតជាសត្វអន់ ៗ
មើល មេអំបៅ រូបល្អឆ្អិនឆ្អៅ គួរឲ្យគយគន់
និត្យនៅអាកាស សង្ហាពេកពន់ ស្មើនឹងហង្សយន្ត
ក្នុងរឿងបុរាណ ៗ សិននោះមានក្មេង មួយក្រុមរត់លេង



ប្របសួនកំសាន្ត ក្រឡេកឃើញមេ
អំបៅកល្យាណ កើតចិត្តចង់បាន
ក៏លើកគ្នាហប់ ។ សត្វល្អជីងខួន
ទំគេចវេះពួន ឆ្វេឆ្វាប្រញាប់
ហើរស្ទន់ទៅមក ប៉ះដៃក្មេងរ៉ាប់
ក្មេងលាដៃក្តាប់ ស្ទាបចង់កាយា ។
ថ្លែងពីចង្រិត ឃើញហេតុប្រែចិត្ត
បាត់ចង់សង្ហា វារចូលក្នុងវល្ល
ហើយគន់គិតថា លាក់ពួនអាត្មា
បានរស់សប្បាយ ។

ដំក្រាហាមស្វា : ចុចរង់មូលពណ៌ក្រហម ដូចទឹកមាត់មនុស្សស៊ីស្លាម្លូ ។
សំដែងវុទ្ធា : ទីនេះបញ្ចេញរូបល្អ ។ កម្មអំព្រោងឯង : សំណាងឯង
កអាក្រក់មិនបានដូចគេ ។ ហាង្សយន្ត : ហង្សគ្មានព្រៃ ។ ហង្សយន្ត
យានជំនិះធ្វើដូចសត្វហង្សរបស់ស្តេចមួយព្រះអង្គក្នុងរឿងបុរាណ ។

---

• ជញ្ជាំងគិត ហេតុម្តេចបានជាចង្រិតប្រដូចមេអំបៅស្មើនឹងហង្សយន្ត?
ប្អូនចង្រិតចង់ធ្វើមេអំបៅ តើហេតុអ្វីបានជាវាបែរប្រែចិត្តមិនចង់ធ្វើវិញ?

# ៤១-៤២ – អ្នកណាយាមព្រៃអមលាំង?



១ – កាលដើម ព្រៃអមលាំ
នៅឆ្ងាយពីស្រុកភូមិ ។ ក្នុងព្រៃ
នេះ មានសត្វអាស្រ័យនៅច្រើ
ណាស់ ។ សត្វអស់នេះរស់នៅ
ជាសុខសាន្ត... ។

២ – លុះក្រោយមក បានមានមនុស្សទៅដល់ ។ មនុស្ស
បរបាញ់សត្វនៅអមលាំង មិនគ្រាន់តែយក មកធ្វើជាអាហារ
មនុស្សខ្លះបាញ់ដំរីយកភ្លុក ។ ខ្លះបាញ់ខ្ទីង-ខ្លា យកស្នែងនិង
ស្បែក ។ ខ្លះបាញ់ក្ងោកយករោមសំណុំកន្ទុយ ។ ខ្លះបាញ់សត្វ
បំផ្លាញ ដើម្បីកំសាន្តទៀតផង ។

៣ – ពួកសត្វព្រៃនៅអមលាំង កើតភ័យខ្លាំង ក៏គិតថា បើមនុស្ស
នៅតែបរបាញ់យ៉ាងនេះ យើងមុខជាស្លាប់អស់ពូជមិនខាន ។ ដូចនេះ
យើងត្រូវទៅជួបនឹងលោកតាបង្កួយ ឲ្យលោកជួយដោះទុក្ខយើង ។

សត្វទាំងអស់នាំគ្នា ទៅជួបនឹងសត្វបង្កួយ ហើយនិយាយថា:

– លោកតាបង្កួយ ! តាជាអ្នកចេះដឹងជាងគេនៅទីនេះ សូមតា

ជួយកុំឲ្យព្រានបរបាញ់

យើងបានទៀត ។

– ឈប់ ! ចាំអញ

គិតសិន ។



៤ – មួយសន្ទុះ

ក្រោយមកបង្ហួយប្រាប់

សត្វទាំងនោះថា :

– មានតែផ្លូវមួយទេ

បើបង់ឲ្យរួចខ្លួនទាំង

អស់គ្នា យើងត្រូវរកអ្នកយាមម្នាក់ ឲ្យចាំយាមមើលព្រាន ។ កាល

ណាឃើញព្រានមកពីចម្ងាយ យើងខ្ញុំប្រាប់គ្នាឲ្យរត់ កុំឲ្យជួបនឹង

វា ។ ការសំខាន់ក្នុងរឿងនេះ គឺរកអ្នកយាម ។ តើអ្នកណាអាច

ធ្វើជាអ្នកយាមបំណាននបាន ?

៥ – សត្វទាំងអស់ស្រែកថា រកអ្នកយាមបំណាន ! ការនេះ

មិនមែនងាយទេ ។ ពេលនោះ មានខ្លារខិនចាស់មួយឆ្លើយឡើងថា:

– ភ្នែកខ្ញុំមើលឃើញឆ្ងាយ ជើងខ្ញុំរត់បានលឿន ខ្ញុំបេះដើរ

មិនឲ្យឮស្នូរ ខ្ញុំចេះលាក់ខ្លួនបាត់នៅគុម្ពស្មៅ ឬនៅមែកឈើ ខ្ញុំអាចធ្វើជាអ្នកយាមពូកែបាន ។

សត្វទាំងអស់យល់ព្រមតាម ក៏តាំងខ្លារខិនជាអ្នកយាម ។ តាំងពីកាលនោះមក ព្រានព្រៃមិនដែលបាញ់បានសត្វ នៅព្រៃអមលាំងទេ ព្រោះតែកាលណាលេចក្បាលព្រានឡើងៗមក ខ្លារខិនឲ្យដំណឹងដល់សត្វឯទៀត ឲ្យរត់គេចបាត់អស់ភ្លាម ។

*ព្រៃអមលាំង : ព្រៃមួយធំនៅខេត្តកំពង់ស្ពឺ ជាប់តាំងពីខេត្តពោធិ-សាត់មក ។ អាស្រ័យ : (អ-ច-អា ស្រៃ) ពឹងពាក់ជ្រកកោន - ជ្រកនៅ ។*

---

● *ជញ្ជឹងគិត : ព្រានយកប្រយោជន៍អ្វីខ្លះពីការបរបាញ់សត្វ ? អំពើដែលមនុស្សដើរបរបាញ់សត្វដូចខាងលើ តើត្រូវឬខុស ? ពីព្រោះអ្វី ? ខ្លារខិនកញ្ចាស់ដែលចង់ធ្វើជាអ្នកយាម មានគំនិតអ្វីកំបាំងដែរឬ ? ប្រហែលជាកំចង់យ៉ាងណា ?*

● *រៀនពាក្យ : អំពីសត្វព្រៃ នាម : ដំរី ខ្ទីង ទន្សោង ក្របីព្រៃ ប្រើស ក្តាន់ ល្មុស ទោច ស្វា ខ្លាធំ ខ្លារខិន ឆ្កែចចក ពស់ ។ គុណនាម : សាហាវ ស្លូត រហ័ស ខ្លាំង ស្រួច សាំង ផ្សើល ។ កិរិយាសព្ទ : ទាំ ទះ ចឹក ស៊ីស្មៅ ស៊ីសាច់ ។*

● *ការិយកម្ម : ចូរអ្នករាប់សត្វព្រៃសាហាវឲ្យបាន ៥ សត្វព្រៃដែលស្លូតឲ្យបាន ៥ ហើយនឹងសត្វព្រៃដែលច្រើនតែនៅជិតភូមិអ្នកស្រុកឲ្យបាន ៣ ។*

## ៥៣-៥៤ — អ្នកយាមមានពុត



១ – ខ្លារខិនពូកែយាមមែនហើយ ប៉ុន្តែវាក៏ពូកែលាក់ពុតណាស់ដែរ ។ កាលណាឃើញឈ្លូស និងប្រើស វាខ្សឹបប្រាប់ថា ព្រានមកដល់ ហើយមកតាមអញ អញនាំឯងទៅពួននៅកន្លែងស្ងាត់ ។

ទៅដល់កន្លែងស្ងាត់ ខ្លារខិនខាំឈ្លូស និងប្រើសស៊ីទៅដោយគ្មានសត្វណាមួយដឹងឡើយ ។

២ – ខ្លារខិនស៊ីឈ្លូសនិងប្រើសមួយថ្ងៃអស់តែមួយទេ តែដល់យូរៗទៅ ចំនួនប្រើសនិងឈ្លូសកាន់តែ ោះពីព្រៃអមលាំង ។ ឈ្លូសនិងប្រើសដែលនៅសល់ទាំងប៉ុន្មានបានដឹងខ្លួនទាន់ ក៏នាំគ្នាទៅប្ដឹងសត្វឯទៀត ។ ពួកសត្វទាំងនោះនិយាយថា :

– ខ្លារខិនពូកែយាមណាស់ ។ សព្វថ្ងៃយើងអាចគេចរួចពីដៃ

ព្រាន ក៏ព្រោះតែវាឲ្យដំណឹងទាន់ពេលវេលា ។ ឈ្លូសឆ្លើយថា :

– វាឲ្យដំណឹងពួកខ្ញុំញឹកញាប់ណាស់ដែរ តែបើបណ្ដោយឲ្យវាធ្វើដូច្នេះតទៅទៀត ឈ្លូសនឹងប្រើស មុខជាស្លាប់បាត់អស់មិនខាន។

៣ – ពួកសត្វឯទៀត ឆ្លើយតបមកឈ្លូសវិញ :

– ខ្លារខិនបំពេញមុខការ ជាអ្នកយាមអស់ប៉ុណ្ណឹងហើយ ។ ឯរឿងផ្សេង ៗ ទៀត បំពោះពួកឯងនឹងវា យើងមិនអាចទទួលដឹងឮបានទេ ។ បើឯងមិនសុខចិត្តទេ ចូរឯងរកអ្នកយាមសម្រាប់ឯងចុះ ។

– រឿងហ្នឹងហើយ ដែលយើងមកនេះ គឺថាយើងលែងត្រូវការខ្លារខិន ឲ្យយាមពួកយើងទៀតហើយ ។

៤ – ថាតែប៉ុណ្ណោះ ឈ្លូសនឹងប្រើស ក៏សួរដំរីភ្លាម :

– បងសុខចិត្តជួយយាមពួកខ្ញុំឬទេ ?

ដំរីថា ទេ! ពួកឯងជាសត្វបោលលឿនណាស់ ម្ដងឯងលោតផ្លោះទៅខាងនេះ ម្ដងទៅខាងនោះ អញគ្មានកម្លាំងរត់តាមឯងទេ ។

ឈ្លូសនឹងប្រើសសួរទៅរមាសថា :

– បងសុខចិត្តជួយយាមពួកខ្ញុំឬទេ ?

រមាសថា : – អញធ្លាប់រស់នៅតែឯកឯងនៅទីស្ងាត់ ឆ្ងាយពីគេ ។ ដូចនេះ ឲ្យអញធ្វើជាអ្នកយាមឯងដូចម្ដេចកើត ។

ឈ្លូសនឹងប្រើស ក៏បែរសួរទៅក្រពើវិញ :

– បងសុខចិត្តជួយយាមពួកខ្ញុំ ឬទេ ?

ក្រពើថា  អញរស់បានតែនៅមាត់ច្រាំង-បឹង-ទន្លេ ។ ថា តែប៉ុណ្ណោះ វាក៏ក្រាំងទៅវិញ ។

*លាក់ពុត : ក្មេងធ្វើឫកឲ្យគេទុកចិត្ត ដោយបំរុងនឹងរករឿងហេតុពីគេ ដូចជាខ្លារខិនខំធ្វើជាអ្នកយាមពួក ដើម្បីឆ្លៀតរកស៊ីឈ្លូស ប្រើស ។*

*ក្រាំង : កំ-កប់ខ្លួននៅស្ងួតក្នុងដី ។*

---

*ជញ្ជឹងគិត : ពីព្រោះអ្វីបានជាខ្លារខិនព្រមធ្វើជាអ្នកយាម ? វាធ្វើយ៉ាងណាទើបនាំឈ្លូសទៅស៊ីបាន ? ឈ្លូសនឹងប្រើសទៅប្ដឹងសត្វឯទៀតពីរឿងនេះ ហេតុម្ដេចក៏សត្វឯទៀតការពារខ្លារខិន ? ។*



# ៩៥-៩៦ — ការជ្រើសរើសអ្នកយាម



១ - ឈ្លូសនឹងប្រើស
ពឹងដំរី រមាសហើយ
និងក្រពើមិនបាន ក
នាំគ្នាទៅជួប នឹងសត្វ
បង្គួយឲ្យជួយរកអ្នក
យាមទៀត ។ លុះ
បានជួបហើយ វានិយាយប្រាប់បង្គួយ
សត្វគ្រប់ ពីពុតខ្លារខិន ។ បង្គួយ
ពន្យល់ថា: «អ្នកត្រូវរើសរកសត្វណា
មួយ ដែលមើលឃើញឆ្ងាយ-ដែល
រត់លឿន ហើយខ្លាំងជាងខ្លារខិនទៅ
ទៀត ពីព្រោះវាត្រូវការពារអ្នក នឹង
ព្រានផង ហើយនឹងខ្លារខិនផង ។ ម្យ៉ាងទៀតអ្នកមិនត្រូវយកសត្វ
ណា ដែលស៊ីសាច់ទៅទេ » ។

ឈ្លូសនឹងប្រើសលាន់មាត់ព្រមគ្នាថា ត្រូវហើយៗ ! ។



បង្កួយថា: – ឈប់! កុំអាលមាត់ហាំ ខ្ញុំរកឈ្មោះសត្វឲ្យ ។ បង្កួយធ្វើក្បាល ងក់ៗរកនឹក ប៉ុន្តែមិនឃើញ ។

២– នៅពេលនោះ មានឋាបមួយ កំពុងរកចំណីនៅគុម្ពស្មៅ លុះបាន ស្តាប់រឿងនោះទាំងអស់ហើយ វាឆ្លើយ ដាបគ្នាថា :

– ខ្ញុំស្គាល់សត្វនោះច្បាស់ណាស់ បើអ្នកទាំងអស់គ្នាបង់ដឹង ទាល់តែឲ្យពងស្រាំងខ្ញុំមួយសំបុក ទើបខ្ញុំប្រាប់ ។

ឈ្លូសនឹងប្រើសអង្វរថា: – ឲ្យប្រាប់មកចុះ យើងសន្យានឹងរក ពងស្រាំងឲ្យបងឯងពីរសំបុកផង ។

ឋាបប្រាប់ថា: – សត្វនោះ... សត្វនោះ... គឺក្ងោក ។

ប្រើសឲ្យយោបល់ថា: – យើងជាពួកសត្វជើងបួន មិនសម នឹងទៅពឹងសត្វស្លាបមកឲ្យយាមយើងទេ ។

ឈ្លូសតបទៅវិញថា : – គួរតែឲ្យក្ងោកយាមពួកយើងលមើល សិន បើទុកជាយ៉ាងណា ក៏វាមិនអាចក្បត់យើងដូចខ្លារខិនដែរ ។

៣– ឈ្លូស នឹងប្រើស នាំគ្នាទៅជួបនឹងក្ងោកហើយនិយាយថា

– សូមបងជួយយាមពួកយើងផង ព្រោះខ្លារខិន ក្បត់ពួកយើងច្រើនដងណាស់ហើយ ។

ក្អែកថា: – មិនអីទេ! ចាំខ្ញុំជួយ ។ ខ្ញុំសុំកុំឲ្យតែបងឈ្លូសលួចបិចបោចកន្ទុយខ្ញុំ ។ ខ្ញុំមិនជាឈឺប៉ុន្មានទេ ប៉ុន្តែ ខ្ញុំគិតថា អ្នកណាលេងកន្ទុយខ្ញុំ អ្នកនោះមើលងាយខ្ញុំហើយ ។

*ក្បត់ : ធ្វើការដោយកលឧបាយ ដោយកលកំបាំងក្នុងបំណងឲ្យបាត់បង់ខ្លួនអ្នកដទៃ ឬអ្នកដែលត្រូវទំនុកបំរុង ឬអ្នកជាមិត្រ ។*

---

*ជញ្ជឹងគិត : បន្ទ័យថា ត្រូវរើសអ្នកយាមសម្រាប់ឈ្លូស ទឹង ប្រើស ឲ្យមានលក្ខណៈយ៉ាងណាខ្លះ ? បើអ្នកវិញ អ្នកថាត្រូវរើសសត្វណាឲ្យយាមឈ្លូស ទឹង ប្រើស ? អ្នកជឿថាក្អែកអាចបំពេញមុខងារជាអ្នកយាមបានឬទេ ?*

*វេយ្យាករណ៍ : ពាក្យ សិង ពាក្យ សិន មានពីរ សិន : ន. មាត្រារង្វាស់ ចម្ងាយប្រវែង ២០ ព្យាម ។ សិន : និ. ក្សិណ សំ ក្សណ ខ្លះ ជួន ជួនកាល : សិនដេក សិនក្រោក សិនថាទៅ សិនថានៅ ។ ពាក្យសម្រាប់ប្រើផ្ញើពីខាងចុងពាក្យដទៃ ច្រើនតែប្រើជាជំនួយ កិរិយាសព្ទ ប្រាប់កំណត់កាលថា « មួយរំពេច មួយស្របក់ » ឈប់សិន កុំអាលសិន ។*

*ការិយកម្ម : ចូរអ្នកហាត់ធ្វើឃ្លានឹងពាក្យ « សិន » ន. ហើយនឹង « សិន » និ. ឲ្យបានម្នាក់មួយឃ្លា ។*



១-នៅព្រៃអមលាំង ខ្លារខិនមើលឃើញសត្វទាំងអស់គ្មានសល់ ។ វាឃើញទាំងក្ងោក ជាអ្នកយាមថ្មីផង ឃើញទាំងព្រានផង ។ ប៉ុន្តែវានៅតែហ៊ានបញ្ចោញពុតខ្ទបដដែល ។

២ – កាលណាវាឃើញកូនឈ្លូសមួយ រកស៊ីឆ្ងាយពីមេ ខ្លារខិនក៏ទៅជិត ហើយខ្សឹបដាក់ត្រចៀកកូនឈ្លូសនោះថា :

– ព្រានមកដល់ហើយ ឯងនៅទីនេះមុខជាស្លាប់មិនខាន បូរឯងមកតាមអញបានរួចខ្លួន ។ ឮដូច្នោះ កូនឈ្លូសឆ្លើយឡើងថា :

– ទេ! បើព្រានមកមែន នោះក្ងោកឲ្យដំណឹងពួកខ្ញុំហើយ ។

ខ្លារខិនបញ្ជាក់ថា :

– ក្ងោកជាសត្វស្លាប វាមិនរវល់នឹងព្រាន ដែលមកបាញ់សត្វជើងបួននោះទេ ។ អញជាសត្វជើងបួនដូចឯង អញទុកឲ្យមនុស្សសម្លាប់ឯងដូចក្ងោកមិនកើតទេ អញអាណិតឯងណាស់ បានជាអញ

នៅស្មៀមមិនកើត ។

ម្តងនេះ កូនឈ្មួសជឿខ្លាវទិនសិប់ ក៏ព្រមទៅតាម ។

៣ – ខ្លាវទិនវែកស្មៅតាំផ្លូវទៅមុខ ។ កូនឈ្មួសដើរ តាមក្រោយ ។ ស្មៅខ្ពស់ញែកផ្លូវឲ្យសត្វទាំងពីររត់ពួន ហើយដើបទងតម្រង់មកវិញ ឥតមានទុកដាន ឲ្យសត្វណាមួយដឹងឡើយ ។ នៅពេលនោះ សត្វទាំងអស់រកស៊ីព្រៃដើយ ។ មានតែក្ងោកមួយដែលជាអ្នកយាម អាចមើលឃើញរឿងហេតុនេះ ។

៤ – ក្ងោកទទះស្លាបហើរ បន្ទាបខ្លួនសំដៅទៅរកខ្លាវទិន ។ ជិតដល់ វាស្ទុះប្ញូលប្រាសខ្លាវទិនឮសូរព្រួស ។ ខ្លាវទិនស្រែកង៉ាកយ៉ាងខ្លាំង ហើយប្រកាប់រកផ្លូវទៅណាពុំរួច ព្រោះឆ្មាល់ក្ងោកបានចាក់បំភែកវាទាំងពីរ ។

៥ – ក្ងោកនាំកូនឈ្មួស មកឲ្យមេវាវិញ ។ តាមផ្លូវវាប្រាប់កូនឈ្មួសថា ថ្ងៃក្រោយ បើឯងជឿតាមខ្លាវទិនទៀត អញនឹងចាក់ឯងនឹងឆ្មាល់មិនខាន ។

កូនឈ្មួសសន្យាថា ខំរាងចាលហើយ ខំស្តាប់តែបងមួយទេ ខំលែងជឿខ្លាវទិនទៀតហើយ ។

លុះមកដល់ហ្វូងឈ្មួសនឹងប្រើស ក្ងោកពង់ជំឡើងឬក ស្រែក

ប្រមូលហៅគ្នា ហើយប្រាប់រឿងហេតុទាំងអស់ ដល់ឈ្លូសនឹងប្រើសយ៉ាងជាក់ច្បាស់ ។ សត្វទាំងអស់លាន់មាត់ព្រមគ្នាថា ៖

យីអើ! បងចាប បេះរើសអ្នកយាមឲ្យយើងត្រូវមែន ។

សព្វ: កិ.វិ. គ្រប់គ្រាន់ ពេញទី ពេញលេញឥតខ្វះខាត ចុះចិត្ត ស៊ប់ ជឿស៊ប់ ។ ដាន: ន ស្នាម លំអាន ផ្លូវ គន្លងដានជើង ដានរទេះ ។ ធ្នាល់: ន គ្រឿងអាវុធរបស់សត្វខ្លះបាទពកខ្វះដុះនៅជើង សម្រាប់ការពារខ្លួន: ធ្នាល់មាន់ ធ្នាល់ទា ធ្នាល់ក្ងោក ។

---

● ផ្ញាំគិត : ខ្លាខិនអាចស៊ីបានជា ហ៊ានបោកកូនឈ្លូសនាំទៅស៊ី ? នៅវគ្គទី ២ ពាក្យត្រង់ណាដែលបញ្ជាក់ថា ខ្លាខិនបោកកូនឈ្លូស ? ហេតុម្ដេចបានជាសត្វឯទៀតមិនឃើញ ? បានជាក្ងោកឃើញ ? ក្ងោកឈ្នះខ្លាខិនដោយសារអ្វី ? ចុងក្រោយ ម្ដេចក៏សត្វឯទៀតលាន់មាត់សរសើរចាបទៅវិញ ?

● ការសំដែងដោយសេរី : ឲ្យសិស្សនិយាយរឿងសត្វនៅព្រៃអមលាំង តាំងពីដើមដល់ចប់ ។



ដំទៀតនេះ បើបេះតែងត្រូវជាព្រាន ជាសត្វ ហើយចេះបញ្ចេញទូវ លក្ខណៈសត្វនិមួយ ១ លេងជារឿងល្ខោនបាន នោះរឹងរឹតតែប្រសើរទៅទៀត ។



១– យប់មួយ ចចកដើរស្វែងរកចំណី ពុំបានសត្វអ្វីធ្វើជាអាហារសោះ ។ ដល់ពេលអស់កម្លាំងខ្លាំង វាចូលទៅសម្រាកនៅម្លប់ឈើ ។ វាដេកពុំលក់ ព្រោះចៃចេះតែរំខាន ។ បន្តិចមក មានស្វាមួយដើរមកជិតនោះ ។ ចចកឃើញស្វានឹកអរ ក៏និយាយថា:

- បងស្វា! ចៃខ្ញុំច្រើនណាស់ សូមបងជួយរកចៃខ្ញុំបន្តិច ។

ស្វាយល់ព្រមតាមចចកសុំ ។

– ចចកដេកឲ្យស្វាចាប់ចៃឲ្យ ។ ស្វារើករោមចចក បួតចៃម្តងមួយៗ ។ ចៃទាំងអស់ភ័យណាស់ រត់មកខាងចុងរោម នាំឲ្យចចកបាត់រមាស់ សម្ងំដេកបានស្រួល រហូតដល់លក់មិនដឹងខ្លួន ។

២ - ស្វាជាសត្វពិស ហើយខិលខូចផង ។ វាលួចចង

កន្ទុយបបក ភ្ជាប់នឹងគល់ឈើ ហើយរត់គេចបាត់ពីទីនោះទៅ ។

បបកភ្ញាក់ឡើងទៅណាមិនរួច ។ វាទំបែរះណាស់ដែរ ប៉ុន្តែកន្ទុយវាមិនរបូតពីគល់ឈើនោះ ។ ទទួលពេលនោះ អណ្តើកមួយវារមកដល់ បបកអង្វរអណ្តើកថា :

– សុំបង ជួយស្រាយបំណងកន្ទុយខ្ញុំផង ។

– ទាល់តែបបកឯងកុំស៊ីពងខ្ញុំ ទើបបានខ្ញុំជួយ ។

– ខ្ញុំសន្យាថា មិនធ្វើបាបបងអណ្តើកឯងទេ ។ អណ្តើកឮដូច្នោះ ក៏ជួយស្រាយកន្ទុយបបកបានរបូតពីគល់ឈើទៅ ។

២ – បបកខឹង តាមរកខាំស្វា ។ វាភ្លេចទាំងថា អរគុណដល់បងអណ្តើកផង ។ ស្វានឹកភ័យនឹងបបក ក៏រត់ឡើងដើមឈើហើយលោតពីចុងឈើមួយ ទៅចុងឈើមួយទៀត ។

តាំងពីកាលនោះមក ស្វារស់នៅតែលើដើមឈើ ។ វាពុំសូវហ៊ានចុះដីទេ ព្រោះវាខ្លាចសត្វបបកណាស់ ។

*ស្វែង : កិ. សង្កាត់រក ចំប្រឹងរកឲ្យបានដូចបំណង ។ ស្វែងទ្រព្យ ។*

*រពឹស : កិ. នៅមិនស្ងៀម បេះតែចាប់នេះ ចាប់នោះរឿយៗ មិនស្រាក ឯនកុំរពឹសពេក ។ រពឹសទីនេះជាគុ. ប្រែថា មស្យាហ៉ក្នុងការលេងខុសទំនង ក្មេងរពឹស ស្វាជាសត្វរពឹស ។*

● ជញ្ជាំងគំនិត : ក្មេងដែលមានចៃមានរូបរាងដូចម្ដេច ? មានទម្លាប់អាក្រក់ដូចម្ដេចខ្លះ? តាមអ្នកបានឃើញឬបានឮគេនិយាយ ទម្លាប់សត្វស្វាមានដូចម្ដេចខ្លះទៀត ? អ្នកជឿថា សត្វស្វានៅលើដើមឈើព្រោះខ្លាចចចកមែនឬទេ ?

● វេយ្យាករណ៍ : អំពីវណ្ណយុត្តិ អ. ប. ពន៌ ណៈ. យុត្ត

វណ្ណយុត្តិសម្រាប់ប្រើក្នុងភាសាខ្មែរ មាន ១៨ យ៉ាងគឺ :

| | | | | | |
|---|---|---|---|---|---|
| ១ – រះមុខ | = | ះ | ១០ – លេខអស្ដា | = | ៏ |
| ២ – ភ្នែកកណ្ដុរ | = | ៉ | ១១ – កែកមាន់ | = | ៎ |
| ៣ – ត្រីស័ព្ទ | = | ៊ | ១២ – ល្បះ | = | ។ |
| ៤ – បដិសេធ | = | ៍ | ១៣ – ល្បះចប់ | = | ៕ |
| ៥ – របាទ | = | ៌ | ១៤ – គោមូត្រ | = | ៚ |
| ៦ – បន្តក់ | = | ់ | ១៥ – ពត់ | = | { } |
| ៧ – សំយោគសញ្ញា | = | ័ | ១៦ – វង់សញ្ញា | = | ( – ) |
| ៨ – លេខទោ | = | ៗ | ១៧ – ពងត្រី | = | ... |
| ៩ – ជើងក្អែក | = | + | ១៨ – ឡាក | = | ។ល។ |

ឯយុគលពិន្ទុ : ទើបនឹងបង្កើតថ្មី សម្រាប់ប្រើចុចសម្រួលពាក្យឱ្យងាយ ថា ដូចជា ធុរៈ ការៈ លក្ខណៈ ជាដើម ។

● កិរិយាកម្ម : ចូរអ្នកឱ្យឈ្មោះ វណ្ណយុត្តិ ដែលមានប្រើក្នុងអត្ថបទខាងលើ ។



## ៦១–៦២– ឆ្កែដើររកមិត្ត

១ – រឿងមួយដំណាលថា:

កាលពីដើមឆ្កែជាសត្វព្រៃ មិនមែនជាសត្វស្រុកនៅជាមួយមនុស្ស ដូចសព្វថ្ងៃនេះទេ ។ វានៅក្នុងព្រៃតែឯកឯង ។ ដោយអផ្សុកខ្លាំងពេក ឆ្កែក៏ដើររកគ្នាធ្វើជាមិត្រ ។ លុះដើរៗទៅវាបានជួបនឹងទន្សាយមួយ ។ ទន្សាយឃើញឆ្កែ រៀបនឹងរត់ទៅហើយស្រាប់តែឆ្កែស្រែកឡើងថា:

– នែបងទន្សាយ ! ឈប់សិន ខ្ញុំចង់យកបងធ្វើជាមិត្រ មិនមែនចង់ធ្វើបាបបងទេ ។

– ប្រពៃហើយ ! បើបងគិតយ៉ាងនេះមែននោះ ខ្ញុំយល់ថាគួរ

យើងទាំងពីរនាក់ រស់នៅជាមួយគ្នាលមើលម្តង ។

២ - ទន្សាយនឹងផ្តៃ បណ្តើរគ្នាទៅរកកន្លែងនៅ ។ យប់មក

ដល់ ទន្សាយសម្ងំដេកលក់ភ្លាម ។ ឯផ្តៃដេកមិនលក់ទេ ព្រោះវា

ប៉េះតែឮស្លឹកឈើធ្លាក់ ឮសូរខ្យល់បក់មែកឈើ ឮសូរសត្វ

ហើរ . . . វាប្រុងខ្លួនជានិច្ចហើយវាស្រែកយ៉ាងខ្លាំង នាំឲ្យទន្សាយ

ភ្ញាក់ផ្អើលជាច្រើនដង ។ ទន្សាយខឹងហើយនិយាយថា :

- ឈប់ស្រែកទៅ ! តែកាលណាបបកឮ វាដឹងថាយើងនៅទី

នេះ មុខជាវាមកស៊ីយើងហើយ ។

៣ - ផ្តៃឈប់ស្រែកហើយគិតថា :

មិត្រអញជាសត្វកំសាកទេតើ អញមិនត្រូវនៅជាមួយវាទេ

គួរតែអញទៅរកបបកវិញ ។

ផ្តៃដើរទៅរកបបក ហោលទន្សាយឲ្យនៅដេកទីនោះតែម្នាក់

ឯង ។ លុះដើរបន្តិចទៅ ផ្តៃជួបបបកហើយនិយាយថា :

- បងបបក! ខ្ញុំចង់យកបងធ្វើមិត្តណាស់ ព្រោះខ្ញុំក៏ព្រាត់គ្នាគ្នា។

- ប្រពៃហើយ ! គួរតែយើងរស់នៅជាមួយគ្នាលមើលម្តង ។

៤ - ពេលថ្ងៃ ផ្តៃនឹងបបកនៅជាមួយគ្នាយ៉ាងសុខសាន្ត ប៉ុន្តែ

ដល់យប់ជ្រៅ ផ្តៃក៏តាំងស្រែកឡើងទៀត ។

បបកទឹង និយាយទៅឆ្កែថា:

– ឈប់ព្រុសទៅ ! តែកាលណាខ្លាឃ្មុំឮ មុខជាវាមកស៊ីយើងទាំងពីរនាក់ហើយ ។

ឆ្កែឈប់ព្រុសហើយគិតថា បបកគ្មានពូកែអ្វីទេ អាណេះខ្លាចខ្លាឃ្មុំ ។ ដូច្នេះ គួរអញទៅរកខ្លាឃ្មុំយកមកធ្វើជាមិត្រវិញ ។

ព្រុស : កិ. ស្រែក ក្ញាក់តក្រោតតក្រាំង រត់ ស្ទុះបោលដោយស្រែក ។

---

• ជញ្ជឹងគំនិត : ពេលយប់ឆ្កែព្រុសរកសត្វហើយ ។ អ្នកដឹងឬទេ តើសត្វអ្វីខ្លះ ហើយរកស៊ីយប់? ឆ្កែអ្នកព្រុសរាល់យប់ តើអ្នកបានសង្កេតមើលថាវាព្រុសអ្វីឬទេ?

• អំពីព្យាង្គ : (អ.ថ ព្យាង) ព្យាង្គ គឺសង្កាត់ពាក្យដូចជា នៅ - ធំ - នាង - ច្រើន - ផ្លាស់ ហៅថា ពាក្យមានព្យាង្គមួយ ឬមួយព្យាង្គ ។ បន្ទប់ - លំនៅ ចំណាស់-ចង្កៀង ហៅថា ពាក្យមានព្យាង្គពីរ ឬពីរព្យាង្គ ។ កន្ទាទូក-សណ្ដាប់ធ្នាប់-ចម្ប៉ាជាក់ ហៅថា ពាក្យមានព្យាង្គបី ឬបីព្យាង្គ ។ តាំងពីបួនសង្កាត់ឡើងទៅ ដូចជា អំពិលអំពែក ទោសានុទោស ជាដើម ហៅថា ពាក្យច្រើនព្យាង្គ ។

• ការិយកម្ម : ឲ្យសិស្សហាត់រកពាក្យមួយព្យាង្គ - ពីរព្យាង្គ ហើយនិងបីព្យាង្គ នៅក្នុងអត្ថបទខាងលើ ។



## ៦៣ – ឆ្កែយកអ្នកណាធ្វើជាមិត្រ

១– ឆ្កែលបរត់ចេញពីបបក ទៅជួបនឹងខ្លាឃ្មុំ ហើយនិយាយថា:
នែ! បងខ្លាឃ្មុំ ខ្ញុំចង់យកបងធ្វើជាមិត្រ ព្រោះខ្ញុំកំព្រាគ្មានគ្នា ។
– ប្រពៃហើយ ! គួរយើងរស់នៅជាមួយគ្នា គាលមើលអង ។
ខ្លាឃ្មុំនាំឆ្កែទៅកាត់រូង ដើម្បីនឹងសំរាក ប៉ុន្តែឆ្កែនៅមិនស្ងៀម ពេះ
តែព្រួសគ្មានឈប់ឈរសោះ ។ ខ្លាឃ្មុំខឹង ក៏និយាយទៅឆ្កែថា:
– ឈប់ព្រួសទៅ! តែកាលណាមនុស្សឮ មុខជាគេមកសម្លាប់
យើងទាំងពីរនាក់ហើយ ។
ឆ្កែឈប់ព្រួស ហើយគិតថា អាខ្លាឃ្មុំនេះ ខ្លាចមនុស្ស ។
វាមានតួកែជាងខ្លួនឯងនឹងបបកឯណា ។ ដូចនេះ គួរអញទៅរក
មនុស្សធ្វើមិត្រវិញទើបប្រសើរ ។

២ – ឆ្កែដើរចេញពីរូងខ្លាឃ្មុំ ហើយទៅជួបនឹងមនុស្ស ។

នែ ! បងមនុស្ស ខ្ញុំឮល្បីថា បងពូកែជាងគេ ហេតុនេះខ្ញុំសុំធ្វើជាមិត្តផង ព្រោះខ្ញុំកំព្រាគ្មានគ្នា ។

– ប្រពៃហើយ ! គួរយើងរស់នៅជាមួយគ្នាមើលម្តង ។ មនុស្សបណ្តើរឆ្កែទៅផ្ទះរបស់ខ្លួន ។ លុះដល់ពាក់កណ្តាលអធ្រាត្រឆ្កែឡើងព្រុសទៀត ។ មនុស្សភ្ញាក់ឡើង ស្រែកប្រាប់ឆ្កែថាៈ

នែឆ្កែ! ឯងស៊ីមិនឆ្អែតឬអ្វី បានជាឯងព្រុស បើឯងឃ្លានបូរឯងទៅស៊ីបំណាំនៅឯនោះទៅ ។

ឆ្កែឈប់ព្រុស ហើយគិតថា មនុស្សគ្មានខ្លាចសត្វណាមែន គួរអញយកគេធ្វើជាមិត្តទៅ ។

ក្រោយមក ឆ្កែបានដេកលក់ជួបមនុស្សដែរ ។ តាំងពីកាលនោះមក ឆ្កែព្រមរស់នៅជាមួយមនុស្ស រហូតមកដល់សព្វថ្ងៃ ។

---

ជញ្ជីងគិត : ឆ្កែដើរចោលទន្សាយ ព្រោះទន្សាយខ្លាចចចក ដើរចោលចចក ព្រោះចចកខ្លាចខ្លាឃ្មុំ . . . ចុះបើមនុស្សថា ខ្លាចយក្សទៅទៀតតើឆ្កែគិតយ៉ាងណា? ឆ្កែយកមនុស្សធ្វើមិត្តឬធ្វើចៅហ្វាយវា? ។ អ្នកយល់ឃើញដូចម្តេចចំពោះកិរិយាឆ្កែនេះ ឬជនណាមួយដែលប្តូរមិត្តញឹកញាប់បែបនេះ ?

ថ្លែងដោយទំនង ដំណើរដើមទងសត្វស្ការ
ឃើញមិត្រក្រសារ វាប្រាប់ថារុីយសំឡាញ់ ។
ថ្ងៃនេះគ្នាបាន ស្មោរត្រីពីរបានយ៉ាងឆ្ងាញ់
អញ្ជើញសំឡាញ់ មកស៊ីនឹងអញបានម្តង ។
ស្ការជ្ជូសស្មោររៀប ដាក់ក្នុងបានទៀបហើយហោង
លាយទឹកសាប់ផង ទើបអញ្ជើញបងក្រសារ ។
កុកខ្នួនកបុះ ហើយហាចំពុះស្រវា
ចឹកហាប់អាហារ ចឹកមិនបានការខកខាន ។
បំណែកប៉ែកស្ការ អណ្តាតស្រវាផ្លាប់បាន
មិនយូរប៉ុន្មាន ស៊ីអស់ពីរបានគ្មានសល់ ។
កុកឈប់ឈរគិត នៅក្នុងគំនិតខ្លាយខ្ចល់
លុះដឹងកិច្ចកល ថ្ងៃក្រោយមកដល់រូងស្ការ ។
កុកថាខ្ញុំមាន អន្ទង់ធាបៀនបងស្ការ
ស្នេកបងមេត្តា អញ្ជើញពិសាបំណាំ ។
ស្ការជាតែបង ! ហៅវិញនេះម្តងមានអី
អន្ទង់ឬត្រី ស្រេចនៅបងលៃបុះណា ។



លុះព្រឹកព្រហាម ស្ករភ្ញាក់ឡើងភ្លាមយាត្រា
ដល់ផ្ទះក្រសារ វាធុំក្លិនឆាអន្លង់ ។
កុកបានឃើញស្ករ ប្រញាប់ដួសឆាដាក់ក្អង.
ឬតីរពុំលង់ ស្ករក្ដរពោះបង់តែធី ។
កុកអញ្ជើញស្ករ មកបងពិសាចាំអី
ស្ករបួលរឹងទ្ទី តែទើសមាត់ខ្វុសខ្នាត ។
បំពុះនឹងឬ អាបល្បកកក្បរដល់បាត
កុកស៊ុសង្ហាត មិនមានឲ្យខាតពេលឡើយ ។
មួយស្ករនឹកឃ្លាន ពីរស្ករនឹកអៀនគ្មានស្បើយ
បាត់មាត់ឆ្លងឆ្លើយ រួបហើយក៏រត់បាត់ទៅ ។
នេះល្បើកបង្អុងតែន ប្រាកដមានមែនគង់នៅ

សោកតែងប្រដៅ ក្អួតហៅរកស៊ីបោកប្រាស ។

ដំណើរដើមទងសត្វស្វារ : ហេតុដែលស្វារនាំបង្កើតជាដំបូង ។

លុះដំណាក់កាល : លុះដំនួត ប្តូរប្បៀបសត្វស្វារ ។

ឃាត្រា : បេញដើរ ។ ជំ : កិ....ស៊ី ។ ហ្វូងដំណែង : មហាកវីជាតិប៉ាំង ក្នុងសតវត្សទី ១៧ ។

---

• ហាត់អានពាក្យ មិត្ត ទុំយ អញ ខ្លល់ កិច្ចកល ឃាត្រា វង្វឹង គុំលង់ ខុសខ្វាត ហ្វូងតែង ។

– ឲ្យសិស្សហាត់ធ្វើបទបន្ទោរកាក ក្រោយដែលគេបេះអានពាក្យពិបាក ហើយ ។ ដំបូងឲ្យធ្វើបទម្នាក់មួង ក្រោយមក ៤ ឬ ៥ នាក់ ជាមួយគ្នា ។

• ជញ្ជីងគិត : ចូរអ្នករៀបរាប់ពីទ្រង់ទ្រាយសត្វស្វារ និងក្រសារ ។ ហេតុអ្វីបានជាក្រសារបោកប្រាស់ស្វារ ? រឿងក្រសារនិងស្វារ ចង់ប្រដៅយើងថាយ៉ាងដូចម្ដេច ?

• ការសំដែងដោយសេរី : ឲ្យសិស្សតែងខ្លួនម្នាក់ធ្វើក្រសារ ម្នាក់ធ្វើស្វារ ដើរតួលេងតាមសាច់រឿងខាងលើ ដោយមានបានទៀត ថូ ស្មោគ្រ ហើយនឹងអន្ទង់ចៀនផង ។

## ៦៦ – ៦៧ – ចាបនឹងដំរី



១ – កាលនោះ នៅជាយព្រៃធំមួយ មានសត្វចាបហើយនឹង
ដំរី រស់នៅជាមួយគ្នា ។ ចាបជាសត្វតូចហើយឆ្លាត ។ ឯដំរីវិញ
ជាសត្វធំសំបើមហើយល្ងង់ ។ នៅទីនោះ សត្វទាំងពីរដណ្តើមគ្នា
ធ្វើស្តេចតែរឿង ៗ ខ្ញន ។ វារករឿងប្រជែងគ្នា យកឈ្នះយកចាញ់
តរាល់ថ្ងៃ ប៉ុន្តែមិនទាន់ឃើញសត្វណាមួយមានព្រៀបជាងឡើយ ។

២ – ថ្ងៃមួយ ដំរីបបួលចាបភ្នាល់ផឹកទឹក ។ វាថាម្តងនេះ
អ្នកណាផឹកទឹកបានច្រើនជាងគេ អ្នកនោះឈ្នះរហូត ។

ចាបនៅស្ងៀម គិតមួយសន្ទុះ ហើយថា៖

– បាន! ខ្ញុំព្រម បើដូច្នោះ យើងត្រូវនាំគ្នាទៅរកកន្លែងណា
ដែលមានទឹកច្រើន ។

ឮដូច្នោះ ដំរីត្រេកអរហើយលាន់មាត់ថា ទៅក៏ទៅ ! ។ ចាបហើរនាំផ្លូវដំរី ទៅទំនៅមែកឈើខាងមុខ ។ កាលណាដំរីទៅដល់ វាហើរទៅមុខទៀត ។ ចាបនាំដំរីកាត់ព្រៃ ឡើងភ្នំ កុំឲ្យប្រទះនឹងបឹងហើយនឹងព្រែក ។ លុះទៅដល់កំពូលភ្នំ វានាំដំរីចុះពីលើភ្នំសំដៅទៅសមុទ្រ ។

៣ – គាប់ជួនពេលនោះ ទឹកកំពុងតែជោរ ។ ចាបឆ្លៀតនិយាយទៅដំរីថា :

– ឯងជាសត្វធំ ហើយជាអ្នកបបួលអញភ្នាល់ផង បើដូច្នោះត្រូវឯងផឹកមុនអញ ។

ទឹកសមុទ្រប្រៃឈ្ងម ដំរីមិនងាយនឹងលេបទេ តែដោយចង់ឈ្នះផង ព្រមទាំងចង់ធ្វើជាស្ដេចផង វាក៏ខំបឺតទឹកតាមប្រមោយយកមកផឹកគ្មានឈប់ ។

ចាបថា : ខំទៅបង ផឹកទឹកប៉ុណ្ណឹងមិនទាន់ឈ្នះខំទេ ។

៤ – ទឹកសមុទ្រជោរឡើងឥតឈប់ ឡើងរហូតដល់ពោះទើបដំរីឈប់ផឹក ។

លុះទឹកនាបមកវិញ ចាបហើរទៅមាត់ទឹក ហើយឱនក្បាលជ្រលក់ចំពុះក្នុងទឹក ធ្វើយកធ្វើជាផឹក ។ ទឹកស្រកចុះ វាលោតទៅ

តាមទឹកស្រក ធ្វើផឹកតាំងពីតាយរហូតដល់ជើងដំរី ។ វាលោតតាមទឹកនាចផឹកបន្តទៅទៀត ។ វាផឹករហូត ផឹកទាល់តែដំរីឃាត់ថា៖ « ផឹកប៉ុណ្ណឹងបានហើយ »

តាំងពីកាលនោះមក សត្វបាបបានឡើងជាស្ដេចនៅព្រៃនោះទៅហោង ។

ជោរ : កិ. ពោរពេញ ទឹកជោរ ។ នាច : កិ. ស្រកចុះហើយមានជោរឡើងវិញ ទឹកជោរ ទឹកនាច ។ ឆ្លាស់ : កិ. តាំងប្រឡូកគ្នា មានក្រយាដំណាក់ ។

---

● ជញ្ជីងគិត : សមុទ្រមាននៅឯណានៅនគរយើង ? អ្នកដែលទៅលេងទឹកសមុទ្រឬទេ ? អ្នកឃើញទឹកសមុទ្រនាចឬទេ ? ទឹកសមុទ្រជោរឬទេ? ហេតុម្ដេចបានជាដំរី ព្រមចាញ់ចាប ? កម្លាំងនឹងប្រាជ្ញា តើមួយណាគ្រាន់បើជាងមួយណា ?

● តែងសេចក្ដី : ចូរអ្នកឆ្លើយនឹងសំនួរខាងក្រោម ។
ទឹកសមុទ្រមានរសជាតិដូចម្ដេច? ផឹកបានឬទេ ? គេយកទឹកសមុទ្រទៅធ្វើអ្វី? ស្រែអំបិលមាននៅឯណា ? ចូរអ្នករៀបរាប់អំពីប្រយោជន៍នៃទឹកសមុទ្រ ។





## ៦៨ – ខ្ញុំឃើញសមុទ្រជាលើកដំបូង

១– រថយន្តខ្ញុំ ចេញផុតពីទីវាលចូលក្នុងព្រៃ ចេញពីព្រៃចូលប្រកភ្នំ ។ ខ្យល់អាកាសត្រជាក់ប្លែក បានបក់មកប៉ះពាល់មុខខ្ញុំ ។ ដំណើរតាមផ្លូវទៅកាន់សមុទ្រនេះ ខ្ញុំឥតធុញទ្រាន់ក្នុងចិត្តទេ ។

២– ខ្ញុំសំឡឹងមើលទៅមុខ ឆ្ពោះទៅទិសខាងលិច ។ ពីកំពូលភ្នំ សមុទ្រលេចចេញផុតមកល្វឹងល្វើយ នាំឲ្យខ្ញុំរីករាយយ៉ាងក្រៃលែង ។ ខ្ញុំធ្លាប់ឃើញសមុទ្រតែក្នុងសៀវភៅ ខ្ញុំមិនដែលបានគិតស្មានថា សមុទ្រធំល្ហល្ហេវ មើលទៅ ឃើញតែទឹកហើយនឹងកោះសន្ធឹមបែកផ្សេង យ៉ាងនេះទេ ។

៣– ទៅដល់មាត់សមុទ្រ រថយន្តឈប់ ។ ខ្ញុំដើរកាត់ឆ្នេរ

ខ្សាច់ យកផើងលេងទឹករលក ។ សូររលកសមុទ្រគ្រាំៗ ដដែលៗ ។
តាមឆ្នេរខ្សាច់ សំបកលៀស-គ្រំ-ខ្យង-ខ្ចៅ... មានពណ៌ប្លែកៗ
រាយរណែល ។ ក្ដាមសមុទ្រមួយឃើញខ្ញុំ ភ័យលៀនភ្នែក ខ្ញុំលើក
ដង្កៀបរត់ទទឹងខ្លួនយ៉ាងលឿន ។ ទឹកសមុទ្រថ្លាខៀវ ធ្លុះឃើញ
ខ្សាច់ស ឃើញផ្ទាំងថ្មធំៗ ឃើញហ្វូងត្រីតូចៗហែលចុះហែលឡើង។

នៅឆ្នេរសមុទ្រ ជាលើកដំបូងនេះ ខ្ញុំស្រូបយកខ្យល់ល្អ ។ ខ្ញុំនឹកសរសើរសំណាងខ្ញុំ ដែលបានមកឃើញសមុទ្រផ្ទាល់នឹងភ្នែក។

*លឹងល្វើយ : គុ. ល្ហល្ហេវក្រៃពេក•ធំពេក-រាលលឹងល្វើយ ។*

*សន្ធឹម : គុ. ដែលឆ្ងាយឃើញសន្ធឹម សន្ធឹមបែកផ្សែង សន្ធឹមបាត់ត្រើយ ។*

---

● **ជញ្ជាំងគិត** : *អ្នកដែលទៅសមុទ្រឬទេ ? តាមផ្លូវណា ? តាមផ្លូវទៅកាន់សមុទ្រ ចិត្តអ្នកមានធុញទ្រាន់ដែរឬ ? អ្នកឃើញសមុទ្រយ៉ាងដូចម្ដេច ? នៅឆ្នេរសមុទ្រអ្នកឃើញអ្វីខ្លះ ?*

● **រៀនពាក្យ** : *អំពីសមុទ្រ : នាម : សមុទ្រ រលក កោះ ច្រាំង ឆ្នេរខ្សាច់ ផ្ទាំងថ្ម ត្រី ខ្យង ខ្ចៅ គ្រំ ក្ដាម សារាយ ឈើសមុទ្រ ។ គុណនាម : លឹងល្វើយ សន្ធឹម ល្ហល្ហេវ ខ្ពោលៗ ប្រៃ ថ្លា រណែល ។ កិរិយាសព្ទ : ធ្វើដំណើរ នេសាទ បោកបក់ ខ្យល់ព្យុះ នាច ដោរ សំរាក ។*

● **ការិយកម្ម** : *ឲ្យសិស្សគូរសមុទ្រ ដោយមានរំលេចរូបអ្វីៗ ដែលមានក្នុងសមុទ្រ ហើយដាក់ឈ្មោះពីក្រោមផង ។*

១ – ថ្ងៃនេះ សុធី សប្បាយចិត្តណាស់ ព្រោះជាលើកដំបូងបង្អស់ ដែលវាបានជិះទូកជាមួយបងវាឈ្មោះ សំអាន ទៅស្ទូចត្រីនៅសមុទ្រ ។ ពេលនោះអាកាសក្ដៅ ខ្យល់បក់មកល្ហិចៗ សមុទ្រមានរលកអង្កាញ់ៗ ។ នៅកន្សៀទូក សំអាន អុំមួយៗ ។ សុធីអង្គុយនៅកណ្ដាលទូក ភ្នែកវាសំឡឹងទៅឆ្ងាយ ព្រោះបងវាបានប្រាប់ថា បើមិនបង់ឲ្យពុលរលក តោងកុំឈ្ងោកមើលទឹកជិតៗទូកយូរពេក ។

២ – នៅជិត សុធី មានមែកឈើមួយធំជាប់ទាំងស្លឹកផង សុធីនឹកឆ្ងល់សួរទៅសំអានថា :

– បះបងយកមែកឈើនេះ មកធ្វើអ្វី ?

សំអាន មិនព្រមប្រាប់ប្អូនវា ថាយ៉ាងណាទេ វាគ្រាន់តែថា :

– ឯងចាំតែមើលទៅ ។

៣– ទូកទៅឆ្ងាយពីច្រាំងសមុទ្រ បានប្រហែល ៣០០ ម៉ែត្រ ហើយ តែទឹកសមុទ្រនៅរាក់ទេ ព្រោះមានពណ៌សតាមដីខ្សាច់នៅឡើយ ។ សំអាន បោះយុថ្កាទៅកុងទឹក ហើយបង្គាប់ សុធីឲ្យលើកមែកឈើចងភ្ជាប់នៅគែមទូក ។

៤ – កុមារទាំងពីរ យកដងសន្ទូចមួយម្នាក់មកលាខ្សែ ដែល



មានកូនសំណាមួយធំ ហើយនឹងផ្លែសន្ទូចបី-បួននៅបុង ។ គេនាំគ្នាបិទនុយបង្គានៅផ្លែសន្ទូច រួចបោះទៅក្នុងទឹក ។ ខ្សែសន្ទូចញាក់ញឹក ៗ ដូចជាមានអ្វីមួយមកទាញ ។ សុធី បុកពោះ... ភាភាត់ដងសន្ទូចឡើង ឃើញត្រីពីរថូបត្រីផ្ទក់ជាប់នៅផ្លែសន្ទូច ។ សុធី លាន់មាត់ថា: យី! បងសំអាន នៅសមុទ្រមានត្រីផ្ទក់ដែរ ?

សំអាន ញឹម ៗ ហើយប្រាប់ប្អូនថា :

– គេហៅថា ត្រីព្រលោះ កន្លែងនេះមានតែត្រីហ៊ឹងទេ ។ កុមារទាំងពីរហាប់សន្ទូចតទៅទៀត ម្ដងភាភាត់បានមួយ ម្ដងភាត់បានពីរ ។

៥ – កាលកំពុងសប្បាយភាត់ត្រី សុធីភ្លេចកំដៅព្រះអាទិត្យ ។ លុះដល់ត្រីអន់ស៊ីសន្ទូច ទើបភារកម្លប់ស្លឹកឈើជ្រក នៅកណ្ដាលទូក ។ នុយបង់អស់ ត្រីបានបង្គួរដែរហើយ សំអានក៏បបួលសុធី

ត្រឡប់មកផ្ទះវិញ ព្រោះវាដឹងថា: ត្រីព្រលោះនេះ ស៊ីសត្វតែមួយសាៗទេ ។

សំអាន ស្រាវយុត្ថា ហើយកាន់ប្រវាផ្ទាប់នៅក្បែរទូកធ្វើចង្កូត។ ម្តងនេះវាមិនបាច់អុំទេ ព្រោះខ្យល់បក់បំស្លឹកឈើ បានធ្វើឲ្យទូកអ្នកនេសាទយើង ត្រឡប់មុខទៅរកច្រាំងវិញយ៉ាងស្រួល ។

*រលកអន្ទាញ់ : រំជួលទឹកដែលខ្ពស់ៗឡើង ដោយកំណាចកម្លាំងខ្យល់ ។ រលកដែលតូចៗ ល្អើបៗ សណ្ឋានដូចពស់ដកតពារ ។ កន្សៃទូក : ប៉ែកខាងក្រោយទូក ។ យុត្ថា : ដែកមានដៃទំពក់ពីរ ចងនឹងខ្សែពួរសម្រាប់ទម្លាក់ទៅបាតទឹកចតទូក ឲ្យនៅនឹងមួយកន្លែង ។ បង្កា : ព្រានសមុទ្រ ។ សត្វទឹកមួយក្រុម ដែលមានរូបរាងដូចកំពឹស ។*

---

• *ជញ្ជឹងគិត : តើឃ្លាណាខ្លះដែលបង្ហាញឲ្យឃើញថា សំអាន ស្ទាត់ជំនាញខាងការនេសាទត្រីនៅសមុទ្រ ? ពីព្រោះអ្វី បានជានៅកន្លែងខ្លះចម្ងាយ ៤០០ ឬ ៥០០ ម៉ែត្រពីច្រាំង សមុទ្រនៅរាក់? ។ ចូរពន្យល់ ហេតុអ្វីបានជាយុត្ថា អាចធ្វើឲ្យទូកនៅនឹងមួយកន្លែងបាន ។ សន្ទូចសម្រាប់ត្រីសមុទ្រ គ្មានកំសួលទេ ចុះដល់ត្រីស៊ីនុយគេអាចដងដូចម្ដេចបាន ? ។*



# ៧១-៧២ — បងប្អូនបីនាក់

១– បុរសម្នាក់ មានកូនប្រុសបីនាក់ ហើយនឹងផ្ទះមួយជាសម្បត្តិទ្រព្យ ។ គាត់ស្រឡាញ់កូនទាំងបីស្មើៗគ្នា តែកូនម្នាក់ៗមានចិត្តលោភ ចង់បានផ្ទះនោះតែសព្វៗខ្លួន ។ ឪពុកគិតថាមានតែលក់ផ្ទះយកប្រាក់ មកចែកគ្នាទើបបាន ។ ប៉ុន្តែដល់នឹកឃើញថា ផ្ទះនោះជាកេរ្តិ៍ដំណែលពីដូន-តាមក គាត់ពិបាកចិត្តយ៉ាងក្រៃលែង ។

គិតយូរៗទៅ ឪពុកសម្រេចឲ្យកូនទាំងបីនាក់ ចេញពីស្រុកដើម្បីម្នាក់ៗបានហាត់រៀនមុខរបរអ្វីមួយ ។ មុននឹងចេញដំណើរឪពុកផ្តាំថា "អ្នកណាជំនាញក្នុងមុខរបរណាមួយជាងគេ អ្នកនោះត្រូវបានផ្ទះនេះជារង្វាន់" ។

កូនទាំងបីនាក់ សប្បាយចិត្តពេក បានស្រុះស្រួលគ្នាចេញទៅរករៀនវិជ្ជាភ្លាម ។ គេណាត់ពេលគ្នាថា គ្រប់ ៥ ឆ្នាំបានត្រឡប់មកផ្ទះវិញ ។

២– បងបង្អស់រៀនធ្វើជាងដែក ប្អូនបន្ទាប់រៀនធ្វើជាងកាត់សក់ប្អូនពៅរៀនវិជ្ជាខាងហាត់គុន ។ ទាំងបីរូប មានប្ញីដៃកម្រមានអ្នកណាប្រដូចបាន ។



ជាងដែកអាចបិទ-ប៉ះ-ដោះ-ដាក់-ផ្សារភ្ជិតដែកយ៉ាងបំណាន ហើយឆាប់រហ័សផង ។ វាសង្ឃឹមថា “ ផ្ទះមុខជាបានវា ” ។

ជាងគំនូរធ្លាក់-គូររូបដាក់តាំងប្រឡងបានឈ្នះគេ ។ នៅទីក្រុង គេតែងសរសើរស្នាដៃវាគ្រប់ ៗ គ្នា ។ វានឹកថា “ នឹងបានផ្ទះនោះដែរ ” ។

អ្នកហាត់គុនមានស្លាកស្នាមពាសពេញខ្លួន ឃើញនៅគង់តែផ្អែញមិនបាក់ប៉ុណ្ណោះ ។ វានឹកថាខ្លួនវាស៊ូទ្រាំដល់ថ្នាក់នេះហើយ “ ប្រហែលជាបានផ្ទះដែរ ” ។

ពាក្យដំណែល : ទ. របស់បានពីជូនតា ឬពីឪពុកម្ដាយដែលគាត់ចែក
មក ៗ ជំនាញ : គុ. ដែលកន់វៃប៉ិនប្រសប់ ៗ ថ្វីដៃ ទ. ស្នាដៃ បំណាច់ដៃ ធ្វើ
រយកថ្វីដៃមនុស្សមានថ្វីដៃ ៗ ស្នាក ស្នាម : ទ. សំណាមដែលជាប់នឹងខ្លួន ៗ

---

● ជញ្ជីងគិត : ហេតុម្ដេចបានជាឪពុកមិនចង់លក់ផ្ទះ? ឪពុកសម្រេចចិត្ត
ដូចម្ដេច? កូនទៅរៀនបានជាអ្វីខ្លះ? ម្នាក់ៗសង្ឃឹមថាដូចម្ដេច? ពីព្រោះអ្វី?
ពុកអ្នកឲ្យអ្នកទៅរៀនមុខរបរណាមួយដូចក្នុងអត្ថបទនេះ តើអ្នកចង់រៀនធ្វើអ្វី?

● វេយ្យាករណ៍ : អំពីព្យញ្ជនៈ: ព្យញ្ជនៈសម្រាប់ប្រើក្នុងភាសាខ្មែរ
ន ៣៣ តួគឺ : ក ខ គ ឃ ង - ច ឆ ជ ឈ ញ - ដ ឋ ឌ ឍ ណ - ត ថ
ធ ន - ប ផ ព ភ ម - យ រ ល វ ស ហ ឡ អ ។ អក្សរមានវគ្គគឺព្យញ្ជនៈ
២៥ តួ តាំងពី ក ដល់ ម ចែកជាវគ្គមាន ៥ គឺ កវគ្គ ចវគ្គ ដវគ្គ តវគ្គ បវគ្គ
តាំងពី យ រៀងទៅ ហៅថា អក្សរសេសវគ្គ ឬអក្សរ អវគ្គ ។

● សំនួរ : ព្យញ្ជនៈមានប៉ុន្មានតួ? អក្សរមានវគ្គមានប៉ុន្មាន? អវគ្គមាន
ប៉ុន្មាន? ចូរអ្នកកាប់វគ្គអក្សរទាំង ៥ មកមើល ។





លុះគ្រប់កំណត់ឆ្នាំ បងប្អូ ទាំងបីនាក់មកដល់ផ្ទះវិញ ។ គេអង្គុយជុំគ្នានៅរានហាលផ្ទះ ម្នាក់ៗ នឹកចង់បញ្ចេញថ្វីដៃតែ រៀងខ្លួន ។

ជួនពេលនោះ មានសេដ្ឋី ម្នាក់ជិះសេះកាត់មុខផ្ទះ ទៅ បរបាញ់សត្វ ។ ជាងដែកនឹក ថា : នេះជាមុខការរបស់អញហើយ វាស្ទុះរត់តាមសេះដែលកំពុង ផាយ ទៅដកដែកពីជើងសេះទាំងបួន ហើយដាក់ដែកថ្មីជំនួស វិញ ។ ឪពុកសរសើរថា : "បើកូនពីរទៀតមិនបានប្រហែល ឯងទេ ផ្ទះនេះជារបស់ឯងហើយ" ។

កូនទីពីរឃើញបងបញ្ចេញបំណោះវិជ្ជាដូច្នេះ ក៏យកក្រដាស ខ្មៅដៃ មកឆាប់គូររូបសេដ្ឋីជិះសេះហើយនឹងបងវា ដែលរត់តាមដោះ ដែកពីជើងសេះ បានដូចឥតខ្ចោះ ។

ឪពុកថា "ឯងគ្រាន់បើ មិនចាញ់បងឯងទេ បើកូនពៅ

សប់មិនដល់ឯង ផ្ទះនេះមុខជាបានឯង ទាំងពីរនាក់ហើយ ,, ។

រំពេចនោះ ស្រាប់តែមានភ្លៀងមួយមេធំធ្លាក់មក ប្អូនពៅ
ាតទៅកណ្តាលវាល ដកដាវគ្រវីលើក្បាល ។ ភ្លៀងធ្លាក់កាន់
ខ្លាំង វាគ្រវីកាន់តែញាប់ឡើង ។ លុះភ្លៀងរាំង គេឃើញខ្លួនវា
តបែស សូម្បីតែខោ-អាវក៏គ្មានទទឹកដែរ ។ ឪពុកថា "ឯងមាន
ដជាងគេ ដូច្នេះ ផ្ទះនេះត្រូវបានជារង្វាន់ដល់ឯងហើយ ,, ។

កូនបងទាំងពីរនាក់យល់ថា ការកាត់សេចក្តីនេះត្រឹមត្រូវ ក៏
តមានប្រណែននឹងប្អូនឡើយ ។ អ្នកហាត់គុណជាមនុស្សល្អ សុខ
ត្តឲ្យបងទាំងពីរនៅផ្ទះនេះ ជាមួយគ្នា ។ ឪពុកសប្បាយចិត្តណាស់
លបើបានឃើញបងប្អូនទាំងបីនាក់ ចេះស្រឡាញ់គ្នា យ៉ាងនេះ ។

ប្រែសម្រួលតាម គុលស្ទួយ

៩ ត ៖ ព្វា : គ. ដែលផ្ទួចរូបភាពដើមពុំមានខុស ។

---

៨ ញ្ញ ផ៏គិត : បងប្អូនទាំងបីនាក់បញ្ចេញថ្វីដៃយ៉ាងណាខ្លះ ? អ្នកណា
ះគេ? ចុះបងទាំងពីរនាក់ ? អ្នកយល់ថាឪពុកកាត់សេចក្តីត្រឹមត្រូវឬទេ ?
ព្រោះអ្វី ? ចុងក្រោយបង្អស់ ហេតុម្តេចបានជាឪពុកសប្បាយចិត្ត ។

ការសំដែងដោយសេរី : ចូរអ្នកនិយាយរឿងបងប្អូនបីនាក់នេះ
ះយើងបានស្តាប់គ្រប់គ្នាមកមើល ។



## ៧៤ — ភ្ជុំបិណ្ឌ

១ - រៀងរាល់ឆ្នាំ មុនថ្ងៃ ១៥ រោច ខែភទ្របទ ខ្មែរយើងតែងតែរៀបចំនំអន្សម នំជាល នំគម ។ល។ ទុកសម្រាប់ធ្វើបុណ្យភ្ជុំឯវត្តរៀងៗខ្លួន មិនសូវមានអ្នកណាមួយខានឡើយ ។

២ - នៅថ្ងៃភ្ជុំ វត្តនីមួយៗ មានសភាពអ៊ូអរខុសពីប្រក្រតី ។ មនុស្សប្រុស-ស្រី ក្មេង ចាស់ ស្លៀកពាក់ខោ-អាវថ្មីៗ យ៉ាងសមរម្យ ទៅជួបជុំគ្នានៅសាលាបុណ្យ ដើម្បីប្រគេនបង្ហាន់ព្រះសង្ឃ ហើយនឹងស្ដាប់លោកសូត្រធម៌ ។

៣ - បុណ្យភ្ជុំបិណ្ឌ ធ្វើឡើងដើម្បីប្រមូលញាតិមិត្ត ជិត

ាយឱ្យមូលគ្នានៅវត្ត ប្រយោជន៍និមន្តព្រះសង្ឃបង្សុកូល ជូនផល
ុណ្យ ជាកិច្ចតបស្នងសងគុណចំពោះបុព្វការី ដែលបានចាកឋាន
ទៅហើយ ។

តាមធម្មតា ខ្មែរយើងធ្វើបុណ្យភ្ជុំបិណ្ឌនៅវត្ត គេមិនសូវធ្វើ
ុណ្យនេះនៅផ្ទះ ឬនៅទីដទៃណាទៀតឡើយ ។

ពន្យល់ពាក្យ : ភ្ជុំ : កិ. ធ្វើឱ្យជុំ ឱ្យជួបជុំ ភ្ជុំគ្នា ភ្ជុំពល ។
បិណ្ឌ : ន. ការប្រមូលឱ្យមូល ឬពូតឱ្យជាដុំ ។ បុព្វការី : ន. អ្នកដែលបាន
ធ្វើសេចក្ដីទំនុកបំរុងផ្ដើមមុនគេ ។ មាតាបិតាជាបុព្វការីរបស់កូន ។ គ្រូជា
បុព្វការីរបស់សិស្ស ។ ចាកឋាន : កិ. បែកកន្លែង ឃ្លាតចាកកន្លែងដើម ។
(កន្លែងនេះ សំដៅ អ្នកដែលស្លាប់ហើយ) ។

---

● ជញ្ជាំងគិត : នៅថ្ងៃខែណា ខ្មែរយើងធ្វើបុណ្យភ្ជុំបិណ្ឌ? បើគិតពីថ្ងៃ
នេះទៅ នៅប៉ុន្មានថ្ងៃ ប៉ុន្មានខែទៀត បានដល់ភ្ជុំបិណ្ឌ? ខ្មែរយើងនិយម
ធ្វើនំអ្វីសម្រាប់បុណ្យភ្ជុំបិណ្ឌ? នៅពេលភ្ជុំបិណ្ឌម្ដងៗ ឪពុកម្ដាយអ្នកទៅ
វត្តណាខ្លះ? ពីព្រោះអ្វី?

● វេយ្យាករណ៍ : ចូរអ្នករកពាក្យផ្ទុយនឹងពាក្យ ប្រជុំ បុណ្យ ញាតិ
គុណ ឆ្ងាយ-អ៊ីអរ ។

# ៧៦ – ចូលឆ្នាំខ្មែរ



១ – ពិធីចូលឆ្នាំខ្មែរ ធ្វើនៅថ្ងៃទី ១៣ ខែមេសារៀងរាល់ឆ្នាំ ។ ជិតដល់ចូលឆ្នាំថ្មីម្ដង ៗ គេសំអាតភូមិហើយលំអផ្ទះនឹងផ្កាឈើ ឬ ផ្កាក្រដាស ដោយមានរំលេចទង់ជាតិ និង ទង់សាសនាផង ។

២ – នៅមុខផ្ទះ គេរៀបចំតុមួយ ដ៏មានធូប-ទៀន-ផ្កា និង ទឹកអប់ ព្រមទាំងផ្លែឈើផ្សេង ៗ សម្រាប់ទទួលទេវតាថ្មី ។ គេតែងបំភ្លឺផ្ទះនិងលំផ្លូងបង្កៀងអគ្គិសនី ហើយនិងគោមក្រដាស គ្រប់ពណ៌ព្រោងព្រាត ។

៣ – ក្នុងឱកាសចូលឆ្នាំថ្មី ខ្មែរយើងតែងខ្លួនទៅវត្ត ឬទៅ

ជូនពរដល់អ្នកមានគុណ ឲ្យបានសុខចំរើនគ្រប់ៗគ្នា ។ វេលាថ្ងៃអ្នកស្រុកតែងនាំគ្នាលេងល្បែងផ្សេងៗ ដូចជាបោះឈូង លេងអង្គុញ ទាញព្រ័ត្រ ទាត់សី លោតអន្ទាក់ ហើយនិង ស្តេចចង់ ។ វេលាយប់ស្រី-ប្រុស នាំគ្នាច្រៀងប្របកែ ឬ រាំវង់នៅជុំវិញតុផ្កាមួយយ៉ាងសប្បាយ ។

ពិធីបុណ្យចូលឆ្នាំនេះ ប្រជាជនខ្លះនិយមធ្វើនៅវត្ត ខ្លះនិយមធ្វើនៅក្នុងភូមិ ឬក៏ធ្វើនៅផ្ទះរៀងៗខ្លួន ។

ប្រជាជន : ន. មនុស្សដែលចំណុះស្រុក ។

---

● ពង្រីកគំនិត : គេធ្វើបុណ្យចូលឆ្នាំខ្មែរនៅថ្ងៃ ខែ ណា ? បើគិតពីថ្ងៃនេះទៅ នៅប៉ុន្មានថ្ងៃទៀត ? នៅពេលចូលឆ្នាំខ្មែរ គេលេងល្បែងអ្វីខ្លះ ?

● តែងសេចក្តី : ចូរអ្នកនិយាយពីផ្ទះអ្នកនៅពេលចូលឆ្នាំខ្មែរ តើមានសភាពប្លែកពីធម្មតាយ៉ាងណាខ្លះ ។ អ្នកគិតឃើញយ៉ាងណាក្នុងឱកាសចូលឆ្នាំខ្មែរ ។



# បញ្ជីអត្ថបទ


| លេខរៀង | ចំណងជើងអត្ថបទ | ទំព័រ | លេខរៀង | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|---|---|---|
| ១– | បំណង ស៊ីនិម | ១ | ៣៦-៣៧ | នៅលើអាកាស | ៥៥ |
| ២-៣ | ស៊ីនិមមានមាន់មួយហើយ | ៣ | ៣៨-៣៩ | គ្រោះថ្នាក់តាមដំណើរ | ៥៧ |
| ៤-៥ | នៅផ្សារបំបក់ | ៦ | ៤០–៤១ | ដំណើរ | ៦០ |
| ៦- | ស៊ីនិមលក់អាទោលមិនដាច់ទេ | ៩ | ៤២–៤៣ | ជាងកាត់សក់នៅភូមិខ្ញុំ | ៦២ |
| ៧-៨ | ការងារ | ១១ | ៤៤ | ជាងដែកយើង | ៦៤ |
| ៩– | គ្រួសារពៅមឿន | ១៣ | ៤៥ | ជាងដែកយើង ឥតឈប់ | ៦៦ |
| ១០- | បងប្អូនពៅមឿន | ១៥ | ៤៦–៤៧ | ជាងកាត់ដេរនៅភូមិខ្ញុំ | ៦៨ |
| ១១– | ដីតាយើង | ១៧ | ៤៨ | ផ្ទះកំពុងសង់ | ៧០ |
| ១២– | យើងទៅទួលតា | ១៩ | ៤៩-៥០ | មេគំពៅនឹងបត្រិត | ៧២ |
| ១៣–១៤ | ពៅមឿនសុទ្ធចិត្តខានញ៉ាំបង្អែម | ២១ | ៥១-៥២ | អ្នក ណា យាមព្រៃអមលាំង? | ៧៤ |
| ១៥– | ឆាងម៉ុមនឹងមេឆ្មា | ២៤ | ៥៣–៥៤ | អ្នកយាមមានពុត | ៧៧ |
| ១៦- | មេឆ្មា និង កូន | ២៦ | ៥៥–៥៦ | ការជ្រើសរើសអ្នកយាម | ៨០ |
| ១៧-១៨ | បំណងខ្ញុំ | ២៨ | ៥៧-៥៨ | ក្លោកអ្នកយាម | ៨៣ |
| ១៩– | ពៅមឿនបង់ទៅឃ្វាលគោ | ៣០ | ៥៩–៦០ | ចចក និង ស្វា | ៨៦ |
| ២០–២១ | ជួប និងពៅមឿនទៅឃ្វាលគោ | ៣២ | ៦១-៦២ | ឆ្កែដើររកមិត្រ | ៨៩ |
| ២២–២៣ | ដើមផ្កានឹងដើមឈើស៊ីផ្លែ | ៣៤ | ៦៣ | ឆ្កែយកអ្នកណាធ្វើជាមិត្រ | ៩២ |
| ២៤– | ទាហានល្បាតរបស់អ្នកចំការ | ៣៦ | ៦៤-៦៥ | ក្រសារ និង ស្ការ | ៩៤ |
| ២៥– | ស្រែប្រាំង | ៣៨ | ៦៦-៦៧ | ពាប និង ដំរី | ៩៧ |
| ២៦-២៧ | ច្រូតស្រូវ | ៤០ | ៦៨ | ខ្ញុំឃើញសមុទ្រជាលើកដំបូង | ១០០ |
| ២៨-២៩ | ល្បែងលក់ផ្ទះ | ៤២ | ៦៩-៧០ | ស្ទូចត្រីសមុទ្រ | ១០២ |
| ៣០- | ជ្រូក ពពែ និង ចៀម | ៤៥ | ៧១-៧២ | បងប្អូនបីនាក់ | ១០៥ |
| ៣១– | ផ្លូវក្រឡែងកែង | ៤៧ | ៧៣-៧៤ | បងប្អូនបីនាក់បញ្ចេញថ្វីដៃ | ១០៨ |
| ៣២-៣៣ | ទីក្រុង | ៤៩ | ៧៥ | ភ្នំពិណ្ឌ | ១១០ |
| ៣៤-៣៥ | កន្លែងធ្វើដំណើរ | ៥២ | ៧៦ | ចូលឆ្នាំខ្មែរ | ១១២ |

មានលក់ដុំនិងរាយនៅ

**Librairie et Imprimerie**
**PHNOM-PENH**
**59, VITHEI PASTEUR, 59**
**PHNOM-PENH**

# ក្បួនសៀវភៅសិក្សាដែលយើងបានចេញផ្សាយហើយ

ឈួក . ម៉ុង . ម៉ៅ — ញ៉ូវ . ហោង
អធិការបឋមសិក្សា — គ្រូបង្រៀន

## យើងរៀនអាន

- រៀនអានថ្នាក់ទី ១២ និពន្ធរួមជាមួយគណៈកម្មការជាតិ ពិនិត្យសៀវភៅសិក្សា ( បោះពុម្ពទៅ - ស ) ។

## យើងអាន

- រៀនអានថ្នាក់ទី ១១ បោះពុម្ពពីរពណ៌ចេញផ្សាយគ.ស ១៩៦២ ( ប្រកាសលេខ - ២០៦៦ ចុះថ្ងៃទី ១៩ - ៦ . ៦៣ ) ។
- រៀនអានថ្នាក់ទី ១០ បោះពុម្ពពណ៌លឿង ថៃគង ក្រហម ( ប្រកាសលេខ ៦៤៨២ ចុះថ្ងៃទី ៣ - ៦ - ៦៤ )

## សុភាវធម៌

សម្រាប់គ្រូបង្រៀន គ្រប់ថ្នាក់ នៅសាលាបឋមសិក្សា
( ប្រកាសលេខ - ១៩៤៦ ចុះថ្ងៃទី ១ . ៦ . ៦០ ) ។

កេងពុម្ពសុី ៧៤៣ វិថីជិនកាឃាំង ៥ ខែ ២៦៩